ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Feb-2013, 10:33
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៣**

**ម៉ោង ០៩: ១៨នាទី**

**សវនាការលើកទី១៥៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក រ៉ូជឺ ហ្វីលីព

*(Mr. Roger Phillips)*

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី

*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វេង ហ៊ត់

លោក វីល្លៀម ស្មីត

*(Mr. William SMITH)*

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត *(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉េង ហ៊ាត់ | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:១៩:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនេះ អង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយ គឺជាសវនាការការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានាពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ដែលនៅក្នុងអំឡុងពេលនេះនឹងដាក់ឡើងដោយតំណាងសហព្រះរាជអាជ្ញា ហើយនិងការធ្វើអត្ថាធិប្បាយ ឬការជំទាស់ និងការឆ្លើយតបទៅនឹងការជំទាស់របស់ភាគីនានាពាក់ព័ន្ធទៅនឹងប្រធានបទនេះ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី ដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមានលើកលែងតែលោក ម៉ៃខល កាណាវាស មេធាវីអន្តរជាតិការពារក្តីឲ្យលោក អៀង សារី អវត្តមានដោយមូលហេតុសុខភាព។ ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ រីឯជនជាប់ចោទ នួន ជា អវត្តមានដោយមូលហេតុសុខភាព និងកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ ប៉ុន្តែជនជាប់ចោទ បានដាក់នូវលិខិតលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការលើឯកសារនេះ ឯកសារលេខ E258/2។ ហើយជនជាប់ចោទ ខៀវ សំផន អវត្តមានដោយមូលហេតុសុខភាព ប៉ុន្តែកាលពីម្សិលមិញនេះ ជនជាប់ចោទបានស្នើសុំតាមរយៈមេធាវីរបស់ខ្លួន ក្នុងការលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការលើឯកសារនេះ។ សូមអរគុណ។

[០៩:២១:២៨]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណលោកស្រី សែ កុលវុឌ្ឍី។ បាទ ចំពោះករណីអវត្តមានជនជាប់ចោទ នួន ជា

អង្គជំនុំជម្រះតម្កល់នូវសេចក្ដីសម្រេចរបស់ខ្លួនទុកជាបានការដដែល គឺសម្រេចទទួលសំណើសុំរបស់គាត់សុំលះបង់សិទ្ធិមានវត្តមាន នៅក្នុងកិច្ចដំណើរការសវនាការដាក់បង្ហាញឯកសារភស្តុតាងជាកន្លឹះនៅចំពោះមុខអង្គជំនុំជម្រះ ដែលអង្គជំនុំជម្រះបានសម្រេចនៅក្នុងអំឡុងពេលដើមដំបូងនៃដំណើរការសវនាការដាក់បង្ហាញឯកសារនេះ។ ដោយសារមូលហេតុ គាត់មានបញ្ហាសុខភាព ហើយតាំងពីពេលនោះមករហូតដល់ពេលនេះ បានកំពុងសម្រាកព្យាបាលនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ដោយឡែកបញ្ហាលោក ខៀវ សំផន អង្គជំនុំជម្រះសូមរំឭកអំពីអនុស្សរណៈរបស់ខ្លួនដែលបានចេញកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៣ ឯកសារ E223/5 គឺកាលពីម្សិលមិញនេះ នៅពេលមុនបញ្ចប់កិច្ចដំណើរការសវនាការ មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំលះបង់សិទ្ធិមានវត្តមានក្នុងការរបស់លោក ខៀវ សំផន ក្នុងអំឡុងពេលបង្ហាញឯកសារនានា ដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធបំផុតទៅនឹងការស្វែងរកការពិតនៅក្នុងសំណុំរឿង០០២/០១។ ហើយអង្គជំនុំជម្រះក៏សង្កត់ធ្ងន់ពីសារៈសំខាន់នៃសវនាការលើឯកសារ ជាគន្លឹះសក្ខានុពលភស្តុតាងដាក់បន្ទុកដែលត្រូវយកមកពិភាក្សា និងអំពីបំណងប្រាថ្នាឲ្យជនជាប់ចោទមានវត្តមាននៅក្នុងអំឡុងពេលបង្ហាញឯកសារនានា ដែលពាក់ព័ន្ធទៅនឹងជនជាប់ចោទ។

[០៩:២៣:១៥]

ទោះជាយ៉ាងនេះក្ដី អង្គជំនុំជម្រះក៏កត់សម្គាល់ផងដែរថា ដោយសារជនជាប់ចោទទើបតែវិលត្រឡប់មកកាន់មន្ទីរឃុំឃាំងនៅ អ.វ.ត.ក នេះវិញនានាពេលថ្មីៗនេះបន្ទាប់ពីគាត់ត្រូវបានទទួលទៅសម្រាកព្យាបាលនៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ហើយគាត់នៅមានបញ្ហាសុខភាពទន់ខ្សោយនៅឡើយ។ ហេតុនេះអង្គជំនុំជម្រះទទួលយកតាមសំណើរបស់ជនជាប់ចោទមួយផ្នែក និងអនុញ្ញាតឲ្យគាត់អវត្តមានពីកិច្ចដំណើរការនីតិវិធីក្នុងអំឡុងពេលបង្ហាញឯកសារនានា ដែលពាក់ព័ន្ធនឹងជនជាប់ចោទ អៀង សារី និង នួន ជា។

ទោះបីជាយ៉ាងនេះក្ដី អង្គជំនុំជម្រះបង្គាប់ឲ្យជនជាប់ចោទ ខៀវ សំផន មានវត្តមាននៅក្នុងអំឡុងពេលបង្ហាញឯកសារនានាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តរបស់គាត់។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា ពួកគាត់នឹងបង្ហាញឯកសារសំខាន់ៗដែលដែលពាក់ព័ន្ធនឹងលោក ខៀវ សំផន នារសៀលថ្ងៃនេះ និងព្រឹកថ្ងៃស្អែក។

[០៩:២៤:១៥]

ហេតុនេះអង្គជំនុំជម្រះបង្គាប់ឲ្យជនជាប់ចោទចូលរួមសវនាការទាំងនេះ ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដែលបានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីឡើងធ្វើការបង្ហាញឯកសារភស្តុតាងជាគន្លឹះពាក់ព័ន្ធជាមួយនឹងអង្គហេតុតួនាទីរបស់ជនជាប់ចោទ។

សូមអញ្ជើញលោកមេធាវី! លោកមេធាវីការពារក្តីឲ្យលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ មុននឹងតំណាងសហព្រះរាជអាជ្ញាបង្ហាញនៅចំពោះឯកសារគន្លឹះទាក់ទងទៅនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទនៅពេលនេះ។ ខ្ញុំសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាបញ្ជូនមកខាងភាគីពាក់ព័ន្ធទាំងអស់ នូវបញ្ជីឯកសារដែលលោកនឹងបង្ហាញ។ ព្រោះថាឯកសារវាមានច្រើន ដល់អ៊ីចឹងការសិក្សារបស់យើងវាមិនអាចបានជិតដល់ទាំងអស់ទេ។ ដូច្នេះសូមឲ្យបញ្ជូនឯកសារបញ្ជីឯកសារហ្នឹងមុនមក ដើម្បីយើងអាចពិនិត្យតាមដានមានប្រសិទ្ធភាពល្អ។ បាទ សូមអរគុណ។

[០៩:២៥:៤០]

**ប្រធានអង្គជំនុំ៖**

ម៉េចទៅតំណាងសហព្រះរាជអាជ្ញា?

**លោក វីណ្ស្មៀម ស្មីត៖**

សូមជម្រាបសួរលោកប្រធាន សូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ លោកប្រធានយើងរីករាយនឹងផ្តល់ឯកសារនេះទៅខាងមេធាវីការពារក្តី។ ប៉ុន្តែដោយសារតែមានពេលវេលាតិចក្នុងការរៀបចំកាលវិភាគ ក្នុងការអនុញ្ញាតឲ្យយើងរៀបចំនូវឯកសារ ដូច្នេះដោយសារតែមានការយឺតយ៉ាវទើបយើងមានការលំបាកនៅក្នុងការរៀបចំឯកសារណាដែលល្អ ហើយយើងនឹងផ្តល់ជូនទៅភាគីនានាឆាប់បំផុតតាមដែលអាចធ្វើទៅបាន។ តើភាគីនានាចង់បានបញ្ជីនៃឯកសារ បើបែបនេះមែនដែរឬទេ?

**ប្រធានអង្គជំនុំ៖**

បាទជាការពិតហើយ សំណើសុំរបស់ភាគីអំមិញ គឺច្បាស់លាស់ហើយ គឺបញ្ជីនៃឯកសារដែលខាងតំណាងសហព្រះរាជអាជ្ញា មានបំណងលើកយកមកបង្ហាញចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។

សង្ឃឹមថាលោកមេធាវីអាចទទួលយកបានហើយ ព្រោះគាត់នឹងប្រឹងប្រែងរៀបឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។

សូមអញ្ជើញលោកមេធាវីជាតិការពារក្តីលោក អៀង សារី!

[០៩:២៦:៥៨]

**លោក អាង ឧត្តមៈ**

សូមគោរពតុលាការ! សួស្តីភាគី សូមក្រាបថ្វាយបង្គំព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ លោកអ្នកទាំងឡាយ ដែលបានចូលរួមសវនាការនេះ។ ពីម្សិលមិញព្រះរាជអាជ្ញាបានអះអាងថា បានត្រៀមខ្លួនរួចហើយក្នុងការបង្ហាញឯកសារទាំងអស់នេះ។ ខ្ញុំក៏រង់ចាំមើលបញ្ជីឯកសារហ្នឹងដែរ រហូតមកពេលនេះ។ អ៊ីចឹងការអះអាងដែលថា ត្រៀមខ្លួនរួចហើយគឺដូចជាមិនពិត។ ហើយទើបឮសួរអំមិញថា បានប្រឹងប្រែងឲ្យអស់លទ្ធភាពក្នុងការត្រៀមឯកសារ។ តាមពិតព្រះរាជអាជ្ញាក្នុងករណីដែលគាត់មិនទាន់បានត្រៀមឯកសាររួចរាល់ គួរតែជម្រាបតុលាការឲ្យត្រូវនឹងស្ថានភាពដែលថាមិនទាន់រួចហើយ។ ពីព្រោះយើងភាគី យើងក៏ត្រូវដឹងឯកសារទាំងអស់មុននឹងលើកយកមក -- សូមលើកយកមកបង្ហាញដែរ។ ក្នុងករណីដែលយើងមើលឯកសារភ្លាមៗ បន្ទាន់ៗនៅពេលនេះ យើងមិនអាចធ្វើការកត់សម្គាល់អីបានទាន់ភ្លាមទេ ពីព្រោះឯកសារមួយចំនួនក៏យើងត្រូវការពិភាក្សាជាមួយកូនក្តីយើង ហើយយើងត្រូវពិភាក្សាមុនដែរ។ អ៊ីចឹងខ្ញុំសូមសោកស្តាយដែរ ដែលថាក្នុងករណីដែលព្រះរាជអាជ្ញាមិនទាន់បានត្រៀមខ្លួនចប់សព្វគ្រប់នៅឡើយ ហើយក៏រូតរះបង្ហាញឯកសារដោយភាគីខាងយើងខ្ញុំអត់បានដឹងមុន។ ជាគួរឲ្យការសោកស្តាយ ប្រហែលជាយើងខ្ញុំមានការពិបាកក្នុងការធ្វើការជំទាស់ ឬការកត់សម្គាល់។ សូមអរគុណ។

[០៩:២៨:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣០:០៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនលោកស្រីចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីជាតិការពារក្តីលោក អៀង សារី។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះមិនបានធ្វើឱ្យលើសការជំទាស់របស់មេធាវី អៀង សារី និងខៀវ សំផន នោះទេ។ ខាងព្រះរាជអាជ្ញាបានបញ្ជាក់រួចទៅហើយថា ខាងព្រះរាជអាជ្ញាបានធ្វើឱ្យអស់ពីលទ្ធភាព។ ហើយខាងព្រះរាជអាជ្ញាបានជម្រាបមកខាងអង្គជំនុំជម្រះរួចទៅហើយ ដោយគាត់បញ្ជាក់ថាខ្លួនបានរៀបចំរួចរាល់តែទៅលើឯកសារទាក់ទងទៅលោក អៀង សារី ប៉ុណ្ណោះ។

អង្គជំនុំជម្រះបានពិចារណារួចហើយថា វាមិនមែនជាត្រឹមត្រូវនោះទេ ដែលយើងធ្វើការរិះគន់ទៅក្រុមព្រះរាជអាជ្ញាដូចដែលបានធ្វើមកនេះ ទាក់ទងទៅនឹងការរៀបចំឯកសារ ដោយសារតែខាងព្រះរាជអាជ្ញាមានសមត្ថភាពមានកម្រិត ហើយការជូនដំណឹងហ្នឹងក៏មានរយៈពេលខ្លីដែរ។ ហើយទី២ គឺសំណុំឯកសារទាំងអស់នៅក្នុងសំណុំរឿងរួចទៅហើយ ដូច្នេះ ភាគីនានាអាចតាមដានដោយសមហេតុផល ហើយបានឆាប់រហ័សទៅលើអ្វីដែលព្រះរាជអាជ្ញាបានធ្វើ។ ដូច្នេះការជំទាស់ គឺមិនមានប្រសិទ្ធភាពនោះឡើយ។ សូមអរគុណ។

[០៩:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

បញ្ហាដដែលៗ អង្គជំនុំជម្រះមិនឱ្យលោកលើកឡើងទៀតទេ។ អង្គជំនុំជម្រះបានសម្រេចរួចហើយ បើមានបញ្ហាថ្មីលោកអាចលើកបាន។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែសុំកែតម្រូវខ្ញុំខ្លួនឯងទេ ពីព្រោះខ្ញុំអំមិញ ខ្ញុំនិយាយថា ខ្ញុំមិនជំទាស់ទេ។ ខ្ញុំមិននិយាយថា ខ្ញុំជំទាស់ទៅនឹងឯកសារ ខ្ញុំគ្រាន់តែជាការកត់សម្គាល់របស់ខ្ញុំ ជាការព្រួយបារម្ភរបស់ខ្ញុំទេ មិនមែនខ្ញុំជំទាស់នឹងការបង្ហាញឯកសារទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៣២:១៩]

**លោក ច័ន្ទ តារាស្មី៖**

បាទ ខ្ញុំសូមគោរពលោកប្រធាន! សូមគោរពលោក លោកស្រីចៅក្រម! សូមគោរពអង្គ

សវនាការទាំងមូល! និងសូមគោរពអស់លោក លោកស្រីដែលសាធារណជនដែលបានចូលរួមសវនាការនៅថ្ងៃនេះ។

ក្នុងនាមតំណាងឲ្យសហព្រះរាជអាជ្ញានៅថ្ងៃនេះ ខ្ញុំសូមបង្ហាញជូននូវភស្តុតាងជាឯកសារដ៏សំខាន់ដែលទាក់ទិនទៅនឹងតួនាទី និងភារកិច្ចរបស់លោក អៀង សារី ដែលគាត់បានធ្វើនៅក្នុងសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជានៅក្នុងសម័យកាលបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារទាំងអស់នេះពិតជាមានសារៈសំខាន់ ហើយខ្ញុំសូមបង្ហាញជូនយ៉ាងសង្ខេបដូចតទៅៈ

តំណាងសហព្រះរាជអាជ្ញានឹងប្រើប្រាស់ពេលវេលានៅក្នុងសវនាការនៅពេលនេះ ដើម្បីបង្ហាញជូននូវឯកសារចំនួន២៩ ជាឯកសារ និងប្រាំបីខ្សែវីដេអូ ដែលជាភស្តុតាងបង្ហាញយ៉ាងច្បាស់ជូនអង្គសវនាការអំពីអ្វីដែលជាសកម្មភាពរបស់លោក អៀង សារី បានធ្វើនៅក្នុងពេលអតីតកាលនៅពេលដែលគាត់បានកាន់អំណាច។ ឯកសារទាំងអស់នោះនឹងជួយបង្ហាញឲ្យសាធារណជន ក៏ដូចអង្គសវនាការបានយល់ជ្រួតជ្រាបច្បាស់អំពីប្រភពនៃឯកសារ ដែលជាភស្តុតាងជាប់ពាក់ព័នទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលជាអង្គហេតុដែលអង្គសវនាការនៅសាលាក្តីខ្មែរក្រហមនេះ បានចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយដែលលោកអៀង សារី បានប្រព្រឹត្ត។

[០៩:៣៣:៥០]

ឯកសារទាំងអស់នេះនឹងត្រូវដាក់បង្ហាញផងដែរ ជាលំដាប់លំដោយដែលប្រើប្រាស់ពេលវេលាប្រមាណជា២ទៅ៣ថ្ងៃ ដើម្បីជូនអង្គសវនាការជ្រាប។ ឯកសារ ឬក៏វីដេអូដែលនឹងបង្ហាញជូននៅពេលនេះ គឺជាឯកសារដ៏សំខាន់ ជាឯកសារដ៏គន្លឹះដែលចង្អុលបង្ហាញអំពីសម្តី សកម្មភាព ឬក៏ព្រឹត្តិការណ៍ទាំងឡាយដែលលោក អៀង សារី បានធ្វើ។ យើងក៏មកពិភាក្សាផងដែរអំពីកំណត់ហេតុនៃកិច្ចប្រជុំសារទូរលេខផ្សេងៗ ដែលជាឧទាហរណ៍ ហើយយើងនឹងយកបង្ហាញផងដែរ អំពីការចងក្រង ការប្រមូលឯកសារទាំងអស់នោះដាក់ជាសំណុំឯកសារតាមលំដាប់លំដោយ។ ឯកសារទាំងអស់នេះត្រូវបានរៀបចំរួចជាស្រេចតាមលំដាប់លំដោយ ដើម្បីជួយក្នុងពន្យល់ពីរបៀបដែលប្រភេទឯកសារទាំងអស់នេះបង្ហាញយ៉ាងច្បាស់អំពីអង្គហេតុពិត និងអំពីអ្វីៗដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យៗ គឺរាប់ទាំងមុនពេលនៃការកកើតព្រឹត្តិការណ៍ដែលលោក អៀង សារី បានប្រព្រឹត្ត បានធ្វើសកម្មភាពនៅក្នុងអំពើរបស់គាត់។

អង្គជំនុំជម្រះជាទីគោរព! ក្នុងការបំភ្លឺឯកសារចំនួនរាប់ពាន់ ក្នុងការបង្ហាញពីភស្តុតាងក្នុងការ

កាត់សេចក្ដីនោះ យើងបានជ្រើសរើសយកតែពីរ ឬបីប៉ុណ្ណោះដែលឯកសារទាំងនេះគឺលោក វីល្លៀម ស្មីត នឹងបង្ហាញជូននៅពេលបន្តិចទៀត។ ឯកសារដែលយើងនឹងបង្ហាញជូននេះ គឺជាឯកសារដែលមានតម្លៃ។ ឯកសារជាលាយលក្ខណ៍អក្សរ ហើយនិងឯកសារដែលបានធ្វើនៅក្នុងកំណត់ហេតុដេញដោលដោយផ្ទាល់មាត់ផងដែរ។

[០៩:៣៦:០០]

ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានយកឯកសារ ដែលជាទស្សនៈនៃការយល់ឃើញរបស់អ្នកជំនាញ ឬក៏ចម្លើយសាក្សីយកមកបង្ហាញជូននៅពេលនេះទេ។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន និងអង្គជំនុំជម្រះឲ្យលោក វីល្លៀម ស្មីត បង្ហាញជូនអំពីឯកសារទាំងអស់នេះ និងវីដេអូដែលគាត់នឹងបង្ហាញជូននៅពេលបន្តិចទៀតនេះជូនអង្គសវនាការដើម្បីជ្រាបច្បាស់។ សូមអនុញ្ញាតពីលោកប្រធានដើម្បីឲ្យលោក វីល្លៀម ស្មីត មានឱកាសក្នុងការបង្ហាញជូន។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព!

ដូចដែលសហសេវិកជាតិបានបញ្ជាក់ មានឯកសារ៤ប្រភេទ៖

ប្រភេទទី១ ឯកសារពាក់ព័ន្ធទៅនឹងការទំនាក់ទំនងរបស់ អៀង សារី ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងនាមជាសមាជិកសាមញ្ញ។ ទី២ យើងបង្ហាញឯកសារពាក់ព័ន្ធទៅនឹងអៀង សារី ក្នុងតួនាទីរបស់គាត់នៅក្នុងសមាជិកគណៈអចិន្ត្រៃយ៍ និងទី៣ ឯកសារទី៣ គឺយើងខ្ញុំបង្ហាញពាក់ព័ន្ធទៅនឹងតួនាទីនៅក្នុងក្រសួងការបរទេស និងឯកសារប្រភេទចុងក្រោយជាក្រុមឯកសារកិច្ចសម្ភាសន៍ជាមួយនឹងជនជាប់ចោទស្ដីអំពីតួនាទីរបស់គាត់ភ្លាមៗ ក្រោយ និងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយរបបនោះ។

[០៩:៣៧:៤៤]

ខ្ញុំសូមចាប់ផ្ដើមប្រភេទឯកសារទី១ ជាការពិតទៅគឺអង្គហេតុឯកភាពមួយចំនួននោះ បានឯកភាពដោយ អៀង សារី នៅពេលចាប់ផ្ដើមសវនាការនេះ ដើម្បីឲ្យយើងយល់អំពីតួនាទីរបស់គាត់ក្នុងអំឡុងពេលនោះ អង្គហេតុពាក់ព័ន្ធទៅនឹងសកម្មភាពរបស់គាត់មុនឆ្នាំ៧៥ វាមានសារៈសំខាន់ដែលយើងត្រូវ

យល់អំពី -- ត្រូវស្វែងយល់អំពីឯកសារទាំងអស់នោះ ថាតើគាត់មានទំនាក់ទំនងយ៉ាងម៉េចជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា។

លោក លោកស្រីចៅក្រមជាទីគោរព! ប្រសិនបើខ្ញុំសូមឲ្យមើលឯកសារ E9/21.3 ឧបសម្ព័ន្ធ១ E00656904 ទៅដល់ 81។ នេះគឺជាឯកសារថតចម្លងនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះហើយបានបញ្ជូនទៅក្រុមមេធាវីការពារក្តី អៀង សារី។ នៅក្នុងនោះ គេបានគូសបញ្ជាក់អំពីតួនាទីរបស់គាត់មុនឆ្នាំ៧៥ ហើយលោក អៀង -- ក្រុមលោក អៀង សារី ហើយនិងលោក អៀង សារី បានឯកភាពទៅលើអង្គហេតុនេះ។ នៅក្នុងនេះគឺមានអត្ថាធិប្បាយមួយចំនួនដែលបានបង្ហាញទៅលើចំណុចដែលបានដកស្រង់នេះ។ ប្រសិនបើយើងមើលកថាខណ្ឌ៩៩៥ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ លោក អៀង សារី បានឯកភាពថា “នៅក្នុងឆ្នាំ១៩៥០ គាត់បានធ្វើដំណើរទៅប៉ារីស ធ្វើការសិក្សារៀនសូត្រ”។ ហើយគាត់បានបញ្ជាក់ថា “នៅឆ្នាំ១៩៥៨ គាត់ត្រឡប់មកទីក្រុងភ្នំពេញវិញ”។ គាត់ក៏បានលើកឡើងថា “គាត់គឺជាសាស្ត្រាចារ្យមួយរូបនៅកម្ពុជាបុត្រ វិទ្យាល័យកម្ពុជាបុត្រ ហើយគាត់បានរត់ទៅលាក់ខ្លួននៅក្នុងឆ្នាំ១៩៦០ ហើយគាត់ក៏បានធ្វើការងារនៅជាសមាជិកសន្និបាតបក្សផងដែរ។ គាត់ជាសមាជិករបស់គណៈមជ្ឈិម ហើយគាត់ក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍នាពេលនោះផងដែរ។ គាត់ឯកភាពថា នៅខែមេសា ឆ្នាំ៦៣ ក្រោយពេលតែងតាំងដោយសម្តេច សីហនុ គឺគាត់បានរត់ទៅព្រំដែនវៀតណាម ហើយក្រោយមក អ៊ំ! នៅពេលនោះគាត់រត់ជាមួយនឹង សុន សេន ហើយបានចូលរួមជាមួយនឹងក្រុម ប៉ុល ពត។ គាត់បានឯកភាពថា នៅក្នុងឆ្នាំ៦៦ គាត់និងសមាជិកផ្សេងទៀតបានធ្វើការផ្លាស់ប្តូរទៅភូមិភាគឦសាន គឺក្នុងខេត្តរតនគិរី ហើយគាត់ក្រោយមកក្លាយទៅជាលេខាឦសាន។ ហើយក្រោយមកគាត់បានត្រឡប់មកធ្វើការនៅក្នុងស្ថានីយវិទ្យុខ្មែរក្រហម ក្រោយមក អៀង ធីរិទ្ធ ជាអ្នកកាន់កាប់ចាប់ពីឆ្នាំ៧១ គឺគាត់បានទទួលកន្លែងស្នាក់នៅអចិន្ត្រៃយ៍នៅប៉េកាំង។

[០៩:៤១:០៧]

គាត់បានក្លាយទៅជាបេសកជននៅក្នុងទីក្រុងប៉េកាំង ហើយបានទទួលតួនាទីធ្វើទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ។ គាត់បានឯកភាពថា ក្នុងអំឡុងពេលនោះគាត់បានត្រឡប់មកប្រទេសកម្ពុជាពីរដង។ម្តងគឺនៅក្នុងឆ្នាំ៧៣ នៅពេលដែលគាត់អមដំណើរជាមួយសម្តេច សីហនុ មកតំបន់រំដោះ ហើយគាត់មកម្តងទៀតនៅក្នុងឆ្នាំ៧៤។ គាត់បានត្រឡប់មកប្រទេសកម្ពុជាអចិន្ត្រៃយ៍នៅក្នុងខែមេសា ឆ្នាំ៧៥។ នេះគឺកថាខណ្ឌ ៩៩៩ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ គាត់បានឯកភាពថានៅក្នុងរបប

កម្ពុជាប្រជាធិបតេយ្យគាត់បានប្រើឈ្មោះរហស្សនាមថា វ៉ាន់។

[០៩:៤១:៥៣]

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេលនេះគឺខ្ញុំសូមឲ្យបង្ហាញនូវខ្សែវីដេអូមួយ គឺឯកសារ E234R។ ខ្សែវីដេអូនេះបានបង្ហាញរាយការណ៍អំពីកិច្ចប្រជុំរបស់សម្តេចនរោត្តម សីហនុ ជាមួយនឹង អៀង សារី ជាមួយនឹងមេដឹកនាំផ្សេងទៀតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជារួមទាំង ប៉ុល ពត, ខៀវ សំផន, ហ៊ូ នឹម នៅក្នុងតំបន់រំដោះ ហើយក្នុងនោះក៏មានការទៅទស្សនកិច្ចនៅអង្គរវត្តនៅក្នុងខែមីនា ឆ្នាំ១៩៧៣ ដែលលោក អៀង សារី បានទទួលស្គាល់អង្គហេតុនេះ។ នៅពេលដែលចាក់ខ្សែវីដេអូនោះ គឺលោក ប៉ុល ពត បានរៀបរាប់ថាតើគាត់ក្លាយទៅជាមេដឹកនាំបក្សដោយរបៀបណា។ ខ្សែវីដេអូនេះគឺមានរយៈពេល១:៣៥ នាទី។ ហើយដូច្នេះខ្ញុំសូមអនុញ្ញាតឲ្យចាក់ខ្សែវីដេអូនេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! អ្នកសោតទស្សន៍ដាក់បង្ហាញឯកសារវីដេអូនៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[០៩:៤៣:១៧]

*(ការបង្ហាញឯកសារវីដេអូ)*

*"គឺថាពីក្មេងមកជាចរិតរបស់ខ្ញុំអ៊ីចឹង។ គឺថាមិនសូវនិយាយស្តីអីទេ ហើយខ្ញុំមិននិយាយសៀវភៅ ម្នាក់ទៀតដែលសម្កាស ហ្សាក់ វ៉ែកហ្សេស គឺថា វ៉ែកហ្សេស ថា ធ្លាប់ស្គាល់ខ្ញុំ២០-៣០ឆ្នាំមុនជាយុវជនមួយ អូនលី ឌីសក្រេ និងអីទៀត។ ខ្ញុំមិនចង់បញ្ចេញថា ខ្ញុំអ្នកដឹកនាំស្អីទេ។ ហើយគេសួរខ្ញុំ (ឮមិនច្បាស់) សួរខ្ញុំថា ប្រវត្តិខ្ញុំយ៉ាងម៉េច? ប្រវត្តិខ្ញុំវាមាន ១) គឺថា ខ្ញុំខំ ចេះតែខំធ្វើការទៅ, ទី២ វាជាថៃដន្យ វាជាអាហ្សា។ ដូចជាធ្វើជាលេខាបក្ស វាគ្មានអ្នកណាធ្វើ បានគេចេះឲ្យខ្ញុំធ្វើ ខ្ញុំថាមិនធ្វើទេ គេឲ្យធ្វើ"។*

*(បញ្ចប់ការបង្ហាញឯកសារវីដេអូ)*

[០៩:៤៥:១៤]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ នៅក្នុងខ្សែវីដេអូនេះ យើងឃើញលោក អៀង សារី ជាមួយនឹងមេដឹកនាំផ្សេងទៀតរួមគ្នា។ យើងនិយាយអំពីអង្គហេតុឯកភាពដោយលោក អៀង សារី

ក្នុងកថាខណ្ឌ៣៣ គាត់ឯកភាពថា គិតខែ -- ត្រឹមខែមេសា ឆ្នាំ៧៥ បក្សនេះត្រូវបានដឹកនាំដោយលក្ខន្តិកៈ ហើយបានរៀបចំសន្និបាតលើកទី១នៅក្នុងខែកញ្ញា ឆ្នាំ៦០។ កថាខណ្ឌ២០ គាត់ឯកភាពថាសន្និបាតឆ្នាំ៦០ នៅពេលនោះគណបក្សប្រជាជនបដិវត្តន៍កម្ពុជាក្លាយជាបក្សពលករកម្ពុជា ហើយក៏បានក្លាយជាបក្សកុម្មុយនីស្ត។ គាត់បានភាពត្រង់កថាខណ្ឌ៣៥ សមាជិកគណៈអចិន្ត្រៃយ៍នោះ មានរួមទាំងសមាជិកពេញសិទ្ធិ សមាជិកបម្រុង ហើយគាត់ឯកភាពថា សមាជិកបម្រុងគឺអាចចូលរួមប្រជុំបានក៏ប៉ុន្តែមិនមានសិទ្ធិធ្វើសេចក្តីសម្រេច។

[០៩:៤៦:២៦]

កថាខណ្ឌ៤២ គាត់ឯកភាពថា ប៉ុល ពត មានអំណាចខ្ពស់ជាងគេនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាជាលេខាគណអចិន្ត្រៃយ៍ គាត់ឯកភាពថាការនិយាយជាមួយនឹង ប៉ុល ពត ស្មើនឹងនិយាយជាមួយនឹងបក្ស។ កថាខណ្ឌ៤៣ គាត់ឯកភាពថា នួន ជា គឺជា -- មានឋានៈទី២នៅក្នុងរចនាសម្ព័ន្ធគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយ តាម៉ុក មានលេខរៀងបន្ទាប់។ គាត់បានឯកភាពថា នៅពេលដែលអនុវត្តមានប៉ុល ពត នួន ជា ធ្វើជាអធិបតីកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ កថាខណ្ឌ២២ គាត់ឯកភាពថា ក្រោយបាត់ខ្លួនឆ្នាំ៦២ គឺក្រោយបាត់ខ្លួនលេខាបក្សពលករ ទូ សាមុត គឺ នៅពេលនោះគឺថាសន្និបាតបក្សលើកទី២ ត្រូវបានប្រជុំនៅក្នុងខែ ចុងខែកុម្ភៈ ឆ្នាំ៦៣ សាឡុត ស ក្លាយជាលេខាថ្មី ហើយ នួន ជា ក្លាយជាអនុលេខា។ សន្និបាតរៀបចំឡើងនៅក្នុងទីក្រុងភ្នំពេញ អ្នកចូលរួមគឺជាក្រុមតូចមួយដែលក្នុងនោះរួមទាំងអៀង សារី, សោ ភឹម អ្នកទាំងពីរនោះត្រូវបានគេបោះឆ្នោតឲ្យក្លាយជាសមាជិកពេញសិទ្ធិនៃគណៈអចិន្ត្រៃយ៍ តាម៉ុក, វន វ៉េត, សុន សេន, រស់ ញឹម ប៉ុន្មានខែក្រោយមក ក្រោយពីរដ្ឋាភិបាលបោះពុម្ពផ្សាយបញ្ជីជនឆ្វេងនិយម៣៤នាក់ ប៉ុល ពត និង មេដឹកនាំបក្សដទៃទៀត រួមមាន អៀង សារី, សុន សេន បានរត់គេចចេញពីទីក្រុងភ្នំពេញ។ ពួកគេបានទៅលាក់ខ្លួននៅមូលដ្ឋានវៀតណាមតាមព្រំដែនដែលនៅទីនោះបានបង្កើតការិយាល័យ -- មន្ទីរមួយហៅថាមន្ទីរ១០០។ គាត់ឯកភាពថា នៅត្រឹមឆ្នាំ៦៥ គាត់ត្រូវបាន ខៀវ ប៉ុណ្ណារី ចូលរួមជាមួយ។ អៀង ធីរិទ្ធ និង យុន យ៉ាត ក៏ចូលរួមជាមួយ។ នួន ជា ឈ្មោះនៅតែសម្ងាត់ដដែល ហើយមិនស្ថិតនៅក្នុងបញ្ជីដែលមាន៣៤នាក់នោះទេ។ ហើយ នួន ជា ស្នាក់នៅទីក្រុងភ្នំពេញ ហើយទទួលតួនាទីដឹកនាំប្រតិបត្តិការបក្សនៅទីក្រុងភ្នំពេញ។

[០៩:៤៨:៣៩]

នៅក្នុងកថាខណ្ឌ២៣ នៅក្នុងឆ្នាំ១៩៦៧ លេខាបក្សបានឯកភាពធ្វើការបះបោរទូទៅក្នុងឆ្នាំ៦៨។

គាត់ឯកភាពថា ទីស្នាក់ការកណ្តាលនៃគណៈមជ្ឈិម គឺហៅថាមន្ទីរ១០០ ហើយត្រូវបានប្តូរទីតាំងទៅខេត្តរតនគិរី គឺមានចម្ងាយប្រហែលជាប៉ុន្មានគីឡូម៉ែត្រពីមន្ទីរ១០២ នៅខាងព្លសាន តំបន់ភាគព្លសានមន្ទីរ នៅមន្ទីរភូមិភាគព្លសានមួយដែលប្រើឈ្មោះដោយ អៀង សារី។ ដូច្នេះហើយ នៅក្នុងនេះ ដូចដែលលោក លោកស្រីចៅក្រមបានបញ្ជាក់ថា អាសញ្ញាពណ៍លឿងនេះ គឺខាងក្រុមលោក អៀង សារី នោះមិនឯកភាព។ កថាខណ្ឌ២៥ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ៧០ គាត់ឯកភាពថា សម្តេច នរោត្តម សីហនុ ត្រូវបាន១ដកហូតតំណែងដោយឧត្តមសេនី លន់ នល់ និងសម្តេច និងព្រះអង្គ សិរិមតៈ។ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ៧០ សម្តេច សីហនុ បានប្រកាសបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ ហើយប្រកាសឲ្យ១ជនស្នេហាជាតិទាំងអស់នោះបះបោរប្រឆាំងនឹងរដ្ឋាភិបាលថ្មីនេះ។

កថាខណ្ឌ២៧ គាត់បានឯកភាពថាគាត់បានទៅហាណូយ នៅដើមឆ្នាំ៧១ (ស៊ីក) ហើយគឺបានបង្កើតវិទ្យុមួយ។ ក្រោយមកនៅក្នុងខែមេសា ឆ្នាំ៧១ គាត់បានធ្វើដំណើរទៅប៉េកាំង ធ្វើការងារជាបេសកជនពិសេសនៃចលនាតស៊ូបះបោរ។ នៅក្នុងទីក្រុងប៉េកាំង លោក អៀង សារី មានទំនងទំនងតេឡេក្រាមដោយផ្ទាល់ជាមួយនឹងខាង ស-៧១។

[០៩:៥០:៤៥]

អត្ថិភាពនៃបក្សកុម្មុយនីស្តកម្ពុជាមិនត្រូវបានប្រកាសទេ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៧ ដែលគាត់ឯកភាពនៅក្នុងកថាខណ្ឌ១៨។ នេះជាអង្គហេតុដែលទទួលការឯកភាពពាក់ព័ន្ធទៅនឹងតួនាទីរបស់អៀង សារី មុនឆ្នាំ១៩៧៥។ ហើយខ្ញុំគិតថា ជាពិសេសនោះវាពាក់ព័ន្ធដោយយើងអាចយល់អំពីតួនាទីអ្វីដែលលោក អៀង សារី កាន់កាប់នៅពេលដែលបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមកាន់កាប់អំណាច ហើយឲ្យយើងយល់អំពីវិសាលភាពតួនាទីរបស់គាត់ផងដែរ។

លោក លោកស្រីចៅក្រមជាទីគោរព! ឯកសារបន្ទាប់មួយទៀតដែលខ្ញុំសូមលើកឡើងគឺ E3/214 នេះគឺជាលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ឆ្នាំ១៩៧៦។ លោក លោកស្រីចៅក្រមដឹងស្តាប់រួចមកហើយថា លក្ខន្តិកៈគឺមានតាំងពី៦០ ហើយបន្ទាប់មកមានការធ្វើវិសោធនកម្ម ក៏ប៉ុន្តែយើងត្រូវចងចាំថា លក្ខន្តិកៈដើមនោះគឺថាវាមានទម្រង់មួយដែលវាចាស់បន្តិច។ ដូច្នេះយើងនឹងលើកយកមកពិភាក្សានៅពេលនេះ។

[០៩:៥២:០៩]

ឯកសារនេះគឺមានតម្លៃជាភស្តុតាងបង្ហាញអំពីមុខងារ និងសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា។ លក្ខន្តិកៈនិយាយអំពីរចនាសម្ព័ន្ធ តួនាទីការទទួលខុសត្រូវរបស់បក្ស គោលការណ៍នៃការរៀបចំសិទ្ធិ

កាតព្វកិច្ចរបស់សមាជិកបក្ស វិន័យរបស់សមាជិកបក្ស លក្ខណៈវិនិច្ឆ័យសម្រាប់បុគ្គលចូលជាសមាជិក និងចំណុចផ្សេងទៀត។ ដូច្នេះឯកសារនេះឲ្យយើងយល់អំពីតួនាទីរបស់ អៀង សារី ក្នុងកម្ពុជាប្រជាធិបតេយ្យ។ មានបទប្បញ្ញត្តិមួយចំនួនដែលវាមានការពាក់ព័ន្ធគ្នា។

ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមមើល ERN 00184024, ខ្មែរ 0052390 (ស៊ីក) គឺនេះគឺជាលក្ខន្តិកៈដែលក្នុងនេះថែងអំពីគោលជំហរនយោបាយ និងបញ្ហាលាក់ការណ៍ ជាពិសេសនៅក្នុងរយៈកាលថ្មីនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម។ ប្រសិនបើយើងមើលចុះក្រោមបន្តិចទំព័រទី២ ត្រង់ផ្នែកដែលនិយាយដោយសង្ខេបអំពីគោលដៅរបស់បក្ស។ បញ្ហានៃគោលនយោបាយគឺដើម្បីទទួលនូវបដិវត្តន៍សង្គមនិយម ហើយក្រោយពេលដែលយើងសម្រេចបដិវត្តន៍នោះ គឺយើង -- កម្ពុជាគឺក្រោយសម្រេចបដិវត្តន៍ប្រជាជាតិ ប្រជាធិបតេយ្យបានទាំងស្រុងនិងជាស្ថាពរហើយ បានធ្វើបដិវត្តន៍សង្គមនិយមបានមួយជំហានធំហើយ ត្រូវបន្តធ្វើនិងសម្រេចបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅក្នុងកម្ពុជាទៀត ហើយឈានទៅកុម្មុយនីស្តនិយមនៅកម្ពុជាទៅអនាគត។ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនេះបក្សកុម្មុយនីស្តកម្ពុជាត្រូវការពារលទ្ធផលបដិវត្តន៍ និងការការពារប្រទេសឲ្យបានល្អផង ហើយដំណើរការកសាងប្រទេសឲ្យបានល្អ។

[០៩:៥៥:១៥]

បក្សបំពាក់ និងប្រកាន់យកនូវលោកទស្សនៈអធន និងជីវទស្សនៈអធន ត្រឹមត្រូវ និងរឹងមាំ និងតស៊ូដាច់ខាត នឹងលោកទស្សនៈ និងជីវៈមិនអធន ប្រឆាំងបដិវត្តន៍របស់អនុធន នាយទុក សក្តិភូមិចក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់។ តាមគោលជំហរនេះបក្សកុម្មុយនីស្តកម្ពុជាតស៊ូប្រឆាំងដាច់ខាតនឹងគំនិតនិយម ពិសោធន៍និយម គម្ពីរនិយម និងសេរីនិយម។

ដូចដែលលោក លោកស្រីចៅក្រមកត់សម្គាល់ឃើញរួចស្រាប់ហើយ លក្ខន្តិកៈនេះគឺមានលក្ខណៈរាប់រៀបស្រដៀងទៅនឹងគោលការណ៍ -- ទៅនឹងផ្នែកដែលនិយាយអំពីបញ្ហាគោលការណ៍ និងសមាជិករបស់បក្ស។ ដូច្នេះនៅពេលនេះ ខ្ញុំសូមឲ្យមើលមាត្រា២វិញម្តង។ ប៉ុន្តែមុនពេលមើលមាត្រា២ ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រម មើលកថាខណ្ឌចុងក្រោយពីរ។ កថាខណ្ឌ៦ ទំព័រ៦ និង៧ នៃភាសាខ្មែរ។ ក្នុងនេះនិយាយថា “បក្សកុម្មុយនីស្តកម្ពុជាយល់ច្បាស់នូវភារកិច្ចដ៏ធ្ងន់ធ្ងរក្រៃលែងរបស់ខ្លួន។ តែជាភារកិច្ចឧត្តុង្គឧត្តមបំផុត។ សមាជិកនៃបក្សយើងគ្រប់រូបត្រូវខិតខំកសាងពង្រឹងពង្រីកសាមគ្គីភាពឯកភាពផ្ទៃក្នុងឲ្យខ្លាំងឡើង ទាំងខាងនយោបាយ ទាំងខាងសតិអារម្មណ៍ ទាំងខាងចាត់តាំងគ្រប់កាលៈ

ទេសៈ។ ត្រូវវាយសម្រុកជាប់លត់ដំជាប់ ដុតកម្ដៅជាប់ បំផុសបំផុលជាប់ វាយជំរុញជាប់ក្នុងមហាចលនាបដិវត្តន៍ដ៏ក្ដៅគគុក និងដ៏ជ្រាលជ្រៅបំផុតរបស់មហាជនកម្មករ កសិករក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ ដើម្បីបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមបានសម្រេចផលល្អប្រពៃ និងឆាប់រហ័សបំផុត ហើយបន្តឈានទៅកុម្មុយនីស្តនិយមទៀត នៅលើកម្ពុជាជាទីស្នេហាបំផុតរបស់យើង។ តាមរយៈនោះក៏រួមវិភាគទានយ៉ាងសំខាន់ក្នុងចលនាបដិវត្តន៍ក្នុងសាកលលោក។

[០៩:៥៦:៣៤]

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេលនេះយើងមើលអំពីតួនាទីរបស់សមាជិកបក្ស គឺតួនាទីរបស់បុគ្គលដែលចូលរួមបក្ស។ គឺយើងចាប់ផ្ដើមនៅក្នុងនោះគឺថាយើងមើលឃើញអំពីលក្ខណៈទូទៅអំពីតួនាទីរបស់បក្ខជន ជាពិសេសតួនាទីរបស់លោក អៀង សារី និងជនជាប់ចោទផ្សេងទៀត។ ប្រសិនយើងមើលមាត្រា២ និយាយអំពីតួនាទីរបស់បក្ខជនក្នុងនោះចែងថា "ភារកិច្ចរបស់បក្ខជន គឺមានដូចតទៅ៖ ភារកិច្ចក្នុងមហាជន ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជិតស្និទ្ធនឹងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ត្រូវទទួលខុសត្រូវខ្ពស់ចំពោះមហាជនបម្រើមហាជនអស់ពីចិត្ត ពីថ្លើម និងគ្មានលក្ខខណ្ឌ រាបសារនឹងមហាជន ហើយខិតខំរៀនសូត្រពីមហាជន។ ខ) បំផុសបំផុលចលនាមហាជន ជាពិសេសមហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តន៍ឱ្យក្ដៅគគុក និងជាប់ជានិច្ចក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសដៅនៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម"។

បន្ទាប់មកគឺបានសរសេររៀបរាប់បន្ថែមទៀតអំពីភារកិច្ចផ្ទៃក្នុងរបស់បក្ខជន។

[០៩:៥៨:១៨]

"ក) មានជីវភាពក្នុងអង្គការសាខាបក្សមួយទៀងទាត់១ខែម្ដង។ បក្ខជនគ្រប់រូបទោះជាមានតួនាទីខ្ពស់យ៉ាងណា រហូតដល់ខ្ពស់បំផុតក៏ដោយ ក៏ត្រូវស្ថិតនៅក្នុងសាខាបក្សមួយហើយមានជីវភាពសាខាទៀងទាត់។ ខ) គោរពអង្គការវិន័យរបស់បក្សដោយគ្មានលក្ខខណ្ឌ និងដោយភ្ញាក់រឮកខ្ពស់។ គ) ខិតខំកសាងគោលជំហរនយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្សឱ្យកាន់តែជ្រួតជ្រាបកាន់តែរឹងមាំដើម្បីអនុវត្តនយោបាយសតិអារម្មណ៍ និងចាត់តាំងរបស់បក្សឱ្យកាន់តែល្អ និងកាន់តែមានប្រសិទ្ធភាពឡើងជានិច្ច។ ឃ) ខិតខំថែរក្សាពង្រឹងពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សឱ្យបានល្អជាប់ជានិច្ចដាច់ខាត។ ង) ខិតខំរក្សាការសម្ងាត់របស់បក្សដាច់ខាត ដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់

ជាប់ជានិច្ច។ ច) ខិតខំអនុវត្តរបបទិតៀន និងស្វ័យទិតៀន របបត្រួតពិនិត្យជីវទស្សនបដិវត្តន៍ ឲ្យបានត្រឹមត្រូវហ្មត់ចត់ និងសកម្ម ដើម្បីកសាងខ្លួន និងផ្ទៃក្នុងបក្សឲ្យបានជាគំរូល្អសកម្មប្រយុទ្ធជាប់ជានិច្ច។ ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ត្រូវមានគោលជំហរស្នេហាជាតិ និយមអធន និងអន្តរជាតិនិយមអធនត្រឹមត្រូវ និងរឹងប៉ឹង។ ចូរខិតខំរៀនសូត្រវប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រដើម្បីបង្កើនសមត្ថភាពបម្រើការងារការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមឲ្យកាន់តែល្អ និងកាន់តែប្រសិទ្ធភាព"។

[១០:០០:២៨]

មាត្រា៣ និយាយអំពីសិទ្ធិរបស់បក្ខជន ដែលក្នុងនោះគឺពាក់ព័ន្ធទៅនឹងតួនាទីរបស់ អៀង សារី ផងដែរ។ "បក្ខជនពេញសិទ្ធិគ្រប់រូបសុទ្ធតែមានសិទ្ធិដូតទៅ៖ ពិគ្រោះ ពិភាក្សា និងរួមមតិសម្រេចកិច្ចការទាំងអស់របស់បក្ស ដោយធ្វើទៅតាមលាក់ការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ"។

ប្រសិន យើងមើលមាត្រា៤ និយាយអំពីវិន័យរបស់បក្សគឺចែងដូចតទៅ "ដើម្បីរក្សាពង្រឹង និងពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សឲ្យបានល្អជាប់ជានិច្ច បក្សកំណត់លើគោលការណ៍គោរពវិន័យ និងអង្គការរបស់បក្សនៅក្នុងផ្ទៃក្នុងបក្សឲ្យបានហ្មត់ចត់។ វិន័យរបស់បក្សតឹងរ៉ឹងបំផុត តែឈរលើគោលការណ៍ភ្ញាក់រឭករបស់បក្ខជនម្នាក់ៗ។ បក្ខជនម្នាក់ៗទោះជាមានតួនាទីជាអ្វីក៏ដោយ ក៏ត្រូវគោរពប្រតិបត្តិតាមវិន័យរបស់បក្សដាច់ខាត។ គោរពវិន័យ និងគោរពអង្គការរបស់បក្សនេះ គឺគោរពមាគ៌ានយោបាយរបស់បក្ស គោលជំហរសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និងលក្ខន្តិកៈរបស់បក្ស។ បក្ខជនពីរ បក្ខជនណា ឬថ្នាក់បក្សណាដែលប្រឆាំងមាគ៌ានយោបាយរបស់បក្ស គោលជំហរសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និងលក្ខន្តិកៈរបស់បក្ស ធ្វើឲ្យប្រេះឆា សាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្ស បង្កជាបក្ខពួកធ្វើសកម្មភាពបំផ្លិចបំផ្លាញបក្ស បដិវត្តន៍ និងប្រជាជន បោះចោលភារកិច្ចរបស់បក្ខជន ធ្វើឲ្យបែកការណ៍សម្ងាត់ នាំឲ្យអន្តរាយដល់បក្ស បដិវត្តន៍ និងប្រជាជន បំបាត់ថវិកា និងទ្រព្យសម្បត្តិរបស់បក្ស ប្រព្រឹត្តសីលធម៌ ពាលាអាវ៉ាសែ មិនប្រជុំជីវភាពសាខា៣ខែជាប់ ។ល។ សុទ្ធតែល្មើសវិន័យ អង្គការរបស់បក្ស ហើយត្រូវទទួលវិន័យស្រាល ឬធ្ងន់ដូចតទៅ៖ ក) ទិតៀនព្រមាន។ ខ) ផ្លាស់ប្តូរភារកិច្ច ដកភារកិច្ច។ គ) បដិសេធចេញពីបក្ស ផ្តន្ទាទោសផ្សេងៗតាមបទល្មើសរបស់ខ្លួនជាសកម្មភាពប្រឆាំងនឹងបក្ស ជាខ្សែសង្វាក់ ឬធ្វើសកម្មភាពក្បត់បក្ស ត្រូវអនុវត្តវិន័យរបស់

បក្សនេះដោយពិនិត្យ វិភាគ វិនិច្ឆ័យហ្មត់ចត់ ឈរលើលាក់ការណ៍សម្ងាត់សមូហភាពដាច់ខាត"។

[១០:០៣:២០]

ដើម្បីយល់បន្ថែមអំពីតួនាទីរបស់លោក អៀង សារី និងជនជាប់ចោទផ្សេងទៀតនោះ យើងមើលមាត្រា៧ ជាពិសេសពាក់ព័ន្ធទៅនឹងលោក អៀង សារី។ ក្នុងនោះនិយាយអំពីរចនាសម្ព័ន្ធរបស់បក្ស និងរបៀបដែលគេរៀបចំបក្ស។

ខ្ញុំសូមអានផ្នែកទី១ គឺចែងដូចតទៅ មាត្រា៧ ខ្សែចាត់តាំងរបស់បក្សមានដូចតទៅ--

**អ្នកបកប្រែ៖**

លោកប្រធានអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាគាត់ជួយបន្តនូវការអានឯកសារ។

**លោក វិល្លៀម ស្មីត៖**

នៅក្នុងរយៈពេលពីមហាសន្និបាតមួយទៅមួយទៀត មានអង្គការប្រតិបត្តិខ្ពស់ជាងគេបំផុត។ ខ្ញុំសូមអាននូវផ្នែកខាងក្រោមបន្តិច ហើយយើងឃើញទាក់ទងទៅនឹងរចនាសម្ព័ន្ធរបស់បក្ស គឺរចនាសម្ព័ន្ធដែលនិយាយអំពីខ្សែចាត់តាំងគឺគណៈមជ្ឈិមដែលមាន -- ដែលជាស្ថាប័នមានអំណាចខ្ពស់ជាងគេបំផុតនៅក្នុងប្រទេស។ បន្ទាប់មកទៀត យើងសូមនិយាយអំពីតួនាទីរបស់គណៈមជ្ឈិមដែលនៅក្នុងគណៈមជ្ឈិមហ្នឹងលោក អៀង សារី បានទទួលស្គាល់ថាគាត់គឺជាសមាជិកនៃគណៈមជ្ឈិមនិងគណៈអចិន្ត្រៃយ៍ ដែលយើងនឹងនិយាយនៅពេលក្រោយ។

មាត្រា២៣ បានរៀបចំ -- បាននិយាយអំពីតួនាទីរបស់បក្សដែលនិយាយអំពីតួនាទីរបស់លោក អៀង សារី។ "*ភារកិច្ចរបស់គណៈមជ្ឈិម -- ភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម* គឺ ១) អនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល។ ២) ណែនាំអង្គការភូមិភាគ តំបន់ក្រុងទាំងអស់ និងអង្គការបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំងតាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស ៣) គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិ -- ដោយក្តាប់ប្រវត្តិរូប គោលជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់ និងឲ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយសតិអារម្មណ៍និងចាត់តាំងជាប់ជានិច្ច។ តាងនាមបក្ស ក្នុងការទាក់ទងបណ្តាបក្សម៉ាក្ស-ឡេនីន ជាបងប្អូន។

[១០:០៦:២៤]

មាត្រា៩ និង១០ គឺពាក់ព័ន្ធជាពិសេសទៅនឹងលោកអៀង សារី ពាក់ព័ន្ធទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់គាត់។ មាត្រា៩ ទាក់ទងទៅនឹងសាខា ដោយនិយាយថា សហករណ៍ រោងចក្រ អង្គភាព អនុសេនាធំ យោធា ការដ្ឋានក្រសួង មន្ទីរបដិវត្តន៍នីមួយៗ អាចចាត់តាំងជាសាខារបស់បក្ស បានឲ្យតែមានបក្ខជនពីរបីនាក់ឡើងទៅ។

ខ្ញុំបន្តទៅទៀត និយាយអំពីភារកិច្ចរបស់សាខា គឺមាត្រា១០ ហើយយើងឃើញថា សាខាមានភារកិច្ចពីរយ៉ាង ដែលមានលក្ខណៈប្រហែលៗគ្នាទៅនឹងសមាជិករបស់បក្ស ពាក់ព័ន្ធទៅនឹងការផ្សព្វផ្សាយទៅដល់មហាជន ក៏ដូចជាភារកិច្ចផ្ទៃក្នុង គឺថាការសរសេរហ្នឹងគឺមានពាក្យប្រហាក់ប្រហែលគ្នា ហើយខ្ញុំសូមអានដូចតទៅនេះ។ ហើយខ្ញុំមិនអានទេ។ ហេតុផលដោយសារតែពួកគាត់មានភារកិច្ច និងតួនាទីប្រហាក់ប្រហែលគ្នារបស់បុគ្គលដែលបំពេញការងារនៅក្នុងសាខាបក្ស និងនៅក្នុងការងារផ្សេងៗទៀត។

ប្រសិនបើយើងមើលមាត្រា៦ គឺនិយាយអំពីលាក់ការណ៍ចាត់តាំងរបស់បក្ស។ មាត្រា៦ គឺជួយឲ្យយើងយល់អំពីតួនាទីរបស់ អៀង សារី និងជនជាប់ចោទដទៃទៀត។ ពីព្រោះថា ចំណុចនេះគឺបង្ហាញអំពីការធ្វើការសម្រេចចិត្ត ក៏ដូចជាការរាយការណ៍ អំពីវិធីក្នុងការរាយការណ៍ ក៏ដូចជាវិធីសាស្ត្រក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

[១០:០៨:២០]

ប្រសិនបើយើងមើលទៅមាត្រា៥ គឺនិយាយអំពីគោលការណ៍ -- ខ្ញុំសូមអភ័យទោស គឺមាត្រា៦ទេ បាននិយាយថា "បក្សកុម្មុយនីស្តកម្ពុជាប្រកាន់យកគោលការណ៍ប្រជាធិបតេយ្យប្រមូលផ្តុំ ធ្វើជាមូលដ្ឋានចាត់តាំងរបស់ខ្លួន។ ១) គ្រប់អង្គការដឹកនាំបក្សត្រូវអនុវត្តរបបដឹកនាំសមូហភាព ហើយមានបុគ្គលទទួលខុសត្រូវដោយឡែក។ ២) គ្រប់ការសម្រេចផ្សេងៗរបស់បក្សត្រូវធ្វើឡើងដោយសមូហភាព អង្គការដឹកនាំរបស់បក្សគ្រប់ថ្នាក់ត្រូវជ្រើសរើសឡើងដោយសមូហភាព"។

ពាក់ព័ន្ធទៅនឹងការរាយការណ៍គឺបាននិយាយអំពីការធ្វើការរាយការណ៍គឺនៅត្រង់មាត្រា៦ ចំណុចទី៤ "ភាគតិចគោរពភាគច្រើន ថ្នាក់ក្រោមគោរពថ្នាក់លើ បុគ្គលគោរពសមូហភាព ឯកជនគោរពអង្គការ អង្គការថ្នាក់ផ្សេងៗគោរពអង្គការមជ្ឈិម។ តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោមត្រូវរាយ-ការណ៍ជូនថ្នាក់លើអំពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ។ តាមកាលកំណត់នីមួយៗ ថ្នាក់

លើត្រូវរាយការណ៍ជូនថ្នាក់ក្រោមអំពីសភាពការណ៍រួម អំពីសេចក្ដីណែនាំជាទិសការងារផ្សេងៗ។ ទាំងអស់នេះបានបញ្ជាក់ឲ្យច្បាស់អំពីការគ្រប់គ្រង ក៏ដូចជាការរាយការណ៍ និងការទទួលខុសត្រូវក្នុងការតាមដាននៅក្នុងរបស់សមាជិកបក្សកុម្មុយនីស្ដ ហើយជាពិសេសគឺសមាជិករបស់អង្គការគណៈកម្មាធិការមជ្ឈិម។ ហើយវាបានបង្ហាញយ៉ាងច្បាស់ថា ការធ្វើសេចក្ដីសម្រេចចិត្តត្រូវតែធ្វើជាសមូហភាពនៅតាមលំដាប់ថ្នាក់នីមួយៗ។ ខ្ញុំគិតថាចំណុចនេះគឺវាពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក អៀង សារី នៅក្នុងគណៈមជ្ឈិម ក៏ដូចជាគណៈអចិន្ត្រៃយ៍ ហើយក៏ក្នុងនាមគាត់ជារដ្ឋមន្ត្រីក្រសួងការបរទេស ដែលជាសាខាបក្សរបស់បក្សកុម្មុយនីស្តកម្ពុជា។

[១០:១១:០៦]

អត្ថបទចុងក្រោយដែលខ្ញុំ -- មាត្រាចុងក្រោយដែលខ្ញុំនិយាយយោងគឺនៅក្នុងជំពូក២ មាត្រា៥ គឺបាននិយាយអំពីលក្ខណៈវិនិច្ឆ័យចំនួន១០ក្នុងការធ្វើ អំពីលក្ខណៈសម្បត្តិ១០យ៉ាងដើម្បីជ្រើសរើសចូលក្នុងអង្គការដឹកនាំផ្សេងៗរបស់បក្ស។ ហើយលក្ខណៈសម្បត្តិទាំងនោះគឺជាលក្ខណៈសម្បត្តិដែលទាមទារឲ្យមានការសម្រេចចិត្តយ៉ាងម៉ឺងម៉ាត់របស់សមាជិកបក្ស ដើម្បីចូលរួមក្នុងអង្គការដឹងនាំរបស់បក្ស។

"ទី១ គឺបានបញ្ជាក់ថា គោលជំហរបដិវត្តន៍រឹងប៉ឹងខាងមាគ៌ានយោបាយរបស់បក្ស។ នេះជាលក្ខណៈសម្បត្តិទី១។ ទី២ គោលជំហរបដិវត្តន៍រឹងប៉ឹងខាងសតិអារម្មណ៍អធនរបស់បក្ស។ ទី៣ គឺជំហរបដិវត្តន៍រឹងប៉ឹងខាងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់បក្ស។ ៤) ជំហរបដិវត្តន៍រឹងប៉ឹងខាងមាគ៌ាចាត់តាំង ដឹកនាំ និងធ្វើការងាររបស់បក្ស។ ទី៥ ជំហរបដិវត្តន៍រឹងមាំខាងការប្រុងប្រយ័ត្នបដិវត្តន៍របស់បក្ស រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្តន៍។ ទី៦ ជំហរបដិវត្តន៍រឹងប៉ឹងខាងឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន និងខ្លួនធ្វើម្ចាស់លើខ្លួនឯងរបស់បក្ស។ ៧) ជំហរបដិវត្តន៍រឹងប៉ឹងខាងការធ្វើ និងការត្រួតពិនិត្យប្រវត្តិរូបនិងជីវទស្សនៈបដិវត្តន៍។ ទី៨ ជំហរបដិវត្តន៍រឹងប៉ឹងខាងវណ្ណភាព។ ៩) ជំហរបដិវត្តន៍រឹងប៉ឹងខាងសីលធម៌រស់នៅ ស្អាតស្អំ និងស្អាតស្អំខាងនយោបាយ។ និងលក្ខណៈសម្បត្តិទី១០ លទ្ធភាពកសាងខ្លួន និងទទួលនាទីដឹកនាំទៅអនាគត"។

[១០:១៣:០៦]

លោកប្រធាន ដើម្បីបញ្ចប់ទៅលើឯក -- មុននឹងបញ្ចប់ទៅលើឯកសារនេះ ខ្ញុំសូមបញ្ជាក់ថាសមាជិកបក្សគឺត្រូវមានគោរពនៅក្នុងបក្ស ហើយមានតួនាទីដើម្បីការពារក៏ដូចជាកសាងដល់សង្គមនិយម។ ដើម្បីសម្រេចនូវគោលការណ៍នេះគឺត្រូវឲ្យមានការផ្សព្វផ្សាយ ក៏ដូចជាការផ្ដល់ព័ត៌មានដល់

មហាជនអំពីគោលនយោបាយក៏ដូចជានៅក្នុងបក្ស។ ហើយលក្ខន្តិកៈតម្រូវឲ្យពួកគាត់ចូលរួមនៅក្នុងការទិតៀន និងស្វ័យទិតៀន ហើយនិងកសាងនូវគោលជំហរមនោគមន៍វិជ្ជា ក៏ដូចជាសាមគ្គីភាព ហើយនិងរក្សាការសម្ងាត់ដោយមានការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់។

ដូច្នេះលក្ខន្តិកៈគឺបានបញ្ជាក់ថានៅក្នុងកម្រិត ឬក៏នៅក្នុងឋានៈផ្សេងៗគ្នាគឺមានតួនាទី និងភារកិច្ចរៀងៗខ្លួន។ នៅក្នុងកម្រិតខ្ពស់បំផុតដែលបានបញ្ជាក់នៅក្នុងលក្ខន្តិកៈ គឺគណៈអចិន្ត្រៃយ៍ គឺធានាដល់មាគ៌ាបក្សត្រូវបានគេគោរពអនុវត្តនៅទូទាំងប្រទេស។ ដូច្នេះនិយាយជារួមគឺថាលក្ខន្តិកៈនេះគឺបង្ហាញជាគោលការណែនាំអំពីអាកប្បកិរិយាដល់សមាជិកបក្ស ក៏ដូចជាប្រជាជនទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះជួយដល់យើងដល់យល់អំពីតួនាទី និងអាកប្បកិរិយារបស់លោក អៀង សារី ក៏ដូចជាជនជាប់ចោទដទៃទៀតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:១៤:៥០]

លោកប្រធាន ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបន្តទៅឯកសារបន្ទាប់។ គឺឯកសារ E3/597 គឺជាកិច្ចសម្ភាសជាមួយលោក អៀង សារី ដែលយើង -- ដែលមានចំណងជើងថា គឺជាការសម្ភាសជាមួយនឹងសារព័ត៌មាន ឡឺម៉ុងដ៍ ហើយជាប្រសាសន៍របស់មេដឹកនាំប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ លោក អៀង សារី បានផ្ដល់ព័ត៌មាអំពីតួនាទីរបស់គាត់មុនឆ្នាំ៧៥ ហើយគាត់ផ្ដល់ទស្សនៈទាក់ទងទៅនឹងសហរដ្ឋអាមេរិក ក៏ដូចជាការអនុវត្តរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងការដឹកនាំ ក៏ដូចជានៅក្នុងឋានានុក្រមការងារ តាមរយៈគណៈកម្មការដែលមានឋានៈផ្សេងៗគ្នា។

[១០:១៥:៥៤]

ខ្មែរមានលេខ 0074476(ស៊ីក), បារាំងមានលេខ 00722245, អង់គ្លេស 00003963។ គេបានសួរថា "តើលោករៀបចំអំណាចបែបណាដែរនៅក្នុងចំណោមប្រជាជន? គឺថានៅក្នុងគោលការណ៍នេះ គឺថាប្រជាជនគឺជាប្រភពនៃអំណាច ហើយនៅកម្រិតក្រសួងទាំងអស់ ចាប់ពីភូមិ ឃុំ ស្រុករហូតដល់ខេត្តគណៈកម្មការបំពេញតួនាទីជាបក្ស"។

ហើយចុះក្រោមខ្មែរគឺ 00749036 ហើយគាត់និយាយអំពីតួនាទីរបស់បក្ស។ "សមាជិករបស់អ្នកបំពេញការងារត្រូវធានាឲ្យបានទាប ហើយធានាថាកងកម្លាំងនយោបាយគោរពទៅតាមគោលការណ៍ ហើយត្រូវមានការរៀនសូត្រ ក៏ដូចជាការមកបំពាក់បំប៉នវគ្គនយោបាយ វប្បធម៌ និងយោធា"។

ពាក់ព័ន្ធទៅនឹងតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងនាមជាសមាជិកគណៈ

អចិន្ត្រៃយ៍ គាត់បានបញ្ជាក់នូវតួនាទីដូចតទៅ៖ "ប្រជាជនត្រូវបានគេផ្ដល់ឲ្យ ហើយលោកត្រូវតែមានសំអាងហេតុគ្រប់គ្រាន់។ ចាប់តាំងពីឆ្នាំ៧១ យើងបានគោរពមួយជំហានម្ដងៗនូវសកម្ម -- យើងបានដឹងមួយជំហានម្ដងៗ នូវសកម្មភាពឧក្រិដ្ឋរបស់ពួកអាមេរិកាំង យើងបានដឹងអំពីលក្ខណៈរបស់ពួកចក្រពត្តិនិយម ដែលយើងតែងតែប្រយុទ្ធប្រឆាំង ហើយព្យាយាមចង់បំផ្លាញនូវភាពឯករាជ្យ ក៏ដូចជាអធិបតេយ្យអព្យាក្រឹតភាពរបស់កម្ពុជា ដើម្បីផ្ដល់ ឬក៏ដើម្បីកែប្រែកម្ពុជាក្លាយទៅជាមូលដ្ឋាននៃការឈ្លានពាន។

[១០:១៨:២៤]

យើងបានរំពឹងមើលឃើញតាំងពីយូរមកហើយនូវរដ្ឋប្រហារ ហើយយើងគិតថាស្ថានភាពនៅក្នុងប្រទេសកម្ពុជា និងវៀតណាមខាងត្បូងនឹងនាំទៅដល់ការ -- នឹងធ្វើឲ្យចក្រពត្តិអាមេរិក និងបនទៅក្នុងប្រទេសកម្ពុជាហ្នឹងធ្វើការប្រព្រឹត្តនូវបទល្មើសដ៏ធ្ងន់ធ្ងរមួយ--

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំឲ្យតំណាងព្រះរាជអាជ្ញាគាត់អានឯកសារឲ្យបានយឺតបន្តិច។

**លោក វីណ្ឌៀម ស្មីត៖**

ការងារទាំងនេះគឺវា-- គឺថាការងារទាំងនេះកើតឡើងមុនពេលដែលរដ្ឋប្រហារបានធ្វើឡើង។ យើងបានសម្រេចនូវការចែករំលែកនូវការគោលនយោបាយទៅដល់ប្រជាជន ដល់មហាជន ជាមួយនឹងគោលការណ៍នៃការដឹកនាំសង្គ្រាមប្រយុទ្ធប្រឆាំងរយៈពេលវែង។ ដូច្នេះហើយជារួមប្រជាជនរបស់យើងគឺមិនមានភ្ញាក់ផ្អើលឡើយនៅពេលដែលទទួលបានព្រឹត្តិការណ៍ឆ្នាំ៧០។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនៃការប្រយុទ្ធប្រឆាំង ប្រឆាំងពួកកុម្មុយនីស្ត ពួកៗសក្តិភូមិនិយមអាមេរិក និងអាណានិគមនិយមបារាំង គឺយើងបានបង្រៀនប្រជាជនរបស់យើងថា ដើម្បីធ្វើបដិវត្តន៍ឲ្យបានជោគជ័យ វាមិន -- គឺចាំបាច់ត្រូវតែមានស្ថាប័ននីយមួយៗដើម្បីដឹកនាំ ហើយស្ថាប័នហ្នឹងត្រូវមានបុគ្គលដែលមានគោល-ការណ៍រឹងមាំ។ បុគ្គលទាំងនេះត្រូវតែគោរព ត្រូវតែមានទំនាក់ទំនងជិតជាមួយប្រជាជន ការប្រយុទ្ធប្រឆាំងត្រូវតែពឹងផ្អែកទៅលើមហាជនដែលធ្វើការយ៉ាងប្រឹងប្រែង ហើយក្នុងចំណោមមហាជនហ្នឹងគឺមានកម្មករ និងកសិករ។

[១០:២០:១៥]

លោកប្រធាន ជាបន្តទៅទៀតនេះ ខ្ញុំសូមបន្តទៅឯកសារបន្ទាប់ E3/597 គឺជាការដកស្រង់មួយទៀតដែលខ្ញុំសូមលើកឡើងថា គឺជាការបង្ហាញអំពីតួនាទីរបស់ អៀង សារី ក៏ដូចជាការជឿជាក់របស់

គាត់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា គឺនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឆ្នាំ៧៥ ដល់ ៧៩។ ឯកសារគឺមានលេខ E3/11 ហើយវាជាការសម្ភាស ជាមួយលោក អៀង សារី ដែលបោះពុម្ពផ្សាយនៅក្នុងសារព័ត៌មាននៅថ្ងៃ៣១ ខែមករា ឆ្នាំ៧២ ដែលជាការសួរអំពីការវិវត្ត របស់ ហ្មុង ហើយនិង ប្រ្កុង នៅក្នុងប្រទេសកម្ពុជា ដោយមានការនិយាយយោងទៅលើកំណែទម្រង់កសិកម្មនៅក្នុងតំបន់រំដោះ។ ការសម្ភាសនេះ ផ្តល់នូវការពិនិត្យមើលនៅពេលនោះ ថាតើប្រជាជននឹងត្រូវ ហើយនិងដីស្រែត្រូវបានប្រើប្រាស់បែបណាដើម្បីទទួលបានជោគជ័យដោយបក្សកុម្មុយនីស្តកម្ពុជា។

[១០:២១:៣០]

ខ្ញុំសូមលើកយកឯកសារ E00711428129 (ស៊ីក), ហើយភាសាអង់គ្លេសមាន 007624151 ដល់ 16, និងភាសាបារាំងមានលេខ 00738624 នេះគឺជាចម្លើយដែលគាត់ឆ្លើយ។ “នៅពេលដែលយើងនិយាយដល់កសិករ គឺយើងធ្វើកំណែទម្រង់បដិវត្តន៍ជាពិសេសទាក់ទងទៅនឹងដីធ្លី”។ សំណួរបន្តទៀត តើគេរៀបចំការផលិតដោយរបៀបណា? បញ្ហាកសិករ គឺមានសារៈសំខាន់ចំពោះយើង។ យើងបានអនុវត្តនូវមធ្យោបាយប្រជាធិបតេយ្យជាច្រើន ដើម្បីបែងចែកកម្លាំងដល់បណ្តាកសិករក្រីក្រ ហើយនិងដើម្បីបង្កើននូវការផលិតរបស់យើង។ ដីស្រីដែលជាកម្មសិទ្ធិរបស់ជនក្បត់ដែលមានចំនួនរាប់ពាន់ហិកតាត្រូវបានយើងប្រមូលផ្តុំ ហើយបានក្លាយទៅជារបស់រួមនៅក្នុងអំណាចប្រជាជន ឬក៏បែងចែកទៅដល់កសិករដែលមិនមានដីធ្លីទៅតាមគោលការណ៍របស់ប្រទេស។ ដីដែលមិនមានម្ចាស់ ឬក៏ជារបស់ជនក្បត់ដទៃទៀតត្រូវបានផ្ទេរទៅដល់អំណាចប្រជាជន ដើម្បីឲ្យធ្វើការច្រូតកាត់ប្រមូលផល។

ចំពោះគោលការណ៍នៃការប្រគល់ដីដែលជារបស់រដ្ឋត្រូវទុកទៅម្ខាង ហើយក្នុងពេលជាមួយគ្នាហ្នឹង យើងត្រូវគិតអំពីអាកប្បកិរិយានយោបាយ។ ទាក់ទងទៅនឹងការបែងចែកដីជាកម្មសិទ្ធឯកជន គឺយើងត្រូវធ្វើការប្រមូលផលដោយកសិករដែលមិនមានដី ហើយយើងមិនទៅគិតអំពីការបង់កម្រៃនោះឡើយ។ ជារួមដីដែលយើងត្រូវបានជួល គឺវាមានកម្រិតលើស៥០ភាគរយនៃចំណាយក្នុងការផលិត ហើយត្រូវបានកាត់បន្ថយយ៉ាងខ្លាំង។ អត្រាការប្រាក់ដែលមានលើស៥០ ទៅ ៦០ភាគរយ ក្នុងមួយឆ្នាំត្រូវបានហាមឃាត់ក្នុងការជួលដី។ ដើម្បីធ្វើឲ្យមានផ្លែផ្កាចំពោះគោលនយោបាយកសិកម្មរបស់យើងក្នុងការគោរពទៅតាមកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹង គឺយើងធ្វើការងារដូចតទៅនេះ៖ អង្គការ របស់កសិករទាំងអស់បានអនុម័តទៅលើកំណែទម្រង់កសិកម្ម ហើយយើងបង្កើតបានទៅជាសមាគមកសិករស្នេហាជាតិ។ យើងជំរុញឲ្យមានការបង្កើតនូវសហករណ៍កសិករ ហើយ

និងសហករណ៍អ្នកប្រើប្រាស់ដើម្បីកាត់បន្ថយនូវឈ្មួញកណ្តាល។ នៅក្នុងគណៈកម្មាធិការនីមួយៗយើងមានកម្រិតរដ្ឋបាល ផ្សេងៗគ្នា ហើយយើងរក្សានៅការផលិត ហើយគោលដៅសំខាន់គឺដើម្បីឲ្យមានការប្រមូលផល។ ស្របទៅតាមការអប់រំផ្នែកនយោបាយ ហើយនិងការយោគយល់គ្នាទៅវិញទៅមក។ កសិករបានទទួលបានផលស្រូវពីរដងក្នុងមួយឆ្នាំ។ ដោយសារតែមានសង្គ្រាមរយៈពេលវែង យើងផ្តល់សារៈសំខាន់ទៅដល់កសិផលបន្ទាប់បន្សំ ហើយនិងការចិញ្ចឹមជ្រូក និងមាន់ទា។

[១០:២៦:០០]

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំសូមបន្តទៅឆ្នាំ៧៥ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនូវខ្សែវីដេអូមួយដែលមាន E3/3051R។ លោកប្រធាននេះគឺជាខ្សែវីដេអូដែលបង្ហាញអំពី ប៉ុល ពត, នួន ជា, អៀង សារី និងសុន សេន ព្រមទាំងមេដឹកនាំដទៃទៀតរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលដឹកនាំៗមីទ្ទិងនៅស្តាតអូឡាំពិក។ ខ្សែវីដេអូនេះបង្ហាញអំពីអំណាចនិងសិទ្ធិរបស់លោក អៀង សារី និងមេដឹកនាំដទៃទៀតដែលជាក្រុមមេដឹកនាំ។ យើងមិនដឹងច្បាស់អំពីកាលបរិច្ឆេទនៃខ្សែវីដេអូនេះទេ ដូច្នេះវាអាចកើតឡើងនៅពេលណាមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប៉ុន្តែខ្សែវីដេអូនេះបានឆ្លុះបញ្ចាំងនូវមីទ្ទិងនានា ដែលយើងបានឮនៅក្នុងឯកសារភស្តុតាងនានា។ ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាបង្ហាញនូវខ្សែវីដេអូនេះដែលមានរយៈពេល ៤នាទី និង១២វិនាទី។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! អ្នកបច្ចេកទេសសោតទស្សន៍ដាក់បង្ហាញឯកសារវីដេអូនៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ លោក លោកស្រីចៅក្រមខ្សែវីដេអូនេះមិនមានសំឡេងទេ។

[១០:២៨:១៧]

*(ការបង្ហាញឯកសារវីដេអូជារូបភាព)*

[១០:៣១:៥៨]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។

ឯកសារបន្ទាប់ទៀត គឺខ្សែវីដេអូបន្ទាប់ទៀត ០៥:៣២ វិនាទី មានរយៈពេល ០៥:៣២ វិនាទី បង្ហាញអំពីតួនាទីរបស់លោក អៀង សារី នៅក្រសួងការបរទេស។ ហើយគឺខ្សែវីដេអូនេះមិនអាចចាក់ដាច់ចេញពីគ្នានោះទេ។ ប្រសិនបើលោក លោកស្រីចៅក្រមចង់ពិនិត្យខ្សែវីដេអូនេះមើលមុនពេលឈប់សម្រាកនោះគឺអាចធ្វើទៅបាន ឬក៏លោកចៅក្រមឲ្យឈប់សម្រាកសិន។ គឺឯកសារ E3/320R។ ខ្សែវីដេអូនេះបង្ហាញអំពីតួនាទីរបស់លោក អៀង សារី នៅក្នុងគណៈប្រតិភូអន្តរជាតិ នៅក្នុងចំណោមគណៈប្រតិភូអន្តរជាតិ ពាក់ព័ន្ធទៅនឹងការងារបរទេសជាមួយនឹងវៀតណាមផងដែរ។ នៅក្នុងនេះ ខ្សែវីដេអូជាមួយនឹងគណៈប្រតិភូវៀតណាម គឺនៅខ្សែវីដេអូប្រជុំថ្ងៃ -- បង្ហាញថ្ងៃទី២៧ ខែកក្កដា ឆ្នាំ៧៥ ហើយទាក់ទងទៅនឹងការជួបប្រជុំជាមួយនឹងគណៈប្រតិភូវៀតណាមជាមួយនឹង ប៉ុល ពត, នួន ជា, ខៀវ សំផន, វន វ៉េត និងបុគ្គលទាំងឡាយដែលបានជួបនៅក្នុងថ្ងៃជាមួយគ្នានោះ។

[១០:៣៣:៣១]

ចំណុចសម្គាល់មួយដែលខ្ញុំសូមលើកឡើងនោះគឺថា ខ្សែវីដេអូមួយនេះ និងខ្សែវីដេអូដទៃទៀតដែលនឹងបង្ហាញ គឺបង្ហាញអំពីគណៈប្រតិភូអន្តរជាតិ ដែលបានមកធ្វើទស្សនកិច្ចនៅក្នុងគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម។ ហើយក្នុងពេលនោះគឺយើងឃើញថា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍បានជួបប្រជុំរួមគ្នា។ ដូច្នេះ សូមអនុញ្ញាតពីលោកប្រធានចាក់ខ្សែវីដេអូនេះ។ សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! អ្នកបច្ចេកទេសសោតទស្សន៍ចាក់បង្ហាញខ្សែវីដេអូលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

**លោក វីណ្ឌៀម ស្មីត៖**

លោកប្រធាន ខ្ញុំសូមបញ្ជាក់ថា ខ្សែវីដេអូមួយនេះ គឺមានសំឡេងផងដែរ។

[១០:៣៤:២៤]

*(ការបង្ហាញឯកសារវីដេអូ)*

*"សមមិត្ត សាឡុត ស ជាអគ្គលេខានៃគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា រួមជាមួយនឹងបណ្ដាសមមិត្តអ្នកដឹកនាំបក្ស នៃកិច្ចការរដ្ឋខាងកម្ពុជាជាច្រើននាក់ បានអញ្ជើញមកដល់ចំណតយន្តហោះពោធិ៍ចិនតុង រង់ចាំធ្វើបដិសណ្ឋារកិច្ច នឹងគណៈប្រតិភូនៃបក្សពលករវៀតណាម ដោយមេត្រីស្និទ្ធស្នាល ដោយសាមគ្គី និងមិត្តភាព ជាភាតរៈ យ៉ាងកក់ក្ដៅបំផុត។ នេះគឺជាទស្សនកិច្ចជាលើកដំបូងបង្អស់របស់*

គណៈប្រតិភូជាន់ខ្ពស់នៃបក្ស និងរដ្ឋវៀតណាមនៅកម្ពុជា គិតតាំងពីក្រោយថ្ងៃដែលប្រទេសកម្ពុជាបានរំដោះទាំងស្រុងមក។

ប្រជាជននិងកងទ័ពកម្ពុជារាប់ពាន់នាក់បានទទួលអបអរសាទរយ៉ាងឱឡារិកចំពោះគណៈប្រតិភូនៃបក្សយើងដែលជាយុទ្ធមិត្តដ៏ជិតស្និទ្ធ និងស្នេហ៍ស្និទ្ធបំផុតរបស់ប្រជាជនកម្ពុជា។

វត្តមាននៅទីក្រុងភ្នំពេញអស់រយៈពេល២ថ្ងៃជាប់ គណៈប្រតិភូនៃបក្សពលករវៀតណាមបានសម្តែងនូវសេចក្តីដឹងគុណដ៏ស្មោះសរបស់វៀតណាមចំពោះការជួយ (ឮមិនច្បាស់) បានរំឭកឡើងវិញនូវប្រវត្តិសាស្ត្រកសាងប្រទេសដ៏រុងរឿងរបស់ប្រជាជាតិខ្មែរ និងចំណងសាមគ្គីភាពរវាងប្រជាជនវៀតណាម និងប្រជាចិនឲ្យបរាជ័យ។ ប្រជាជនតែមួយ មាគ៌ាសមស្របរបស់ខ្លួន-- ត្រូវរួបរួមជាតិក្រោមការដឹកនាំរបស់បក្សកុម្មុយនីស្ត។ ប្រជាជនកម្ពុជា -- ១៧ខែមេសា ឆ្នាំ១៩៧៥ នាំមកនូវសុខសន្តិភាពជូនមាតុភូមិ។

[១០:៣៦:២០]

ប្រែប្រួលជាសារវន្ត៖ ការតស៊ូរបស់ប្រជាជនទាំងបីប្រទេសបានដណ្តើមយកជ័យជម្នះយ៉ាងធំសម្បើម។ បុព្វហេតុបដិវត្តន៍របស់ប្រជាជនទាំងបីប្រទេសនៅឥណ្ឌូចិនបាន--(ភ្លេង) ក្រោមការដឹកនាំយ៉ាងកក់ក្តៅបំផុតចំពោះជោគជ័យយ៉ាងត្រចះត្រចង់អំពីច្រើនវិស័យរបស់ប្រជាជនកម្ពុជាជាបងប្អូន។ ក្រោយពីការតស៊ូទទួលបានជ័យជម្នះ ប្រជាជនកម្ពុជាបានខិតខំខ្នះខ្នែងធ្វើការងារពលកម្មដោយឧស្សាហ៍ព្យាយាម និងក្លាហានអង់អាច ហើយគ្រាន់តែប៉ុន្មានខែក្រោយមកប៉ុណ្ណោះ ក៏បានទទួលនូវជោគជ័យយ៉ាងធំក្នុងការពង្រាបជាបងប្អូន ស្តីពីបញ្ហាជាច្រើន ដែលទាំងសងខាងសុទ្ធតែបានយកចិត្តទុកដាក់គណៈប្រតិភូនៃបក្សពលករវៀតណាម និងគណៈដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជាបានឯកភាពគ្នា ទាំងស្រុងវៀតណាម និងកម្ពុជាមានព្រំប្រទល់ជាប់នឹងគ្នាជិត ១.០០០គីឡូម៉ែត្រ ហើយមានការទាក់ ទងជាប់ស្អិតជាមួយគ្នាអំពីច្រើនវិស័យ ខាងប្រវត្តិសាស្ត្រ វប្បធម៌នៃភូមិសាស្ត្រ។ ហើយសុខរួមរំលែក នូវការផ្អែមឆ្ងាញ់ជូរចត់ជាមួយគ្នា សាមគ្គីជាមួយគ្នា ប្រយុទ្ធដើម្បីការពារស្រុកកំណើតរបស់ប្រទេសនីមួយៗ ហើយកសាងចំណងសាមគ្គីភាពជាភាតរៈឲ្យបានឋិតថេរជានិច្ច។

[១០:៣៧:៥៨]

ដើម្បីទុកជាអនុស្សាវរីយ៍នៃការជួបជុំសន្ទនាជាប្រវត្តិសាស្ត្រនេះ គណៈកម្មាធិការនៃមជ្ឈិមបក្សនៃពលករវៀតណាមបានជូនដល់គណៈកម្មាធិការនៃមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា នូវផ្ទាំងគំនូរដ៏ល្អ

*វិចិត្រមួយផ្ទាំង ប្រដាប់តែបុរាណមួយសម្រាប់ និងផ្ទាំងគំនូរមួយផ្ទាំងមានរចនាជាអក្សរថា "ចំណងសាមគ្គីប្រយុទ្ធ និងមិត្តភាពរវាងបក្សពលករវៀតណាម និងបក្សកុម្មុយនីស្តកម្ពុជាក្នុងផ្ទះតែមួយ"។ បាទដៃ ទាំងឡាយដែលក្តាប់រឹតរវាងបណ្តា-- កង(ឮមិនច្បាស់) នៅតែល្អចិនជាថ្មីទៀត។ ក្រោយពី២ថ្ងៃដែលរួមគ្នាធ្វើការអស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីបុព្វហេតុបដិវត្តន៍របស់ប្រទេសទាំងពីរ និងសកលលោក នៅថ្ងៃ២៩ កក្កដា ឆ្នាំ១៩៧៥ គណៈប្រតិភូនៃបក្សពលករវៀតណាមបានគោរពលាបណ្តាមិត្ត បណ្តាសមមិត្តដ៏ស្នេហ៍ស្និទ្ធរបស់ខ្លួន និងចំពោះមនោសញ្ចេតនាដ៏ជ្រាលជ្រៅ និងក្តីអាលោះអាល័យ-- ការពារលទ្ធផលបដិវត្តន៍ និងខិតខំធ្វើការងារពលកម្មកសាងមាតុភូមិជាទីស្នេហា។*

[១០:៣៩:១៤]

*ដើម្បីចំណងសាមគ្គីភាពដ៏រឹងប៉ឹង និងមហិមារបស់ប្រជាជាតិទាំងពីរ យើងខ្ញុំជាជនកុម្មុយនីស្តវៀតណាមសូមប្តេជ្ញាអនុវត្តឲ្យបានពេញលេញបំផុតនូវពាក្យបណ្តាំដ៏ពិសិដ្ឋរបស់លោកប្រធាន ហូ ជីមិញ គឺខិតខំយកអស់កម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីពង្រឹងនិងពង្រីកចំណងមិត្តភាពដ៏ល្អប្រពៃរវាង ប្រជាជនវៀតណាម ប្រជាជនកម្ពុជា ព្រមទាំងប្រជាជនលាវជាបងប្អូន ឈរលើមូលដ្ឋាននៃរាល់លាក់ការណ៍ស្មារតីស្មើភាពនិងគោរពគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍យូរអង្វែងរបស់ជាតិនីមួយៗ"។*

*(បញ្ចប់ការបង្ហាញឯកសារវីដេអូ)*

[១០:៤០:០៣]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤០ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញនូវឯកសារ។

សូមអញ្ជើញលោកមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពតុលាការសាជាថ្មី។

ខ្ញុំបាទស្នើសុំដល់តំណាងអយ្យការ មិនចាំបាច់លើកយកឯកសារមកអះអាងចំពោះអង្គហេតុដែលលោក អៀង សារី មិនបានជំទាស់តវ៉ានោះទេ។ ព្រោះការលើកឯកសារមកអះអាងអង្គហេតុដែលលោក អៀង សារី មិនបានជំទាស់តវ៉ានេះ វានាំតែខាតពេលទេ។ សូមជម្រាបថានៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឲ្យភាគីទាំងឡាយដាក់ឯកសារដើម្បីត្រៀមរៀបចំសវនាការ។

[១១:០៣:៤៦]

តាមសំណើរបស់សហព្រះរាជអាជ្ញា យើងបានឆ្លើយតបនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ទៅលើអង្គហេតុមួយចំនួនដែលលោក អៀង សារី គាត់មិនជំទាស់តវ៉ា។ នេះនៅក្នុងឯកសារ E9/21.3។ ប៉ុន្តែឯកសារដដែលដែលទាក់ទងនឹងជនជាប់ចោទដទៃទៀត ខ្ញុំមិនជំទាស់ទេ ប៉ុន្តែក្នុងករណីដែលយកមកប្រើសម្រាប់តែបញ្ជាក់ពីអង្គហេតុទាក់ទងលោក អៀង សារី ដែលគាត់មិនជំទាស់តវ៉ាបែបនេះ ខ្ញុំថាវានាំតែខាតពេលវេលាទេ។ ក៏ប៉ុន្តែបើព្រះរាជអាជ្ញាធ្វើសាថ្មីម្តងទៀត ក៏ខ្ញុំមិនយល់ទាល់ទេ។ ប៉ុន្តែយ៉ាងណាបើសិនជាមិនចាំបាច់លើកយកមក ព្រោះយើងអត់បានឈ្លោះតវ៉ា ប្រកែកផងហ្នឹង ហើយយកមកជជែកគ្នានាំតែខាតពេលទេ។ សូមអរគុណ។

**លោក វីល្លៀម ស្មីត៖**

លោក លោកស្រីចៅក្រម ខ្ញុំសូមធានាថាខ្ញុំនឹងមិនអានមួយសាជាថ្មីទៀតទេ។ ប៉ុន្តែគោលដៅសំខាន់ដែលយើងលើកយកអង្គហេតុកាលពីព្រឹកមិញនេះ គឺថាអង្គជំនុំជម្រះបានជម្រាបមកយើងថាគោលដៅសំខាន់នៃសវនាការនេះ គឺបង្ហាញដល់សាធារណជន ក៏ដូចជាការបង្ហាញនូវឯកសារភស្តុតាងនានា។ នៅពេលដែលយើងធ្វើការកាត់បន្ថយនូវចំនួន ដោយបង្ហាញឯកសារមួយចំនួន ឯកសារខ្លះមិន

បង្ហាញ វាធ្វើឲ្យរូបភាពចេញមកវាមិនបានច្បាស់លាស់។ ប៉ុន្តែយ៉ាងណាយើងសូមធានាថា យើងនឹងមិនអានឯកសារនេះសាជាថ្មីឡើងវិញនោះទេ។ ដូច្នេះជាបន្តទៅទៀតនេះ ខ្ញុំសូមបន្តទៅខ្សែវីដេអូ។

[១១:០៥:៤២]

លោក លោកស្រីចៅក្រម ដូចដែលសហការីខ្ញុំបានបញ្ជាក់រួចទៅហើយ គឺយើងព្យាយាមពិនិត្យមើលទៅលើឯកសារដែលទាក់ទងទៅនឹងលោក អៀង សារី តាមលំដាប់លំដោយ ហើយនៅពេលដែលយើងមកផ្តល់ឯកសារមួយចំនួន យើងនឹងផ្អាក ហើយយើងនឹងពិភាក្សាទៅលើឯកសារទាំងអស់នេះ។ ឧទាហរណ៍ដូចជា របាយការណ៍កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ជាដើមនោះ។ ប៉ុន្តែឥឡូវនេះ យើងនៅក្នុងឆ្នាំ៧៥នៅឡើយ។ ហើយខ្ញុំសូមបង្ហាញនូវវីដេអូមួយដែលមានលេខ E3/2384R ហើយវាជាខ្សែវីដេអូដែលបង្ហាញលោក អៀង សារី ពិភាក្សាជាមួយនឹងអ្នកសារព័ត៌មាននៅក្នុងឆ្នាំ៧៥ អំពីមូលហេតុដែលភ្នំពេញត្រូវបានគេជម្លៀស។ វាមានរយៈពេល២នាទី និង៣វិនាទី។ ហើយបន្តទៀតមានផ្នែកមួយរបស់លោក ស៊ីវ ហេងឆ័រ ដែលបន្តពីផ្នែកនេះមានរយៈពេលប្រហែល ៣០វិនាទីប៉ុណ្ណោះ។

ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានមេត្តាបង្ហាញនូវខ្សែវីដេអូនេះ។

[១១:០៧:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ដាក់បង្ហាញឯកសារវីដេអូនៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា។

[១១:០៧:២២]

*(ការបង្ហាញឯកសារវីដេអូ)*

*"អៀង សារី៖ ដូចលោកដឹងស្រាប់ហើយ កាលមុនរំដោះយើងខ្ញុំស្មានតែមានប្រជាជនតែ៧លាននាក់ (ឮមិនច្បាស់) ប៉ុន្តែដាក់ស្តែងដល់រំដោះហើយភ្លាម យើងខ្ញុំឃើញថាប្រជាជននៅភ្នំពេញ ហើយនិងនៅទីរួមខេត្ត ឡើងទៅជិត៣លាននាក់ ដែលបក្សមានការរៀបចំពីមុនមកហើយ រៀបចំទៅដោះស្រាយបញ្ហានេះបាន។ ក្នុង៥ថ្ងៃ យើងរំដោះប្រជាជននៅក្នុងភ្នំពេញ (ឮមិនច្បាស់) ចេញទៅ (ឮមិនច្បាស់)។ យើងឃើញថា ហេតុផលមួយទៀត ដែលនាំឲ្យយើងខ្ញុំដកប្រជាជនចេញពីភ្នំពេញ ព្រោះថាយើងខ្ញុំដឹងច្បាស់ បានឯកសារច្បាស់ថាមុនរំដោះនេះនៅខែមករា។*

*បរិយាយ(មិនស្គាល់អត្តសញ្ញាណ)៖ មូលហេតុនៃការជម្លៀសប្រជាជនមានដូចតទៅ ដើម្បីប្រែ*

*ក្លាយកម្ពុជាឲ្យទៅជាប្រទេសទំនើប គេត្រូវធ្វើឲ្យប្រជាជនក្លាយជាវណ្ណៈអធន ដោយបង្កើតជាសហករណ៍ជនបទពាក់កណ្ដាលឧស្សាហកម្ម។ ប្រព័ន្ធនេះតម្រូវឲ្យលត់ដំអ្នកទីក្រុងដែលត្រូតពិនិត្យ ក) ដោយកសិកក្រីក្រ និង ខ) ដោយបក្សតាមរយៈកសិករទាំងនេះ។*

*អៀង សារី៖ ក៏ចាប់ផ្ដើមវែដល់ខែកុម្ភៈ ហើយនិងមិថុនា (ពុំមិនច្បាស់) បានដឹងថាខ្លួនចាញ់ពេលដែលមេគង្គត្រូវដាច់ [...]”*

*(បញ្ចប់ការបង្ហាញឯកសារវីដេអូ)*

[១១:០៩:៤០]

**លោក វ៉ែណ្ឌៀម ស្មីត៖**

សូមអរគុណលោក លោកស្រីចៅក្រម។ ដើម្បីបញ្ជាក់ឲ្យច្បាស់នេះគឺជាខ្សែវីដេអូពេញតែម្ដង មិនមែនជាការកាត់តអ្វីនោះឡើយ គឺថានៅពេលដែលយើងឃើញថាមានលោក ស៊ីវ ហេដឌ័រ បន្ទរពីលោក អៀង សារី ហ្នឹងគឺមិនមែនយើងកាត់តទេ គឺវីដេអូវាចេញមកបែបនេះតែម្ដង។

នៅក្នុងឆ្នាំ៧៥ ដែលមានការបោះពុម្ពផ្សាយនូវសារព័ត៌មានញូវស៍វីកថ្ងៃ០៨ ខែ៩ ឆ្នាំ៧៥ នោះលោក អៀង សារី បានផ្ដល់ការសម្ភាសទៅជាមួយនឹងលោក ជេមស៍ ព្រីងហ្គល *(James Pringle)* ដែលជាប្រធានការិយាល័យអាមេរិកឡាទីននៅក្នុងសារព័ត៌មានញូវស្វីក។ គឺឯកសារ E3/550 គឺជាការផ្ដល់ការសម្ភាសនៅក្នុងកិច្ចប្រជុំបណ្ដាប្រទេសមិនចូលបក្សសម្ព័ន្ធ។ ការសម្ភាសនេះផ្ដល់នូវព័ត៌មានទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ដោយលោកអៀង សារី និយាយផ្ទាល់មាត់តែម្ដង។

ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញអត្ថបទនៅក្នុងអេក្រង់មានលេខ 00087603 ដល់ 604, ហើយខ្មែរមានលេខ 00291035 ដល់ 38, បារាំងមានលេខ 00698262 ដល់ 64។ ដូច្នេះខ្ញុំសូមអនុញ្ញាតបង្ហាញ “លោក ជេមស៍ ព្រីងហ្គល បាននិយាយអំពីខ្សែវីដេអូឃោសនាការដែលលោក អៀង សារី បានចាក់បង្ហាញនូវមហាសន្និបាតនោះ។ ហើយការចាប់ផ្ដើមគឺនិយាយថា “ហេតុអ្វីបានជាខ្សែភាពយន្តហ្នឹងវាសំខាន់ ដើម្បីបង្ហាញដល់ពិភពលោកឲ្យឃើញថាប្រជាជន គឺថា -- គឺត្រង់ថា វាឲ្យសាកលលោកមើលឃើញកម្ពុជាជាលើកដំបូងចាប់តាំងពីថ្ងៃជ័យជម្នះខ្មែរក្រហមខែមេសាមក។

[១១:១១:៥៨]

ពិតណាស់វត្តមាននៅក្នុង នៅទីក្រុងលីម៉ារបស់លោក អៀង សារី ឧបនាយករដ្ឋមន្ត្រីកម្ពុជា

ទើបតែងតាំងថ្មី ដែលអ្នកផងជឿថាជាមនុស្សម្នាក់ក្នុងចំណោមមេដឹកនាំកំពូលពីរ ឬបីរូបរបស់របប ភ្នំពេញថ្មី បានធ្វើឲ្យគេគិតថាកម្ពុជាថ្មីកំពុងត្រៀមខ្លួនចេញពីវាំងននខ្មៅ ដើម្បីស្វែងរកការទំនាក់ទំនង កាន់តែទូលំទូលាយជាមួយអន្តរជាតិ។ ហើយការសម្ភាសបានចាប់ផ្តើមដូចតទៅនេះ

“លោក ជេមស៍ ព្រីងហ្គល បានសួរលោក អៀង សារី តទៅ៖ ហេតុអ្វីបានជាកងកម្លាំងរបស់ អ្នកជម្លៀសប្រជាជនចេញពីភ្នំពេញ ក្រោយពីពួកគេបានកាន់កាប់ទីក្រុងភ្នំពេញថ្ងៃទី១៧ ខែមេសា? លោក អៀង សារី បានឆ្លើយថា៖មានមូលហេតុពីរ មូលហេតុទី១ គឺកត្តាស្បៀង យើងបានគិតថាមាន ប្រជាជនចំនួន២លាននាក់នៅភ្នំពេញ ប៉ុន្តែពេលយើងបានចូលទៅដល់ យើងបានដឹងថាមានចំនួន ៣លាននាក់។ កាលពីមុនសហរដ្ឋអាមេរិកបានដឹកជញ្ជូនស្បៀងចំនួន៣០.០០០ ទៅ ៤០.០០០ តោនក្នុង មួយខែចូលភ្នំពេញ។ យើងពុំមានមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាប់ដើម្បីជញ្ជូនស្បៀងចូលទៅក្រុង ដូច្នេះ ប្រជាជនត្រូវតែធ្វើដំណើរទៅកាន់ទីកន្លែងមានស្បៀង។ ហើយយើងត្រូវតែផ្គត់ផ្គង់ស្បៀងដោយឯករាជ្យ មិនពឹងពាក់ប្រទេសដទៃ។ សំណួរ៖ តើមូលហេតុទី២ ជាអ្វី? លោកអៀង សារី បានឆ្លើយថា៖យើងបាន រកឃើញឯកសារមួយដែលនិយាយលម្អិតអំពីផែនការនយោបាយ យោធាសម្ងាត់មួយរបស់ភ្នាក់ងារ សម្ងាត់កណ្តាលសហរដ្ឋអាមេរិក និងរបបលន់ នល់ ដួលរលំក្នុងការធ្វើឲ្យមានការភ័ន្តច្រឡំបន្ទាប់ពីជ័យ ជម្នះរបស់យើង។ ផែនការនោះមានចំណុចបី៖ ១) ប្រសិនបើយើងពុំអាចដោះស្រាយបញ្ហាក្រពះរបស់ ប្រជាជនបាន ពួកវានឹងបង្កបញ្ហាដោយឲ្យភ្នាក់ងារជ្រៀតចូលក្នុងចំណោមប្រជាជន។ ២) ទាហាន លន់ នល់ ភាគច្រើនដែលគ្រវីទង់ជ័យ-ស តាមការពិតពួកវាបានលាក់អាវុធទុក។ ពួកវាមានចេតនាវាយយើង ក្រោយរំដោះភ្នំពេញរួច។ ៣) ពួកវាមានផែនការធ្វើឲ្យកងទ័ពយើងពុករលួយ ធ្វើឲ្យស្មារតីតស៊ូពួកយើង ចុះខ្សោយ ដោយយកស្រី ស្រា និងមាសប្រាក់មកបំពុល។ សំណួរបន្ត៖ តើភ្នំពេញដែលគ្មានមនុស្សនៅ ឬ? លោក អៀង សារី បានឆ្លើយថា៖ ទេ មានប្រជាជនប្រហែល១០០.០០០នាក់បានវិលត្រឡប់ចូល មកវិញ។ ហើយប្រជាជនផ្សេងទៀតកំពុងវិលចូលមកភ្នំពេញជាបណ្តើរៗ សាលារៀន មន្ទីរពេទ្យ និង រោងចក្របានចាប់បើកទ្វារធ្វើសកម្មភាពវិញជាបណ្តើរៗហើយ។ ប្រជាជនអាចត្រឡប់ចូលភ្នំពេញវិញ ប្រសិនណាបើពួកគេចង់ ឬក៏ពួកគេអាចស្នាក់នៅជនបទ។ ប្រជាជនយើងទាំងអស់គ្នាកំពុងធ្វើការទាំង ថ្ងៃទាំងយប់ដើម្បីកសាងប្រទេសឡើងវិញ។ ប្រទេសកម្ពុជាដូចជារោងជាងធំមួយ”។

[១១:១៥:០៥]

ចុះក្រោមបន្តិចនៅក្នុងអត្ថបទនោះ គឺប្រហែលជាប្រាំ ប្រាំមួយសំណួរនៅខាងក្រោម គេសួរ

សំណួរលោក អៀង សារី ដូចតទៅនេះ៖

“សួរ៖ តើរដ្ឋាភិបាលរបស់លោកគោរពព្រះពុទ្ធសាសនា ដែលជាសាសនារបស់កម្ពុជាដែរឬទេ? លោក អៀង សារី ឆ្លើយថា៖ យើងគោរពជំនឿសាសនារបស់មនុស្សគ្រប់គ្នា។ ប្រជាជនមានសិទ្ធិជឿ ប៉ុន្តែពួកគេត្រូវគោរពច្បាប់រដ្ឋ។ វត្តអារាមនៅកម្ពុជាមិនមានបិទទេ។ សំណួរបន្ត៖ តើមានអ្វីកើតឡើង ចំពោះមន្ត្រីនៃរបបលន់ នល់? ចម្លើយ៖ សព្វថ្ងៃពួកគេចូលរួមក្នុងការបង្កបង្កើនផលកសិកម្ម។ យើងនឹង អបអរសាទរពួកគេ ប្រសិនណាបើពួកគេស្មោះត្រង់ ហើយពួកគេអាចចូលរួមក្នុងជីវភាពជាតិកម្ពុជា របស់យើង។ ក្នុងរបប -- ក្នុងរដ្ឋបាលរបស់យើង យើងប្រើប្រស់មនុស្សពីរបបមុនទាំងឡាយណាដែល ស្មោះត្រង់។ សំណួរ៖ តើអតីតប្រធានាធិបតី ឡុង បូរ៉េត នៅរស់ ឬស្លាប់? ចម្លើយ៖ ស្លាប់ ឬរស់គាត់ គឺជាជនក្បត់ ហើយត្រូវបានកាត់ទោសដោយប្រជាជននិងសភា”។

[១១:១៦:១៨]

ខ្ញុំសូមបញ្ចប់អត្ថបទនេះ ហើយយើងបន្តទៅប្រធានបទមួយទៀត និយាយអំពីគណៈអចិន្ត្រៃយ៍ គឺជាកំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍ ហើយឯកសារនេះមាននៅក្នុងសំណុំរឿង។ កំណត់ហេតុ កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ទី១ គឺចុះថ្ងៃ០៩ ខែ១០ ឆ្នាំ១៩៧៥។ ប៉ុន្តែមុនពេលដែលខ្ញុំចាប់ផ្ដើមពិភាក្សានៅ លើឯកសារនេះ ខ្ញុំចង់ឲ្យអង្គជំនុំជម្រះពិនិត្យមើលទៅលើចម្លើយរបស់ ខៀវ សំផន E3/27។ នៅក្នុង ចម្លើយនោះ ខ្មែរមានលេខ 00156619 ហើយភាសាអង់គ្លេសមានលេខ 00156750។ លោក ខៀវ សំផន បានបញ្ជាក់ដូចតទៅនេះ “ជាគោលការណ៍អង្គការដែលសំខាន់ជាងគេ គឺគណៈកម្មាធិការមជ្ឈិម ប៉ុន្តែជាក់ស្តែងគឺគណៈកម្មាធិការអចិន្ត្រៃយ៍។ យើងអាចប្រៀបប្រដូចវាជាបន្តបន្ទាប់ទៅនឹងសភាជាតិ និងរដ្ឋាភិបាលនៅក្នុងរបបសភានិយម គឺរដ្ឋាភិបាលជាអ្នកកាន់អំណាចពិតប្រាកដ”។

នៅក្នុងទំព័រដដែលនេះ គឺនៅចុងខាងក្រោម ខ្មែរមានលេខ 00156619 លោក ខៀវ សំផន បាននិយាយអំពីការប្រជុំរបស់គណៈអចិន្ត្រៃយ៍ ហើយការនិយាយនេះគឺវាមានសារៈសំខាន់ដោយសារវា បញ្ជាក់អំពីតួនាទីរបស់ អៀង សារី, នួន ជា ហើយនិងតួនាទីរបស់ ខៀវ សំផន ផងដែរ។ គាត់បាន និយាយថា “គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិម ធ្វើការប្រជុំជារៀងរាល់៦ខែម្តង ចាប់ពីឆ្នាំ១៩៧០មក។ គណៈកម្មាធិការអចិន្ត្រៃយ៍ជួបប្រជុំទៀងទាត់ប្រហែលជា៧ទៅ១០ថ្ងៃម្តង ឬញឹកញាប់ជាងនេះក្នុង ករណីបន្ទាន់”។

[១១:១៨:៥០]

លោក លោកស្រីចៅក្រម! នៅក្នុងសំណុំរឿងរបស់យើងគឺមានកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមចំនួន១៩កំណត់ហេតុ។ ដូច្នេះ ប្រសិនបើប្រជុំ៧ទៅ១០ថ្ងៃក្នុងរយៈពេល៣ឆ្នាំ តើវាយ៉ាងដូចម្ដេចដែរ? ប៉ុន្តែក្នុងចំណោមកំណត់ហេតុដែលយើងទទួលបាន គឺយើងសូមពិនិត្យមើលតែលេខឯកសារ E3/27 គឺឯកសារ E3/182 គឺជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដែលយើងមាននៅក្នុងសំណុំរឿង។ នៅក្នុងឯកសារនោះមិនបានកត់ត្រាថាអ្នកណាបានចូលរួមវត្តមាននៅក្នុងការប្រជុំនោះទេ។ ប៉ុន្តែ វាជាកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដ៏សំខាន់ ដោយបានបញ្ជាក់អំពីតួនាទីរបស់លោក អៀង សារី និងជនជាប់ចោទដទៃទៀត។

ឥឡូវនេះយើងមើលពិនិត្យខ្មែរមានលេខ 0019108 ហើយភាសាអង់គ្លេសមាន 00183393។ យើងឃើញថា ការបែងចែកការងារ គឺបានបញ្ជាក់ទៅតាមលំដាប់លំដោយពីលេខ១ ដល់លេខ១៣។ ទី១ គឺសមមិត្តលេខា ទទួលរួមយោធា និងសេដ្ឋកិច្ច។ ទី២ គឺសមមិត្តអនុលេខា ការងារបក្ស សង្គមកិច្ច វប្បធម៌ ឃោសនាការ និងសិក្សាធិការ។ ទី៣ គឺសមមិត្ត វ៉ាន់ ការងារបរទេស ទាំងបក្សទាំងរដ្ឋ"។

ឯកសារបានបង្ហាញជារួមនូវការរាយរៀបរាប់អំពីសមាជិកគណៈអចិន្ត្រៃយ៍ ហើយគេធ្វើទៅតាមលំដាប់លំដោយចាប់ពី ប៉ុល ពត មក នួន ជា បន្តទៅ អៀង សារី។ ហើយយើងសូមបញ្ជាក់ថា នេះគឺជាការសំខាន់ទាក់ទងទៅនឹងការយល់ដឹងអំពីឋានានុក្រមរបស់សមាជិក ហើយឯកសារនេះក៏មានលក្ខណៈសំខាន់ចំពោះការយល់អំពីកំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍នានា ដែលបញ្ជាក់អំពីតួនាទីរបស់ អៀង សារី ទោះបីថាគាត់ទទួលខុសត្រូវទាំងការងារបក្ស ទាំងការងារបរទេស ទាំងបក្សទាំងរដ្ឋ។

[១១:២១:៣២]

សារៈសំខាន់មួយទៀត ទាក់ទងទៅនឹងកំណត់ហេតុការប្រជុំមួយនេះ គឺការសំខាន់ក្នុងការបែងចែកតួនាទីរបស់សមាជិកបក្សកុម្មុយនីស្តកម្ពុជាក្នុងដឹកនាំប្រទេស។ ហេតុដូច្នេះខ្ញុំសូមជម្រាបថា វាជាការចង្អុលបង្ហាញអំពីសារៈសំខាន់របស់គណៈអចិន្ត្រៃយ៍នៅក្នុងរបបនោះ។ ជាពិសេស ការបែងចែកអំណាចនៅក្នុងបក្សកុម្មុយនីស្ត ដើម្បីបង្ហាញអំពីការដឹកនាំប្រទេស ក៏ដូចជាដឹកនាំបក្ស។

ប្រសិនបើយើងមើលទំព័រ៣ជាភាសាខ្មែរ យើងក៏ឃើញនៅក្នុងកំណត់ហេតុនេះបានបញ្ជាក់ផងដែរថា សមាជិកគណៈអចិន្ត្រៃយ៍ គឺជាផ្នែកដ៏សំខាន់នៅក្នុងបក្សកុម្មុយនីស្តកម្ពុជានៅពេលនោះ។ ប្រសិនបើយើងមើលខ្មែរមានលេខ 000191090 (ស៊ីក), អង់គ្លេសមានលេខ 00183394 គឺបានបញ្ជាក់ថា "បុគ្គលនីមួយៗ គឺមិនគ្រប់គ្រាន់នោះឡើយ គឺយើងត្រូវឲ្យមានសមាជិកទាំងអស់ចូលរួមជាមួយគ្នា។

បើធ្វើយ៉ាងនេះបានវាជាកម្លាំងធំ បើយើងភ្លេច យើងភ្លាំងគេអាចចាត់ចែងជំនួសបាន។ ក្នុងការលើកគម្រោងត្រូវសួរយោបល់អចិន្ត្រៃយ៍ដើម្បីសម្រេច និងអនុម័ត ត្រូវជៀសវាងនិន្នាការ”។

[១១:២៣:១៤]

នៅទំព័របន្ទាប់គឺបានបញ្ជាក់ថា “សួរតែអចិន្ត្រៃយ៍ បើធ្វើយ៉ាងនេះមិនមានប្រជាធិបតេយ្យប្រមូលផ្តុំទេ។ គណៈអចិន្ត្រៃយ៍វត់មិនរួចទេ បើមកទាំងដុល។ ធ្វើតែនាម ធ្វើតែតាមផ្នែកនីមួយមិនសួរអចិន្ត្រៃយ៍ នេះក៏ជាការខុសឆ្គង។ ដូច្នេះបានជាត្រូវដោះស្រាយដោយយកសេចក្តីសម្រេចរបស់បក្សទៅអនុវត្ត តាមដាន តម្រែតម្រង់ឲ្យល្អ។ ដើម្បីសម្គាល់ថា យើងអនុវត្តបានល្អ ឬមិនល្អ គឺនៅត្រង់មហាជនទទួលបាន ឬមិនបាន។

ចុះក្រោយបន្តិច គឺនិយាយអំពីអំណាចរបស់គណៈអចិន្ត្រៃយ៍ ដោយធ្វើការ -- ដោយបង្ហាញនៅក្នុងឯកសារ 00019111 ដល់ 12 បានបញ្ជាក់ថា “ត្រូវតែមានជំនាញ ការធ្វើរបាយការណ៍ត្រូវតែច្បាស់អ្វីៗ សួរអីដឹងហ្នឹង ពីការសម្រេចរបស់មជ្ឈិម របស់អចិន្ត្រៃយ៍ ឯកសារប្រជុំថ្ងៃណា ខែ ត្រូវធ្វើយ៉ាងណាឲ្យច្បាស់។ បើកំណត់ហេតុមិនច្បាស់នាំពិបាកមើលសាជាថ្មី។ បើធ្វើអ៊ីចឹងបានវាសម្រាលច្រើន។ ឥឡូវការងារនៅតិចទេ ប៉ុន្តែ១ឆ្នាំ ២ឆ្នាំទៀតការងារកាន់តែច្រើន ដូចជាការងារសេដ្ឋកិច្ចជាដើម។ ការងារបរទេសក៏អ៊ីចឹង។ តាំងពីទូរលេខឡើងទៅពេលទទួលបានភ្លាមមន្ទីរត្រូវប្រគល់ឲ្យផ្នែកទទួលខុសត្រូវភ្លាម ឲ្យគេពិនិត្យ ពិចារណា ហើយស្នើអចិន្ត្រៃយ៍ បញ្ហាខ្លះត្រូវប្រញាប់។ បញ្ហាយោធាឲ្យខាងយោធា បញ្ហាពាណិជ្ជកម្មឲ្យពាណិជ្ជកម្ម បញ្ហាបក្សឲ្យផ្នែកបក្ស។ ដូច្នេះបើទៅជិតគ្នា យើងស្រួលប្រមូលកម្លាំងធ្វើការ”។

[១១:២៥:៣៣]

នៅទំព័រ 00019112 គឺបានបញ្ជាក់ថា “ពេលអចិន្ត្រៃយ៍ប្រជុំ ម្នាក់ៗរាយការណ៍។ កន្លងមកការងារប្រមូលមកសមមិត្ត ឌឿន ទាំងអស់។ ថ្ងៃក្រោយត្រូវឲ្យទៅផ្នែកនីមួយៗគេគិត ឧទាហរណ៍ការងារបរទេស ថ្ងៃក្រោយត្រូវគិតទាំងអស់។ យើងមិនចង់ឲ្យការងារប្រមូលមកអចិន្ត្រៃយ៍។ មន្ទីរអចិន្ត្រៃយ៍ទាក់ទងពីផ្នែកមួយទៅផ្នែកមួយ។ អចិន្ត្រៃយ៍តាមដានផ្នែកនីមួយៗក្នុងការអនុវត្តមាគ៌ា។ ខាងមន្ទីរមានភារកិច្ចតាមដានការអនុវត្ត”។

ការណ៍ទាំងអស់នេះបានបង្ហាញអំពីអំណាចខ្ពស់បំផុតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយវាជារបស់សមាជិកគណៈអចិន្ត្រៃយ៍។ ហើយនៅក្នុងកិច្ចប្រជុំនេះដដែល ក៏មានការពិភាក្សានូវឯកសារ

00019121 ដល់ 22 "ក្នុងការប្រជុំត្រូវតែប្រុងប្រយ័ត្ន ប្រសិនបើយើងប្រើពាក្យ ជនក្បត់ គឺមានន័យថា វាធ្ងន់ធ្ងរហើយ គឺយើងត្រូវតែរកឲ្យឃើញខ្មាំង ហើយយើងត្រូវតែយល់ដឹងអំពីការងារនេះឲ្យបានច្បាស់ បញ្ហាបក្សពេលខ្លះវាធ្ងន់ធ្ងរ ដែលនាំទៅដល់បញ្ហាដែលមិនអាចអប់រំសាជាថ្មីបាន។ បញ្ហាដែលត្រូវផ្សព្វផ្សាយ គឺថាសមាជិកបក្សនៅក្នុងអង្គការ"។

[១១:២៧:១៩]

ហើយអានេះគឺជាអ្វីដែលគេនិយាយអំពីសមាជិជាក់លាក់ ហើយខ្ញុំសូមដកស្រង់ អង់គ្លេសមាន 00183404។ ខ្ញុំសូមបញ្ជាក់ថា ឯកសារនេះសំខាន់ ដោយសារតែនៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ជាពិសេសកិច្ចប្រជុំមួយនេះ គឺបានពិភាក្សាអំពីខ្មាំង និងជនក្បត់។ ហើយខ្មាំង និងជនក្បត់គឺជាផ្នែកនៃការប្រជុំនេះ ហើយអ្នកដែលចូលរួមនៅទីនេះនឹងដឹងអំពីការពិភាក្សា ហើយនិងយល់អំពីលក្ខណៈរបស់ពាក្យថា "ជនក្បត់" និង "ខ្មាំង" នេះ។

មុនពេលដែលខ្ញុំបន្តទៅកំណត់ត្រាកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ដទៃទៀត ខ្ញុំគិតថានៅក្នុងសំណុំរឿង គឺមានឯកសារចំនួន១៩។ ប្រសិនបើយើងពិនិត្យមើលទៅលើឯកសារនៅក្នុងសំណុំរឿង យើងឃើញថា លោក អៀង សារី បានចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់ អ៎! ហើយចូលរួមយ៉ាងតិចបំផុតក៏១0នៅក្នុងកិច្ចប្រជុំនោះដែរ។ ហើយ ខៀវ សំផន បាននិយាយថា កិច្ចប្រជុំប្រហែលជា៧ ទៅ១0ថ្ងៃម្តង បានបញ្ជាក់ដូច្នេះ។ ប៉ុន្តែយើងមិនបានប្រមូលនូវកំណត់ហេតុនៃកិច្ចប្រជុំទាំងអស់បាននោះទេ។

[១១:២៨:៤២]

ក្នុងកំណត់ហេតុនៃកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដែលបានចូលរួមដោយលោក អៀង សារី គឺនៅថ្ងៃ ០២ ខែ១១ ឆ្នាំ៧៥ គឺឯកសារ E3/227 ថ្ងៃ២២ ខែ០២ ឆ្នាំ៧៦។ ទី៣ គឺ E2/229 ដែលពិភាក្សាអំពីបញ្ហាការពារជាតិ ហើយទី៣ គឺ ២៦ ខែ០២ ឆ្នាំ៧៦។ ឯកសារ E3/230 នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ៧៦ គឺឯកសារ E3/231 ថ្ងៃ១១ ខែ -- ឯកសារ E3/233 និង E3/234 និងថ្ងៃទី០៣ ខែ៥ ឆ្នាំ៧៦ E3/2។ ថ្ងៃ ១៤ ខែ៥ ឆ្នាំ៧៦ E3/221។

ខ្ញុំនឹងលើកយកកំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ចំនួនបួន មកពិភាក្សា ហើយកំណត់ហេតុនេះគឺនិយាយអំពីគោលនយោបាយការបរទេស គឺនិយាយអំពីប្រទេសដែលគាំទ្រពេញលេញដល់ប្រទេសកម្ពុជា និងប្រទេសដែលគាំទ្រមួយផ្នែកទៅដល់ប្រទេសកម្ពុជា ក៏ដូចជានិយាយអំពីជំនួយបរទេស។ ប្រសិនបើយើងមើលឯកសារ E3/227 គឺឯកសារថ្ងៃ០២ ខែវិច្ឆិកា ឆ្នាំ៧៥ ខ្មែរមានលេខ 00019127។

ប្រសិនបើយើងមើលទំព័រទី១នៃកំណត់ហេតុនោះ គឺយើងឃើញការចូលរួមប្រជុំអចិន្ត្រៃយ៍ ហើយយើងឃើញនៅលើអេក្រង់ គឺមានការចូលរួមដោយសមមិត្តប៉ុល, ទី២ សមមិត្តនួន, ទី៣ សមមិត្តវ៉ាន់។ ហើយក្នុងកំណត់ហេតុការប្រជុំនេះ គឺនិយាយអំពីបញ្ហាថៃនិងវៀតណាម គឺជាការពិភាក្សាអំពីការគំរាមកំហែងដែលវៀតណាមនិងថៃ អាចបង្កមកប្រទេសកម្ពុជា។

[១១:៣១:២៣]

ដូច្នេះបញ្ហាសំខាន់ គឺពាក់ព័ន្ធទៅនឹងសន្តិសុខជាតិដែលបានលើកពិភាក្សាក្នុងកិច្ចប្រជុំទាំងអស់នោះ។ នៅពេលនេះសូមមើលឯកសារ E3/230 គឺកំណត់ហេតុគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី២២ ខែកុម្ភៈ ៧៦។ ខ្មែរលេខ 00000711 ហើយប្រសិនបើយើងមើលកិច្ចប្រជុំនេះ គឺយើងឃើញថា "ប៉ុល ពត នៅដំបូងគេ, នួន ជា ទី២ បន្ទាប់មកអៀង សារី ដាក់បន្ទាប់ពីនេះ គឺទី៣"។ នៅក្រោមហ្នឹងបន្តិច "កិច្ចប្រជុំបានកត់ត្រាទុកសមាសភាពសមមិត្តវ៉ន, សមមិត្តឌុច និងសមមិត្តវ៉ាន់ បានលើកបញ្ហាមួយចំនួន -- សមមិត្តធុច និងសមមិត្តវ៉ាន់ បានលើបញ្ហាមួយចំនួនទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម ដឹកជញ្ជូន និងបញ្ហាយូហ្គោស្លាវី ហើយក៏បាននិយាយអំពីផលិតផលអំបិល...។ល។"

នៅក្នុងកិច្ចប្រជុំនេះ នៅក្នុងចំណុច៥ ខ្មែរលេខ 00000712 នៅក្នុងចំណុចទី៥ លើកឡើងថា "បញ្ហាបន្ថែមកម្លាំង ស្នើឲ្យសុំយកកុមារជំទង់ៗពីមូលដ្ឋានបន្ថែម។ លើកយកមកធ្វើការងារនៅឧស្សាហកម្មចាត់ចែង"។ នៅក្នុងកិច្ចប្រជុំនេះ គឺវាបានបង្ហាញច្បាស់ថាតួនាទីរបស់ អៀង សារី អនុញ្ញាតឲ្យគាត់លើកបញ្ហាមួយចំនួន គឺបញ្ហាសំខាន់ៗ ហើយគាត់មានវត្តមាននៅក្នុងពេលពិភាក្សាពាក់ព័ន្ធទៅនឹងការយកកុមារយកមកធ្វើការងារបន្ថែម។

[១១:៣៣:២០]

ប្រសិនបើយើងមើលថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ៧៦, ៦ថ្ងៃក្រោយមក គឺឯកសារE3/238 យើងឃើញថាកិច្ចប្រជុំនោះ អៀង សារី គឺបានធ្វើរបាយការណ៍គឺដាក់សរសេរថា "សេចក្តីរាយការណ៍របស់សមមិត្តវ៉ាន់" ដែលក្នុងនោះគាត់និយាយអំពីជំនួយពីប្រទេសស្វីស -- ប្រទេសស៊ុយអែត។ ជំនួយរបស់ស៊ុយអែត ហើយក៏និយាយអំពីបញ្ហាជំនួយយូហ្គោលស្លាវីផងដែរ។ នៅក្នុងកិច្ចប្រជុំ គឺចុងក្រោយនៃកិច្ចប្រជុំបានលើកឡើងថា "និយាយអំពីមតិយោបល់របស់អង្គការ"។ ហើយក្នុងនោះបានបង្ហាញនូវទស្សនៈជាក់លាក់តែម្តងនៅចុងបញ្ចប់នៃរបាយការណ៍។ នៅចំណុច(ខ) ខ្មែរលេខ 00072459, បារាំង 00446631 មតិរបស់អង្គការគឺបានលើកឡើងដូចតទៅ "ខាងយោធា និងសេដ្ឋកិច្ចក៏ឃើញថាគ្មានអ្វីមក

ឈ្លានពានយើងទេ គាត់ចងមិត្តក្នុងឃោធាដែរ ដូច្នេះពេលខ្លះទៅបញ្ហាភ្នាក់ងារនេះរដ្ឋាភិបាលមិនបានដឹងនោះទេ។ តែពិនិត្យនយោបាយរួមរបស់គេ គ្មានអ្វីទេ”។

[១១:៣៤:៤៧]

ជាថ្មីម្តងទៀត ការពិភាក្សាបញ្ហានៃបញ្ហាជនក្បត់ និងខ្មាំង គឺបានលើកយកពិភាក្សានៅក្នុងនេះផងដែរ។ ឯកសារចុងក្រោយមួយទៀត លោក លោកស្រីចៅក្រម គឺខ្ញុំលើកជាឧទាហរណ៍ថ្ងៃ១៧ ខែឧសភា ឆ្នាំ៧៦ ឯកសារចុះថ្ងៃ១៧ ខែឧសភា ឆ្នាំ៧៦ បារាំងមានលេខ 00323984 ឯកសារ E3/223 ខ្មែរមានលេខ 00000829, អង់គ្លេស 00182708 នៅក្នុងកិច្ចប្រជុំនេះ អៀង សារី បានរៀបរាប់អំពីសកម្មភាពរបស់ក្រសួងការបរទេសជូនទៅដល់ ប៉ុល ពត។ នេះយើងក៏អាចឃើញនៅក្នុងទំព័រដំបូងដែលបានសរសេរឡើងចំណុចទាំងអស់នេះ គាត់បានរាយការណ៍បន្ថែមនៅកថាខណ្ឌក្រោម គឺពាក់ព័ន្ធទៅនឹងកិច្ចប្រជុំ និងបញ្ហាសំខាន់ហើយនិងបញ្ហាប្រុងប្រយ័ត្ន គឺខាងយើងក៏បានអប់រំបងប្អូនឲ្យមានការប្រុងប្រយ័ត្ន និងបញ្ហាសំខាន់ៗដែលគាត់យកមកពិភាក្សានៅក្នុងនេះផងដែរ”។

[១១:៣៦:០៥]

នៅក្នុងកថាខណ្ឌទី៤ បន្ទាប់ការងារទូតនៅក្នុងទីក្រុងភ្នំពេញ យើងឃើញថា អៀង សារី គឺបានដាក់ឈ្មោះទី៣ នៅក្នុងកិច្ចប្រជុំនោះ ហើយគាត់បានពិភាក្សាអំពីបញ្ហាពាក់ព័ន្ធទៅនឹងការប្រុងប្រយ័ត្ន ហើយតាមសន្ទតនោះគឺគាត់បានលើកឡើងអំពីការប្រុងប្រយ័ត្នក្នុងការឲ្យរឹងមាំក្នុងការកសាងបដិវត្តន៍។ ប្រសិនយើងមើល 00182711 ជាភាសាអង់គ្លេស, បារាំង 00323896 យើងឃើញថា អៀង សារី បានរាយការណ៍ពាក់ព័ន្ធទៅនឹងស្ថានទូតនៅទីក្រុងភ្នំពេញ បន្តអប់រំយុទ្ធនារី យុទ្ធជន ដើម្បីឲ្យមានការប្រុងប្រយ័ត្នទៅលើបញ្ហាបដិវត្តន៍ ជាពិសេសបង្រៀនពួកគេឲ្យរាយការណ៍ដល់ក្រសួង ហើយក្រសួងនោះជាអ្នករាយការណ៍បន្តទៅមន្ទីរ។ ដូច្នេះវាបង្ហាញយ៉ាងច្បាស់ថា អៀង សារី បានលើកឡើងពិភាក្សាអំពីបញ្ហាពាក់ព័ន្ធទៅនឹងខ្មាំងនៅក្នុងកិច្ចប្រជុំទាំងអស់នេះ។

លោក លោកស្រីចៅក្រម នៅពេលនេះខ្ញុំបញ្ចប់ឯកសារពាក់ព័ន្ធទៅនឹងកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ហើយខ្ញុំសូមចូលប្រធានបទមួយទៀត គឺប្រធានបទពាក់ព័ន្ធទៅនឹងសារទូរលេខ។ ខ្ញុំ -- ក្រោយពីយើងពិនិត្យមើលកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ សារទូរលេខគឺជាប្រភេទឯកសារមួយទៀត ភស្តុតាងបានបង្ហាញឲ្យឃើញថា “អៀង សារី បាន -- ត្រូវបានគេចម្លងជូន” ហើយអ្វីដែលយើងគណនាពីសំណុំរឿងឃើញថា គេចម្លងជូនគាត់យ៉ាងហោចណាស់ ១០០ដង។ ដូច្នេះ ខ្ញុំសូម

បង្ហាញឯកសារ E3893 ឯកសារចុះថ្ងៃ០៦ មករា ឆ្នាំ៧៦។ ខ្ញុំសូមយោងកថាខណ្ឌទី១ ទី២ ដំបូងនៃសារទូរលេខនេះ ដែលក្នុងនោះពាក់ព័ន្ធទៅនឹង “ជម្រាបបង ម-៨៧០ និងបងវី ជាទីគោរព” ហើយបានសរសេរថា៖

[១១:៣៨:៣៣]

“យើងខ្ញុំសូមរាយការណ៍អំពីលទ្ធផលនៃការជួយវៀតណាមថ្ងៃ២៤ ខែ០១។ ប្រតិភូមានប្រាំមួយនាក់ ឈ្មោះ លីយ៉ាង អនុប្រធានគណៈកម្មាធិការយោធាភូមិភាគជាប្រធានប្រតិភូ គាត់នេះបញ្ជាក់ថា ឈ្មោះ ភូ ឈឺមិនបានមក តែតាមយើងខ្ញុំសន្និដ្ឋានពួកវាផ្លាស់ប្ដូរ ដោយយើងផ្លាស់ប្ដូរពីកម្មាភិបាលវរសេនាធំមកគណៈយោធាភាគ។ គាត់នេះៗចាស់ហើយស៊ីជម្រៅខ្លាំង”។

បន្ទាប់មកសារទូរលេខបានរៀបរាប់បញ្ហាពាក់ព័ន្ធទៅនឹងការលុកលុយនៅតាមព្រំដែនដោយវៀតណាម ហើយនិងការមិនឯកភាពគ្នា។ នៅក្នុងកថាខណ្ឌ៦ នៅចុងខាងក្រោយ ជិតចុងខាងក្រោយនៃសារទូរលេខ គឺខាងក្រោម គឺបានលើកឡើងថា “វាដាក់សម្ពាធខ្លាំងមកលើយើង ក៏ប៉ុន្តែយើងនៅតែរក្សាជំហររបស់យើងដដែល យើងជឿជាក់ដោយសារតែយើងមានអំណួតទៅលើពួកវា។ យើងរក្សាបរិយាកាសសាមគ្គីបាន យើងខ្ញុំប៉ាន់ប្រមាណថា យើងទទួលជោគជ័យជំហានដំបូងល្អបង្គួរ”។

នៅចុងបញ្ចប់នៃសារទូរលេខ គឺបានចម្លងជូនបង -- គឺ “ចម្លងជូន ប៉ុល ពត, នួន ជា, អៀង សារី, បងវី, បងខៀវ, បងខឿន។ បងខៀវ បានន័យថាជា សុន សេន។ ដូច្នេះវាបង្ហាញឲ្យយើងឃើញច្បាស់ថា សារទូរលេខនេះបង្ហាញឲ្យយើងឃើញថា អៀង សារី គឺគាត់បានដឹងអំពីបញ្ហាយោធាផងដែរ គឺគាត់បានដឹងយ៉ាងទៀងទាត់។ ដូច្នេះ ប្រសិនបើយើងមើលឯកសារសារទូរលេខមួយបន្ទាប់ទៀត គឺ E3/995 ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ៧៨ គឺក្រោយមក គឺថាជិតចុងបញ្ចប់កម្ពុជាប្រជាធិបតេយ្យ។ សារទូរលេខនេះមកពី “កង ចាប គោរពជូនគណៈ៨៧០” ហើយក្នុងនោះក៏បានចម្លងជូន អៀង សារី ផងដែរ។ ប្រសិនបើយើងមើលចំណុចចុងក្រោយ និងសរសេរថា “ចម្លងជូនបង”។ បងនេះ គឺថា ប៉ុល ពត, នួន ជា, អៀង សារី, បងវ៉ាន់ បងវន គឺសំដៅលើ វន វ៉េត ហើយនិងមន្ទីរ៨៧០។ សារទូរលេខនេះគឺជា និយាយអំពីស្ថានភាពខ្លាំងនៅក្នុងភូមិភាគ រួមទាំងការបោសសម្អាតផ្ទៃក្នុងនៅខាងភូមិភាគឧត្តរផងដែរ។

[១១:៤១:២៥]

កថាខណ្ឌដែលពាក់ព័ន្ធគឺនិយាយអំពីវិធីដែល អៀង សារី និងសមាជិកផ្សេងទៀតបានពិភាក្សា

អំពីការបោសសម្អាត។ ប្រសិនបើយើងមើលកថាខណ្ឌ 00019202 នេះគឺជាអ្វីដែលសារទូរលេខនោះបានលើកឡើង "ស្ថានភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង៖ នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើងនៅតាមការដ្ឋាន។ ពួកខ្មាំងដែលនៅសេសសល់ទាំងនេះវាទាក់ទងជាមួយពួកប៉ូលិស ទាហាន និងពួករដ្ឋការ។ ពួកទាំងនេះវាបន្តធ្វើប្រជាជនថ្មី ក្រោយពីវាធ្វើសកម្មភាពប្រឆាំងនឹងយើង ទើបយើងស្គាល់មុខវាច្បាស់។ ទន្ទឹមនឹងនេះ យើងក៏បានបោសសម្អាតវាជាខ្សែសង្វាក់។ មកដល់ថ្ងៃនេះ សភាពការណ៍ខ្មាំងបង្កប់ត្រូវស្ងប់ស្ងាត់។ ពួកទាហាន ប៉ូលិស និងរដ្ឋការមួយចំនួនត្រូវរត់បាត់។ ក្រោយពីយើងបោសសម្អាតចំនួនប្រមាណជាង២០ក្បាល។ យើងក៏មានវិធានការបន្តរកចាប់ពួកនេះតទៅទៀត។ ឯខ្មាំងបង្កប់នៅតំបន់ព្រះវិហារ ក្រោយពីយើងបានបោសសម្អាត និងកំពុងបោសសម្អាតតទៅទៀតនោះ ក៏គ្មាន"។

[១១:៤២:៥៧]

ឯកសារសារទូរលេខនេះបានចម្លងជូនឲ្យអៀង សារី និងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀត។ យើងខ្ញុំសូមលើកឡើងថា ឯកសារនេះវាពាក់ព័ន្ធមានតម្លៃជាភស្តុតាង។ ដូច្នេះឯកសារប្រភេទនេះគឺវាសំខាន់ ហើយវាបង្ហាញថា អៀង សារី បានចូលរួមក្នុងការផ្លាស់ប្តូរការ ដឹងឮរវាងគ្នា ហើយក្នុងពេលនោះ គឺកំណត់គោលដៅសំខាន់ទៅលើខ្មាំងផងដែរ។

សារទូរលេខចុងក្រោយគឺ E3/157 ដែលវាជាឧទាហរណ៍មួយខ្ញុំសូមបង្ហាញ។ ហើយសារទូរលេខនេះបញ្ជូនទៅ អៀង សារី E3/157 គឺឯកសារសារទូរលេខចុះថ្ងៃ២១ ខែមេសា គឺមកពីខាងភូមិភាគពាយ័ព្យ ចម្លងជូន អៀង សារី និយាយអំពីការប៉ះទង្គិចជាមួយនឹងវៀតណាម និងការសម្លាប់គិញ និងជនក្បត់ ជាពិសេសសារទូរលេខគឺបានជម្រាប អៀង សារី ថា "គឺគិញបានចូលមកតំបន់នោះពីរដង ហើយយើងបានវាយកម្ទេចវា ប៉ុន្តែអ្នកខ្លះរត់រួច។ ហើយជនក្បត់ត្រូវបានបោសសម្អាត ហើយយើងក៏បានដកអ្នកដែលទទួលខុសត្រូវនោះយ៉ាងជោគជ័យផងដែរ"។ នៅចុងបញ្ចប់នៃសារទូរលេខនេះ គឺយើងខ្ញុំសូមបញ្ជាក់ថា សារទូរលេខនេះមួយចំនួនទាំងអស់នេះ គឺយើងឃើញប្រហែលជាមួយ១០០ ឬក៏១០០ជាងនៅក្នុងសំណុំរឿង។ សារទូរលេខនេះបានបង្ហាញថា អៀង សារី មានតួនាទីជាអ្នកតាមដានក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ហើយនិងសមាជិកអចិន្ត្រៃយ៍។ ហើយក៏បានបង្ហាញអំពីសកម្មភាពរបស់សមាជិកគណៈអចិន្ត្រៃយ៍ ដែលក្នុងនោះបានបញ្ចូល អៀង សារី ហើយក៏បានលើកឡើង សារទូរលេខបានលើកឡើងអំពីការបោសសម្អាតខ្មាំង និងបុគ្គលដែលជាជនក្បត់នៅក្នុងប្រទេស។

[១១:៤៤:៥៦]

លោក លោកស្រីចៅក្រមជាទីគោរព! នៅពេលនេះគឺ ខ្ញុំសូមត្រឡប់ទៅមើលកាលប្បវត្តិកាលខែមីនា ឆ្នាំ៧៦ ដែលវាជាសេចក្ដីសម្រេច ឯកសារសេចក្ដីសម្រេច ឯកសារ E3/12 វាជាសេចក្ដីសម្រេចរបស់មជ្ឈិមចុះថ្ងៃទី៣០ មីនា ឆ្នាំ៧៦ ស្ដីអំពី "សិទ្ធិកម្ទេចនៅក្នុងនិងក្រៅជួរ"។

លោក លោកស្រីចៅក្រម សេចក្ដីសម្រេចនេះគឺស្រដៀងមុនដែរ នៅទំព័រដំបូងគឺបានលើកឡើងថា "សិទ្ធិកម្ទេចនៅក្នុងនិងក្រៅជួរ គឺមានក្របខ័ណ្ឌដាច់ខាតក្នុងការអនុវត្តបដិវត្តន៍របស់យើង គឺត្រូវពង្រឹងប្រជាធិបតេយ្យសង្គមនិយម ហើយនិងពង្រឹងអំណាចរដ្ឋរបស់យើង។ ប្រសិនបើនៅមូលដ្ឋានត្រូវសម្រេចដោយគណៈភូមិភាគ ជុំវិញមន្ទីរត្រូវសម្រេចដោយមជ្ឈិម តំបន់ឯករាជ្យត្រូវសម្រេចដោយអចិន្ត្រៃយ៍ ហើយកងទ័ពមជ្ឈិមត្រូវលេខាសម្រេច"។ នៅក្នុងឯកសារនេះ ត្រូវបានបង្ហាញអំពីគណៈអចិន្ត្រៃយ៍បានផ្ដល់អំណាចគណៈអចិន្ត្រៃយ៍ក្នុងការកម្ទេចនិងសម្លាប់ចោល។ អៀង សារី ពាក់ព័ន្ធទៅហ្នឹងតួនាទីរបស់អៀង សារី ឯកសារនេះវាពាក់ព័ន្ធយ៉ាងម៉េច គឺវាបង្ហាញថា អៀង សារី ជាសមាជិករបស់គណៈមជ្ឈិម ហើយក៏ជាសមាជិកនៅក្នុងគណៈអចិន្ត្រៃយ៍ផងដែរ។

[១១:៤៧:១៣]

លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមលើកឡើងដោយសង្ខេបឯកសារ E3/210 គឺជាសេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ គឺកំណត់ហេតុសួរចម្លើយ ខៀវ សំផន ត្រង់ទំព័រ ខ្មែរ 00156691, អង់គ្លេស 00156949។ ខៀវ សំផន បាននិយាយអំពីការបាត់ខ្លួន ហើយនិងតើនរណាជាអ្នកសម្រេចទៅលើការបាត់ខ្លួននេះ។ គាត់បានឆ្លើយថា "ពាក់ព័ន្ធទៅនឹងការប្រកាសអំពីស្វ័យទិតៀននោះ គឺយើងខ្ញុំសូមលើកឡើងថា កម្មាភិបាលមួយចំនួនយល់ឃើញថាសមស្របក្នុងការដាក់ទណ្ឌកម្មចំពោះបុគ្គលទាំងឡាយដែលខុសសីលធម៌ ហើយឲ្យសាធារណជនបានដឹង។ កំហុសទាំងអស់ត្រូវបានប្រកាស ហើយត្រូវបានកែតម្រូវ។ ពាក់ព័ន្ធនឹងបញ្ហាព្រះវិហារពិតជាមានមែន ប៉ុន្តែអ្នកទោសត្រូវដោះលែងវិញ។ មានការរំលោភបំពាននៅតាមមូលដ្ឋាន ប៉ុន្តែមិនមានការយល់ព្រមពីថ្នាក់ដឹកនាំនោះទេ។ ចុងបញ្ចប់ទាក់ទងទៅនឹងការបាត់ខ្លួននៃសមាជិកគណៈកម្មាធិការមជ្ឈិម និងអចិន្ត្រៃយ៍គ្រប់គ្នាហាក់ដូចជាយល់ស្រប ប៉ុន្តែខ្ញុំវិញ ខ្ញុំមិនដឹងអំពីទំហំរបស់វាទេ"។ ដូច្នេះឯកសារនេះ បានបង្ហាញថាវាមានតម្លៃជាភស្តុតាង យើងខ្ញុំសូមលើកឡើងដូច្នេះ។ ហើយវាបង្ហាញអំពីពាក់ព័ន្ធនឹងសេចក្ដីសម្រេចរបស់មជ្ឈិមក្នុងការកម្ទេច និងបោសសម្អាតផងដែរ។

[១១:៤៨:៥២]

លោក លោកស្រីចៅក្រម ឯកសារជាក់លាក់ទាំងអស់នេះបានបង្ហាញឲ្យឃើញថា អៀង សារី-- បានបង្ហាញឲ្យឃើញតួនាទីរបស់លោក អៀង សារី នៅក្នុងគោលនយោបាយបោសសម្អាតមួយចំនួន។ ចំណុចមួយទៀតដែលខ្ញុំមិនបានលើកឡើង គឺនៅក្នុងការស្ដាប់ចម្លើយ ខៀវ សំផន នោះគឺឯកសារ E3/210 គេបានសួរ ខៀវ សំផន អំពីសេចក្ដីថ្លែងការណ៍ ឬសុន្ទរកថា ហើយគាត់បានឆ្លើយថា "ខ្ញុំសូមបញ្ជាក់ថា សុន្ទរកថាដែលខ្ញុំលើកឡើងនៅកូឡុំបូ គឺសរសេរដោយលោក អៀង សារី មកឲ្យខ្ញុំ។ ក្នុងពេលទស្សនកិច្ច នួន ជា, វន វេត នៅប៉េកាំងនោះគឺ មានសុន្ទរកថាសរសេរឡើងដោយ អៀង សារី"។

ខ្ញុំសូមលើកឡើងអំពី ហ៊ូ យន់ ហើយនិង ដែលបានលើកឡើងអំពីបញ្ហានេះនៅក្នុងឆ្នាំ១៩៧៩។ ឯកសារ 00156689។ ដូច្នេះឯកសារមួយនេះគឺជាបានបង្ហាញអំពីតួបន្ថែមរបស់ អៀង សារី ក្នុងពេលនោះ ក្នុងនាទីរបស់គាត់សរសេរសុន្ទរកថាសម្រាប់មេដឹកនាំ ឬក៏សមាជិកជាន់ខ្ពស់ដទៃទៀតនៅក្នុងបក្ស។

លោក លោកស្រីចៅក្រមជាទីគោរព នៅពេលនេះខ្ញុំសូមត្រឡប់ទៅឯកសារដដែល គឺឯកសារថ្ងៃ០៥ តុលា ៧៦។ គឺខ្ញុំសូមនិយាយអំពីឯកសារមួយបណ្ដុំទៀតពាក់ព័ន្ធទៅនឹងសុន្ទរកថាថ្លែងឡើងដោយ អៀង សារី។ ថ្លែងទៅដល់មហាសន្និបាតនៃអង្គការសហប្រជាជាតិ ឯកសារដែលខ្ញុំលើកឡើងនេះ គឺ E3/607 គឺចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ៧៦។ អ្វីដែលចាប់អារម្មណ៍ចំពោះសុន្ទរកថាមួយនេះ គឺសុន្ទរកថាបានថ្លែងឡើងដោយ អៀង សារី ខ្ញុំលើកឯកសារនេះជាឧទាហរណ៍ គឺឯកសារហ្នឹងបង្ហាញអំពីពាក្យពេចន៍ដែលមានសរសេរនៅក្នុងលក្ខន្តិកៈផងដែរ ហើយដែលក្នុងនេះនិយាយអំពីសាមគ្គីភាពជាមួយនឹងប្រទេសមិនចូលបក្សសម្ព័ន្ធផ្សេងទៀត។ ហើយមានការខឹងសម្បានៅក្នុងចំណោមប្រទេសមូលធន និងប្រទេសចក្រពត្តិ។ ហើយសូម្បីនៅក្នុងសេចក្ដីថ្លែងការណ៍សុន្ទរកថាជាសាធារណៈលោក អៀង សារី មានភាពក្លាហានណាស់ ខ្ញុំគួរតែនិយាយដូច្នេះ ដែលគាត់ហាននិយាយអំពីបញ្ហាពាក់ព័ន្ធនឹងខ្មាំង។

[១១:៥១:៤៩]

ខ្ញុំសូមឲ្យលោក លោកស្រីចៅក្រមមើលឯកសារ 00816624 ជាភាសាខ្មែរ និង 00586884 ជាភាសាអង់គ្លេស។ គាត់បានលើកឡើងនៅក្នុងសុន្ទរកថារបស់គាត់ថា "យើងបាន -- ដោយសារហេតុផលនេះហើយ យើងបានទទួលជោគជ័យភ្លាមៗ និងរំដោះប្រជាជនយើង។ សន្តិសុខមានគ្រប់នៅទិសទីនៅទូទាំងប្រទេស ប៉ុន្តែបទពិសោធន៍យើងខ្ញុំផ្ទាល់ និងបទពិសោធន៍បដិវត្តន៍ដទៃទៀតនៅលើពិភពលោកបង្រៀនយើងខ្ញុំថា ក្រោយពីបរាជ័យពួកចក្រពត្តិអាមេរិក បរិវារ និងកម្លាំងប្រតិកិរិយាដទៃទៀតនៅតែ

បន្តវាយប្រហារប្រទេសរបស់យើង ប្រជាជនយើង។ ដោយសារតែមិនអាច ឬលំបាកក្នុងការវាយប្រហារយើងខ្ញុំជាចំហពីខាងក្រៅ ពួកវាខិតខំប្រមែប្រមូលកាកសំណល់កម្លាំងក្បត់ដើម្បីបង្កសកម្មភាពវិទ្ធង្សនា បង្ករឿង បំបែកបំបាក់ និងបំផ្លិចបំផ្លាញ នៅប្រទេសយើងខ្ញុំ និងដើម្បីជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់យើងខ្ញុំ។

[១១:៥៣:០០]

ដោយសារស្មារតីប្រយ័ត្នបដិវត្តន៍ជាប់ជានិច្ច និងការរួបរួមគ្នាយ៉ាងស្អិតល្មួតជាតិ ប្រជាជន និងកងទ័ព យើងខ្ញុំបានវាយពួកវាឲ្យទទួលរង និងបរាជ័យយ៉ាងធ្ងន់ធ្ងរ។ ប៉ុន្តែដោយមានចរិតល្ពានពាន និងងងឹតងងុលដោយមហិច្ឆតាហួសប្រមាណ ពួកចក្រពត្តិអាមេរិកបរិវារ និងកម្លាំងប្រតិកិរិយាដទៃទៀតមិនចេះចាំមេរៀនពីបរាជ័យរបស់ខ្លួននោះទេ។ ហើយវានៅតែចចេសបន្តសកម្មភាពឧក្រិដ្ឋរបស់ខ្លួន។ ច្បាស់ណាស់ថា ប្រជាជន និងកងទ័ពបដិវត្តន៍យើងខ្ញុំបានវាយពួកវាឲ្យបរាជ័យយ៉ាងអាម៉ាស់ជាថ្មីទៀតដោយឯករាជ្យម្ចាស់ការ"។

លោក លោកស្រីចៅក្រម សុន្ទរកថានេះជាសុន្ទរកថាជាសាធារណៈថ្លែងជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិ។ ខ្ញុំសូមលើកឡើងថា ឯកសារនេះមានតម្លៃជាភស្តុតាង ហើយវាបានឆ្លុះបញ្ចាំងយ៉ាងជាក់ស្តែងអំពីតើមានអ្វីកើតឡើងនៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ តើមានអ្វីកើតឡើងនៅក្នុងការធ្វើទំនាក់ទំនងជាមួយនឹងកងកម្លាំងនៅក្រៅ នៅទូទាំងប្រទេសកម្ពុជា តាមរយៈសារទូរលេខហើយក៏បានលើកឡើងអំពីការបោសសម្អាត និងការសម្លាប់ខ្មាំងបង្កប់ផ្ទៃក្នុង។

[១១:៥៤:២៤]

សុន្ទរកថាជាសាធារណៈនេះ និងសេចក្តីថ្លែងការណ៍ ឯកសារមុនៗ សារទូរលេខ កំណត់ហេតុទាំងឡាយដែលខ្ញុំលើកឡើងនេះ គឺស៊ីសង្វាក់នឹងគ្នា ហើយវាមានភាពពាក់ព័ន្ធ។

លោក លោកស្រីចៅក្រមជាទីគោរព ខ្ញុំនៅពេលនេះ សូមចូលទៅដល់ឯកសារមួយក្រុមទៀត គឺឯកសារនេះពាក់ព័ន្ធទៅនឹងឯកសារលេខ -- ខ្ញុំមិនមានលេខ -- គឺឯកសារនេះមានលេខ D366/7.1.820 ចុះថ្ងៃ២០ ខែកញ្ញា ឆ្នាំ១៩៧៨ ខ្ញុំមិនមានលេខឯកសារជាលេខ E នោះទេ។ ឯកសារនេះមិនមានលេខ E ទេ ហើយខ្ញុំបានពិនិត្យមើលសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងឧបសម្ព័ន្ធដែលសហព្រះរាជអាជ្ញាបានដាក់ជូនឯកសារមួយនេះ។ ជាការពិតមិនមានការជំទាស់នៅក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនោះទេ។ ឯកសារ២០ទៅ៣០ ដែលត្រូវបានបដិសេធតាមរយៈសេចក្តីសម្រេចរបស់

អង្គជំនុំជម្រះ។ ឯកសារមួយនេះ គឺយើងខ្ញុំបានធ្វើការស្វែងរក ហើយឃើញថាវាមិនមានលេខសម្គាល់នោះទេ។ ដូច្នេះខ្ញុំមិនលើកឡើងថា ឯកសារនេះមាន E ប៉ុន្មាននោះទេ ប៉ុន្តែមានលេខ D366/7.1.820។ ដូច្នេះឲ្យមន្ត្រីដែលកាន់កាប់សំណុំរឿងនោះ ធ្វើការពិនិត្យផង ហេតុអ្វីមិនដាក់លេខ E លេខសម្គាល់ E។

[១១:៥៦:១៧]

នេះជាសារទូលេខបញ្ជូនពី អៀង សារី គឺបានបញ្ជូនអនុគណៈកម្មការប្រឆាំងនឹងវិធានការរើសអើងការពារជនជាតិភាគតិច ដែលវាពាក់ព័ន្ធទៅនឹងគណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ឯកសារនេះចុះថ្ងៃ១៦ ខែមេសា ឆ្នាំ៧៨ ពីរដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ។ អនុគណៈកម្មការប្រឆាំងនឹងការវិធានការរើសអើង និងការពារជនជាតិភាគតិច គឺយើងឃើញថាបានលើកឡើងអំពីសមាជិកផងដែរ។ នៅក្នុងសារទូលេខគឺឯកសាររបស់អង្គការសហប្រជាជាតិ អៀង សារី បានលើកឡើងដូចតទៅ “យើងសូមធ្វើការច្រានចោលនូវសេចក្តីសម្រេចរបស់អនុគណៈកម្មការ ដែលសេចក្តីសម្រេចជាការលូកដៃចូលដោយឥតអៀនខ្មាសនៅក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ។ តាមរយៈសេចក្តីសម្រេចនេះ អនុគណៈកម្មការធ្វើការគាំទ្រសកម្មភាពរបស់ពពួកជនក្បត់ជាតិ ហើយឧបាយកលរបស់ចក្រពត្តិនិយមអាមេរិក និងបក្សពួករបស់ខ្លួន ដែលពួកនេះក្រោយពីបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មដ៏សែនធំធេងមកលើប្រជាជនកម្ពុជា បានសម្លាប់រង្គាលប្រជាជនកម្ពុជាអស់ជាង១លាននាក់ ហើយដែលបំផ្លាញប្រទេសកម្ពុជាអស់ជាងពាក់កណ្តាលប្រទេស បានបន្តធ្វើការបង្កាច់បង្ខូចកម្ពុជាប្រជាធិប-តេយ្យ ដើម្បីលាងសម្អាតខ្លួនពីឧក្រិដ្ឋកម្មដែលពួកគេបានប្រព្រឹត្ត។ បច្ចុប្បន្ននេះប្រជាជនកម្ពុជាដែលបង្រួបបង្រួមគ្នា បានក្លាយជាម្ចាស់លើជោគវាសនារបស់ខ្លួន ហើយក្រោយបានខិតខំប្រឹងប្រែងអស់រយៈពេល៣ឆ្នាំមក ប្រជាជនយើងបានដោះស្រាយបញ្ហាសំខាន់ មានស្បៀងអាហារគ្រប់គ្រាន់ កសាង និងការពារប្រទេសដោយរក្សាបាននូវឯករាជ្យ និងអធិបតេយ្យភាពពេញលេញ ហើយពឹងផ្អែកលើកម្លាំងខ្លួនផ្ទាល់ ដោយមិនពឹងផ្អែកលើចក្រពត្តិនិយមណាមួយឡើយ។ ដូចកាលពីពេលមុនប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានធ្វើឲ្យបរាជ័យនូវឧបាយកលទាំងឡាយរបស់ចក្រពត្តិនិយម ព្រមទាំងបរិវាររបស់ខ្លួន។ ពួកគេមិនអាចលើកឡើងបានចំពោះរាល់ទង្វើទាំងឡាយដែលបះពាល់ដល់អធិបតេយ្យភាពរបស់កម្ពុជានោះទេ។ រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ៧៨”។

[១១:៥៨:៤១]

លោក លោកស្រីចៅក្រមជាទីគោរព សេចក្តីថ្លែងការណ៍មួយនេះ គឺឆ្លើយតបទៅនឹង ខ្ញុំនឹងអានលេខយោងដើម្បីឲ្យយើងយល់ទាំងគ្នា គឺឆ្លើយតបទៅនឹងសេចក្តីសម្រេចលេខ១១ លេខ៣១ ដែលឯកសារហ្នឹងអនុម័តក្នុងសម័យប្រជុំលើកទី២៦ កាលពីថ្ងៃ១៥ ខែកញ្ញា ឆ្នាំ១៩៧៨។ អនុគណៈកម្មការប្រឆាំងទៅនឹងវិធានការរើសអើង និងការពារជនជាតិភាគតិច បានសម្រេចស្នើសុំដល់ប្រធាន ឬសមាជិកណាមួយថា ប្រធានអនុគណៈកម្មការមានបំណងចង់ធ្វើការចាត់តាំង ធ្វើការវិភាគក្នុងនាមអនុគណៈកម្មការនូវផ្នែកឯកសារពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាប្រជាធិបតេយ្យ ដែលអនុគណៈកម្មការបានទទួលពាក្យបណ្តឹងស្របតាមសេចក្តីសម្រេចលេខ៩, ៣៤ របស់គណៈកម្មការសិទ្ធិមនុស្ស ដែលដូចជាបទអត្ថាធិប្បាយ បទសង្កេតរបស់អនុគណៈកម្មការ និងឯកសារសមហេតុសមផលដទៃទៀត ដែលអគ្គលេខាធិការអាចទទួលបានមុនសម័យប្រជុំលើកទី៣៥ របស់គណៈកម្មការ និងបង្ហាញនូវអត្ថបទវិភាគនេះទៅកាន់គណៈកម្មការ ដោយស្នើសុំឲ្យគណៈកម្មការធ្វើការសម្រេចចាត់ទុកបញ្ហានេះជាចំណុចអាទិភាពបំផុតសម្រាប់ការពិភាក្សាក្នុងសម័យប្រជុំលើកទី៣៥ របស់ខ្លួន។

[១១:៥៩:៥៨]

ឯកសារនេះគឺបង្ហាញយ៉ាងច្បាស់ថា បានបង្ហាញអំពីការ -- លើកអំពីការខឹងសម្បានៅក្នុងអង្គការសហប្រជាជាតិ ហើយក៏បានលើកឡើងអំពីបញ្ហារំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាខែកញ្ញា ឆ្នាំ៧៨។ ឥរិយាបថដែលបានបង្ហាញនៅក្នុងលិខិតនេះបានបង្ហាញឲ្យឃើញថា វាមានភាពធំធេងឲ្យយើងយល់អំពីតួនាទីរបស់ អៀង សារី ក្នុងរបប -- នៅក្នុងប្រទេសនេះនាសម័យនោះ។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះ ដែលពាក់ព័ន្ធនឹងប្រធានបទដែលអង្គជំនុំជម្រះបានកំណត់ឲ្យសម្រាប់ធ្វើសវនាការនាពេលនេះ។

សុំកុំអាលទាន់! សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ ហេតុផលដែលខ្ញុំងើបឈរឡើងនៅពេលនេះ គឺដោយសារតែបទបង្ហាញទៅលើឯកសារគន្លឹះដែលយើងបានស្តាប់ពីព្រឹកមិញនេះ គឺបង្ហាញដោយតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។ យើងមានកាតព្វកិច្ចត្រូវបង្ហាញនូវការកោតសរសើរចំពោះការបង្ហាញរបស់លោក ស្មីត ដែលមានលក្ខណៈល្អ ផ្តល់នូវព័ត៌មានលម្អិតនៅក្នុងសារណាបញ្ចប់របស់ខាងតំណាងសហព្រះរាជអាជ្ញា។

[១៣:៣៤:៥២]

ចំពោះយើង យើងយល់ច្បាស់ថាការបង្ហាញនេះ គឺវាមាន គឺថាលោក ស្មីត បានប្រើប្រាស់នូវភាសាមួយចំនួន ដូចជាពាក្យថា “សំខាន់ ឬក៏សំខាន់ផ្នែកភស្តុតាង” ឬប្រើពាក្យ “បង្ហាញ” ឬក៏ ហើយពេលខ្លះគាត់ប្រើពាក្យថា “យើងសូមស្នើ” ឬក៏ “សូមបញ្ជាក់” ដែលធ្វើឲ្យសវនាការនេះវាមានលក្ខណៈប្រែប្រួលពីការបង្ហាញឯកសារ ទៅដូចជាទៅជាការដាក់សារណាបញ្ចប់ការពិភាក្សាដេញដោលទៅវិញ។ ដូច្នេះ តាមគំនិតរបស់យើង គឺថាវាផ្ទុយពីអ្វីដែល វេយ៍ន័រ បានធ្វើពីសប្តាហ៍មុន គឺវាមានលក្ខណៈជាការផ្តោតតែទៅលើឯកសារតែប៉ុណ្ណោះ។ ទាក់ទងទៅនឹងទឡ្ហីករណ៍ដែលសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងកាលពីព្រឹកមិញ ក៏ដូចជាសារណាដែលរូបគាត់បានលើកឡើងពីព្រឹកមិញនេះ យើងភ្ញាក់ផ្អើលដោយសារតែការណ៍នេះបង្ហាញថា ដូចថាសវនាការនេះវាមានសារៈសំខាន់ខ្លាំងទាល់តែមែនទែន។

តាមពិតទៅលោកប្រធាន យើងយល់ឃើញថា អង្គជំនុំជម្រះទទួលស្គាល់អំពីសារៈសំខាន់នៃសវនាការនេះ ហើយជាពិសេសគឺសារៈសំខាន់នៃវត្តមានរបស់ជនជាប់ចោទ ដែលថាត្រូវឲ្យមានការបង្ហាញនូវវត្តមាន នៅទីនេះ ជាពិសេសនៅពេលដែលទាក់ទងនឹងលោក ខៀវ សំផន នៅពេលដែលមានការបទបង្ហាញទាក់ទងទៅនឹងតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងយល់ស្រប

ទាំងស្រុង ហើយយើងគិតថាវត្តមានរបស់កូនក្តីខ្ញុំនៅក្នុងផ្នែកដែលធ្វើបទបង្ហាញ ទាក់ទងទៅនឹងតួនាទីរបស់គាត់នៅក្នុងសម័យខ្មែរក្រហមនោះ គឺជាការមួយដ៏សំខាន់បំផុត។

[១៣:៣៧:០០]

អង្គជំនុំជម្រះប្រហែលជាកត់សម្គាល់ឃើញដែរថាលោក សុន អរុណ មិនមានវត្តមានវត្តមានទេនៅពេលនេះ ដោយសារគាត់ធ្វើដំណើរទៅមន្ទីរពេទ្យខ្មែរ-សូវៀត ដើម្បីជួបជាមួយលោក នួន ជា។ ដោយសារតែលក្ខណៈនៃបទបង្ហាញដែលបានធ្វើឡើងក្នុងថ្ងៃនេះ ដូច្នេះយើងរួមគ្នាដាក់អនុស្សរណៈ ដើម្បីបង្ហាញថាលោក នួន ជា បានដកចេញនូវការលះបង់សិទ្ធិរបស់គាត់វិញ ទាក់ទងទៅនឹងឯកសារនេះ។

នៅពេលដែលឯកសារ ឬក៏បទបង្ហាញពីឯកសារ គឺនិយាយអំពីតួនាទីរបស់លោកនួន ជា នៅក្នុងសម័យខ្មែរក្រហម។ ដូច្នេះគាត់សុំដកមកវិញនូវការលះបង់សិទ្ធិរបស់គាត់។ លោក សុន អរុណ គឺមានឱកាសបានទៅជួបជាមួយកូនក្តីរបស់យើង ហើយយើងសង្ឃឹមថាលោក នួន ជា នឹងអាចផ្តល់នូវការណែនាំដើម្បីប្រាប់យើងទាក់ទងទៅនឹងការធ្វើសវនាការលើឯកសារនេះ។

[១៣:៣៨:០១]

ហើយពាក់ព័ន្ធទៅនឹងបញ្ហានេះដែរ ខ្ញុំសូមធ្វើការកត់សម្គាល់ផងដែរថា ខ្ញុំ និងលោក សុន អរុណ ប្រហែលជាមានឱកាស គឺថាកាលពីម្សិលមិញយើងមានឱកាសបានទៅជួបកូនក្តីរបស់យើង។ យើងមិនត្រឹមតែមានបញ្ហានោះទេ ប៉ុន្តែយើងថែមទាំងរន្ធត់ នៅពេលដែលយើងឃើញស្ថានភាពសុខភាពរបស់គាត់គឺមានការធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរ គឺធៀបជាមួយនឹងថ្ងៃ២៦ ខែមករា គឺថ្ងៃសុក្រនេះ។

នៅពេល -- ការណ៍ដែលយើងបង្ហាញនូវការភ្ញាក់ផ្អើលនេះ គឺថា កាលពីម្សិលមិញអង្គជំនុំជម្រះកាលពីម្សិលមិញយើងបានជម្រាបទៅអង្គជំនុំជម្រះថា សុខភាពរបស់គាត់បានប្រសើរ គឺយើងធ្វើការជម្រាបហ្នឹង ដោយសារតែយើងផ្អែកទៅលើរបាយការណ៍មន្ទីរពេទ្យដែលយើងបានទទួល គឺរបាយ-ការណ៍ទទួលពីព្រឹកម្សិលមិញនេះ។ ដូច្នេះហើយគឺថា ព័ត៌មាននៅក្នុងរបាយការណ៍នោះគឺវាមិនបានឆ្លុះបញ្ចាំងអំពីអ្វីដែលបានកើតឡើងចំពោះកូនក្តីខ្ញុំនៅពេលរសៀលនោះឡើយ។ ខ្ញុំមិនគួរលើកយកបញ្ហានេះនិយាយជាសាធារណៈនោះទេ។ ដូច្នេះ -- ហើយក្រុមគ្រួសារលោក នួន ជា គាត់ហាក់ដូចជាជឿជាក់ថាលោក នួន ជា ជិតស្លាប់ទៅហើយ។ ដូច្នេះក្នុងការផ្តល់នូវការដកចេញនូវការលះបង់សិទ្ធិរបស់គាត់នោះគឺវាជាការបង្ហាញ។

លោកប្រធាន យើងសង្ឃឹមថា យើងនឹងទទួលបានព័ត៌មានថ្មីៗនៅពេលរសៀលនេះ ហើយយើង

នឹងជម្រាបដល់អង្គជំនុំជម្រះតាមលទ្ធភាពដែលយើងអាចទទួលទៅបាន។ សូមអរគុណលោកប្រធាន។

[១៣:៣៩:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ជាការឆ្លើយតបដោយសង្ខេប ខាងព្រះរាជអាជ្ញាមិនមានចេតនាធ្វើសវនាការបញ្ចប់ការពិភាក្សាការដេញដោលនៅពេលនេះទេ។ អ្វីដែលយើងធ្វើគឺថាដើម្បីផ្តល់នូវព័ត៌មានទាក់ទងទៅនឹងតម្លៃភស្តុតាងនៃឯកសារ។ ប្រសិនបើក្នុងពេលណាមួយដែលខ្ញុំធ្វើលើសពីអ្វីដែលខ្ញុំគ្រោងនឹងធ្វើ ខ្ញុំមិន-- ខ្ញុំចង់បញ្ជាក់ថា ខ្ញុំមិនមានចេតនានោះទេ។ ខ្ញុំចង់បង្ហាញអំពីតម្លៃភស្តុតាងនៃឯកសារនេះ។ គឺថាខ្ញុំមិនមានចេតនាដើម្បីធ្វើសារណាបញ្ចប់ការពិភាក្សាការដេញដោលនោះទេ។ ប្រសិនបើខ្ញុំធ្វើដោយអចេតនា ខ្ញុំសូមអភ័យទោស។

[១៣:៤១:១០]

លោក លោកស្រីចៅក្រមជាទីគោរព! មុនពេលដែលយើងឈប់សម្រាកអាហារថ្ងៃត្រង់ យើងបានពិនិត្យមើលទៅលើសុន្ទរកថារបស់លោក អៀង សារី ក៏ដូចជាឯកសារនានា ដែលបានបញ្ជូនទៅគណៈកម្មការសិទ្ធិមនុស្ស បញ្ជូនទៅអនុគណៈកម្មការការពារ និងរារាំងការធ្វើបាបចំពោះជនជាតិភាគតិច នៅពេលនោះលោក អៀង សារី ដែលជារដ្ឋមន្ត្រីក្រសួងការបរទេសបានបង្ហាញ បានធ្វើការពារចំពោះការដែលមានរបាយការណ៍ថាប្រទេសកម្ពុជានៅសម័យនោះបានរំលោភទៅលើសិទ្ធិមនុស្ស។ ឯកសារដែលយើងពិនិត្យមើលគឺនៅថ្ងៃទី២០ ខែ៩ ឆ្នាំ៧៨ ហើយយើងនឹងពិនិត្យទៅលើឯកសារមួយទៀត E3/1337 គឺជាទូរលេខរបស់ក្រសួងការពារជាតិ -- របស់ក្រសួងការបរទេស ផ្ញើជូនអនុគណៈកម្មការការពារសិទ្ធិមនុស្ស ដែលបានស្នើសុំឲ្យមានការស៊ើបអង្កេតដោយរដ្ឋាភិបាលប្រទេសអង់គ្លេសទៅលើឧក្រិដ្ឋកម្មដែលបានកើតឡើងនៅប្រទេសកម្ពុជានៅពេលនោះ។

[១៣:៤២:៣៨]

ឯកសារគឺថ្ងៃ៣០ ខែមិថុនា នៅពេលដែលអង្គការសហប្រជាជាតិបានបញ្ជូននូវលិខិតមួយដែលនិយាយអំពីឯកសាររបស់ គឺឯកសារអង់គ្លេសមានលេខ 00235721, ខ្មែរមានលេខ 0033905, បារាំងមានលេខ 00235729។ ឯកសារនេះ គឺនិយាយអំពីការរំលោភសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។

ជាពិសេសគឺនៅក្នុងផ្នែកនានានៃពិភពលោក ហើយជាពិសេសគឺនិយាយទៅលើប្រទេសដែលស្ថិតនៅក្រោមអាណានិគម។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានទទួលនូវលិខិតមួយពីក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យចុះថ្ងៃទី២២ មេសា ៧៨ ដែលមានសំណើសុំថាឲ្យអង្គការសហប្រជាជាតិចែក ធ្វើការផ្សព្វផ្សាយឯកសារផ្លូវការទៅដល់ស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ និងប្រទេសជាសមាជិកទាំងអស់។ ខ្លឹមសារនៃការបញ្ជូនរបស់ក្រសួងការបរទេសបានដាក់បញ្ចូលនៅក្នុងឯកសារនេះផងដែរ។ ខ្ញុំនឹងមិនអានទាំងស្រុងទៅលើខ្លឹមសារនោះទេ ប៉ុន្តែខ្ញុំនឹងដកស្រង់នូវផ្នែកសំខាន់ៗមួយចំនួនដែលបញ្ជាក់អំពីតួនាទីរបស់លោក អៀង សារី ជាពិសេសនៅក្នុងឆ្នាំនោះតែម្តង។

[១៣:៤៤:១៣]

នៅក្នុងកថាខណ្ឌទី២ បាននិយាយថា "ជាពិសេសគឺប្រព័ន្ធផ្សព្វផ្សាយបានលើកឡើងថាការធ្វើឡើងប្រឆាំងនឹងប្រទេសកម្ពុជា និងប្រជាជនកម្ពុជា គឺមិនមែនជាការភ្ញាក់ផ្អើល ហើយក៏មិនមែនជាអ្វីដែលធ្វើឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមានការភ្ញាក់ផ្អើលនោះឡើយ។ ពួកចក្រពត្តិ ពួកអាណានិគមបានព្យាយាមធ្វើយុទ្ធនាការមួយដើម្បីធ្វើឡើងប្រឆាំងនឹងប្រជាជនកម្ពុជា។ នៅពេលនោះ ពួកគេមិនត្រឹមតែធ្វើការវាយប្រហារផ្នែកពាក្យសម្តីប៉ុណ្ណោះទេ ពួកគេថែមទាំងធ្វើការវាយសង្គ្រុប ក៏ដូចជាការធ្វើការគាបសង្កត់ទៅលើប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជាផងដែរ។

ការផ្សព្វផ្សាយនេះបានបន្តទៅដល់កថាខណ្ឌទី៦ ដែលក្រសួងការបរទេសបានបញ្ជាក់ថា "អ្វីដែលរដ្ឋាភិបាលប្រទេសអង់គ្លេសបានគិត គឺថាវាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការប៉ះពាល់ទៅដល់អំពើមនុស្សធម៌។ ក្នុងការពិតជាក់ស្តែងរដ្ឋាភិបាលរបស់ប្រទេសអង់គ្លេសបានតំណាងឲ្យចក្រពត្តិ ហើយនិងពួកអាណានិគមអង់គ្លេស ដែលគេចាត់ទុកថាជាពួកចក្រពត្តិ ឬក៏ពួកអាណានិគមដែលមានឥទ្ធិពលខ្លាំងនៅក្នុងពិភពលោក។ ពួកនោះគឺមានលក្ខណៈមិនផ្លាស់ប្តូរ ពួកគេនៅតែមានលក្ខណៈកាចសាហាវ និងឃោរឃៅជាទីបំផុត។ ពួកគេបានធ្វើការផ្លាស់ប្តូរតិចតួចបំផុត ពីព្រោះថាពួកគេមានអំណាចគ្រប់គ្រាន់ដើម្បីគ្របសង្កត់ទៅលើកម្លាំងដែលប្រឆាំងនឹងពួកគេ"។

[១៣:៤៦:០៨]

ព័ត៌មានបានបន្តនៅកថាខណ្ឌទី៨ ដែលបានបញ្ជាក់ថា "រដ្ឋាភិបាលអង់គ្លេស ក៏ដូចជាចក្រភពអង់គ្លេសបាននិយាយថា តើខ្ញុំធ្វើយ៉ាងណាដើម្បីជួយដល់ប្រជាជនកម្ពុជាឲ្យលើសពីប្រជាជនអង់គ្លេស? ពួកគេប្រើប្រាស់ហេតុផលក្នុងលក្ខណៈជាពួកចក្រពត្តិ ពួកអាណានិគម ហើយនិងប្រទេសអង់គ្លេស

ព្យាយាមជ្រៀតជ្រែកចូលទៅក្នុងកិច្ចផ្ទៃក្នុងរបស់ប្រទេសកម្ពុជា។ ប្រជាជន និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សូមថ្កោលទោសទៅដល់ការព្យាយាមជ្រៀតជ្រែកយ៉ាងឯងើលរបស់រដ្ឋាភិបាលអង់គ្លេស ដែលធ្វើឲ្យប៉ះពាល់ដល់កិត្តិយស និងកិត្តិសព្ទរបស់ប្រជាជនកម្ពុជា ក៏ដូចជាអធិបតេយ្យភាពនៃកម្ពុជាប្រជាធិបតេយ្យ"។

ហើយបន្តទៀតនៅកថាខណ្ឌទី១០ រដ្ឋ -- ក្រសួងបានបញ្ជាក់ថា "ក្នុងរយៈពេល៣ឆ្នាំកន្លងមកនេះប្រជាជនកម្ពុជាបានកម្ទេចសកម្មភាពជ្រៀតជ្រែករបស់ពួកចក្រពត្តិ ក៏ដូចជាសកម្មភាពរបស់ពួកឈ្លានពានវាទីនិយម ហើយក៏បានកម្ទេចនូវចេតនាក្នុងការផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រជាជនកម្ពុជាបានការពារក៏ដូចជាពង្រឹង និងពង្រីក ហើយបានកម្ទេចចោលនូវអំណាចដែលមានចេតនាបំផ្លាញប្រទេសកម្ពុជា។ កងទ័ពរំដោះប្រជាជនកម្ពុជា ក៏បានតទល់ប្រឆាំងជាមួយនឹងពួកសត្រូវឈ្លានពាន ដើម្បីការពារអធិបតេយ្យភាពក៏ដូចជាដែនដីកម្ពុជា"។

[១៣:៤៨:០០]

នៅក្នុងកថាខណ្ឌទី១១ "មានការរីកចម្រើនក្នុងការកសាងសង្គមថ្មីមួយ ដែលជាសង្គមសមូហភាពដោយមានការចូលរួមពីប្រជាជនជារួម។ ទំនាក់ទំនងរវាងការផលិត ហើយនិងការ -- ត្រូវបាន -- គុណ -- គឺយើងផ្អែកទៅលើគុណភាពនៃសង្គមនិយមសមូហភាព។ ហើយក្នុងពេលនេះប្រទេសកម្ពុជាប្រជាធិបតេយ្យមិនមែនជាប្រទេសដែលមានលក្ខណៈអាណានិគមនិយម ឬក៏វាទីនិយម ប៉ុន្តែយើងទទួលផលពីការងាររបស់កម្មករ កសិករ ហើយអតីតកម្មករ កសិកររបស់របបមុនក៏បានរស់នៅជាមួយយើងក្នុងលក្ខណៈដូចជាប្រជាជនរបស់យើងដែរ គឺផ្អែកទៅលើមូលដ្ឋានស្មើគ្នានៃសមូហភាព។ យើងបានការពារប្រទេសយើងដោយជោគជ័យ។ ខ្ញុំរីករាយក្នុងការចូលរួមក្នុងការកសាងសង្គមថ្មីមួយ ដោយសារតែយើងបានកសាងមាគ៌ាមួយសម្រាប់ប្រជាជនទាំងអស់។ ប្រជាជនទាំងអស់ស្មើភាពគ្នា ហើយមិនមានការគាបសង្កត់ ឬក៏កែងប្រវ័ញ្ចនោះឡើយ។ ប្រជាជនដាំដុះនៅក្នុងវាលស្រែ ហើយកម្មករធ្វើការនៅក្នុងរោងចក្រ។ យើងទទួលបាននូវផលដែលជាកម្លាំងញើសឈាមរបស់ប្រជាន ហើយផលនិងបានទៅដល់ប្រជាជនមិនមែនបានទៅដល់អ្នកដទៃនោះឡើយ"។

[១៣:៤៩:៤៩]

ឥឡូវនេះ យើងបន្តទៅកថាខណ្ឌទី១៣ ខ្មែរមានលេខ 00333917, និងភាសាបារាំងមានលេខ 00235726, អង់គ្លេសមាន 00235727 គឺជាឯកសាររបស់ក្រសួងការបរទេសដដែល ដែលបាន

និយាយថា "ក្នុងការបែងចែកកម្លាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានកំណត់នូវគោលនយោបាយយ៉ាងល្អ ហើយធ្វើការបែងចែកច្បាស់រវាងកម្លាំងស្លូល ហើយនិងកម្លាំងប្រយុទ្ធ។ យើងដឹងច្បាស់ថា គឺថាពាក្យនៅក្នុងសរសេរមិនច្បាស់ គឺធ្វើការប្រយុទ្ធប្រឆាំងក្នុងការកម្ទេច ហើយនិងប្រមូលផ្តុំគ្នា។ ក៏ប៉ុន្តែនៅពេលដែលយើងដោះស្រាយជាមួយនឹងជនក្បត់មួយចំនួន ភ្នាក់ងាររបស់ពួកចក្រពត្តិ ពួកអាណានិគមនិយមដែលព្យាយាមកម្ទេចប្រទេសកម្ពុជាយើង ក៏ដូចជាកម្ទេចប្រជាជននិងបដិវត្តន៍របស់យើង រដ្ឋាភិបាលត្រូវតែប្រើប្រាស់នូវអំណាចផ្តាច់ការ ផ្តាច់មុឺងម៉ាត់ និងតឹងរ៉ឹង ដើម្បីកម្ទេចពួកនេះ"។

[១៣:៥១:១២]

ហើយនៅក្នុងកថាខណ្ឌ -- ហេតុដូច្នេះហើយគឺរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាអង្គការ គឺថាតម្រូវឲ្យមានការលុបបំបាត់ចោលនូវអាណានិគមនិយម ក៏ដូចជាពួកចក្រពត្តិនិយម ហើយត្រូវគាំទ្រដល់ប្រទេសកម្ពុជា។ ហេតុដូច្នេះត្រូវតែប្រឆាំងជាមួយនឹងរដ្ឋាភិបាលអង់គ្លេស ដែលបានព្យាយាមធ្វើការរិះគន់ទៅដល់រដ្ឋាភិបាលកម្ពុជា។ គឺថាអង្គការសហប្រជាជាតិត្រូវតែគាំទ្រដល់ប្រទេសកម្ពុជា ក៏ដូចជាប្រជាជនកម្ពុជា ដើម្បីកសាងសង្គមថ្មីមួយដែលមានការរីកចម្រើន ដោយប្រជាជននិងប្រជាជន ហើយមាន -- ទី៤ ប្រសិនបើមិនមានសេរីភាពនោះទេ នៅក្នុងរបបកម្ពុជាថ្មីនឹងត្រូវបានគេកេងប្រវ័ញ្ច ហើយលិខិត -- ហើយជាការបំផ្លាញរបបសង្គមនិយមថ្មីនេះទៀត។

លោកប្រធាន ឯកសារមួយនេះគឺជាការផ្តល់ព័ត៌មាន អាចនឹងជួយក៏ដូច អាចជួយផ្តល់ព័ត៌មាន ក៏ដូចជាការផ្តល់ការពន្យល់អំពីតួនាទីរបស់លោក អៀង សារី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៣:៥២:៣៥]

លោកប្រធាន ឥឡូវនេះខ្ញុំសូមលើកយកនូវឯកសារ ដែលយើងបាននិយាយអំពីក្រសួងការបរទេស ហើយនិងផ្តល់នូវព័ត៌មានលម្អិតអំពីអ្វីដែលបានកើតឡើងនៅក្នុងក្រសួងការបរទេស។ ទោះបីថាឯកសារហ្នឹងត្រូវបានគេផ្សព្វផ្សាយជាសាធារណៈទៅខាងក្រៅក៏ដោយ។ ខ្ញុំសូមលើកយកនូវឯកសារ E3/522 ហើយឯកសារនេះមានចំណងជើងថា "កំណត់ត្រារបស់ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ" ហើយវាត្រូវបានរកឃើញ។ វាជាឯកសារអនាមិក ដែលបានរកឃើញនៅក្នុងឆ្នាំ៧៩ មានទំព័រលេខ 0003239 (ស៊ីក) ភាសាអង់គ្លេស។ ដោយនិយាយថាកម្ពុជា -- នៅពេលដែលត្រឡប់មកពីជនបទ គឺប្រជាជនបានរកឃើញនូវឯកសារមួយចំនួនដែលរបស់លោក អៀង សារី។ ឯកសារនេះគឺមិនមានបញ្ជាក់ឈ្មោះអ្នកនិពន្ធ ឬអ្នកសរសេរនោះឡើយ។ ប៉ុន្តែនៅក្នុងនោះមានបញ្ជាក់ឈ្មោះរបស់លោក

អៀង សារី ថាឈ្មោះ វ៉ាន់ ដែលបញ្ជាក់ក្នុងឱកាសមួយចំនួន។ ឯកសារនេះគឺនិយាយថ្ងៃ២១ ឧសភា ៧៦ ដល់ថ្ងៃទី០៥ មករា ឆ្នាំ៧៩។ វាជាឯកសារសរសេរដៃ ហើយឯកសារនេះភាគច្រើនគឺសរសេរកាត់។ មានចំនួន១៥២ទំព័រ ជាទំព័រសងខាង វាជាសៀវភៅទិនានុលេខន៍ ដែលបោះពុម្ពនៅក្នុងរបបលន់ នល់។

[១៣:៥៤:៣០]

ចំណុចទី១ គឺនៅថ្ងៃ០៧ មករា ឆ្នាំ១៩៧៦ ហើយឯកសារចុងក្រោយគឺនៅថ្ងៃទី០៥ មករា ៧៩ ដែលជាពេលដួលរលំ។ ឯកសារនេះគឺនិយាយអំពីការប្រជុំដែលបានធ្វើឡើងនៅក្រសួងការបរទេស ក៏ដូចជាសមាជ ក៏ដូចមហាសន្និបាតនានាដែលបានធ្វើឡើង។ ឯកសារនេះបានបង្ហាញនូវបរិយាកាសនៅក្នុងក្រសួងការបរទេសនៅពេលនោះក៏ដូចជាបាននិយាយអំពីតួនាទីដែលលោក អៀង សារី បានបំពេញនៅក្នុងក្រសួង។ ជាការគួរឲ្យចាប់អារម្មណ៍មួយនៅក្នុងទំព័រភាសាអង់គ្លេសមានលេខ 00003243 គឺការបកប្រែកំណត់ត្រាបានបកប្រែដូចតទៅនេះ គឺព័ត៌មានទាក់ទងទៅនឹងលក្ខន្តិកៈរបស់បក្ស ហើយវាបានឆ្លុះបញ្ចាំងអំពីអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល។

នៅភាសាអង់គ្លេសមានលេខ 00003247 យើងឃើញថាចំណងជើងនៃទំព័រនោះបាននិយាយអំពីសមាជផ្ទាល់ខ្លួន នៅខែឧសភា ឆ្នាំ៧៦ គឺជារបាយការណ៍សអំពីក្រសួងការបរទេស ហើយនៅចុងទំព័រនោះគឺបានបញ្ជាក់ថា “បង -- គំនិតរបស់ បងវ៉ាន់”។ ហើយវាបាននិយាយថារបាយការណ៍ធ្វើឡើងហ្នឹងគឺមានលក្ខណៈល្អ ហើយយើងអាចរៀនសូត្រពីបទពិសោធន៍ដោយខ្លួនឯង។

[១៣:៥៦:២០]

ប្រសិនបើយើងមើលនៅទំព័រខ្មែរ 00427830 ដល់ 33, អង់គ្លេសមានលេខ 00003254 គឺមានការកត់ត្រានូវមតិយោបល់ដូចតទៅ “សត្រូវនៃកម្ពុជាយើង ដៃជើងពួកក្បត់ដែលជាបរិវារ ពួកចក្រពត្តិ ពួកសេរីរើដែលបង្កប់ធ្វើសកម្មភាពសម្ងាត់។ យកដំណឹងពីយើង បង្វែរមាគ៌ា បំបះបំបោរផ្ទៃក្នុងសតិអារម្មណ៍ កម្មសិទ្ធិឯកជន ជាសត្រូវរបស់បដិវត្តន៍”។

ហើយនៅលេខ 00328482 គឺជាការកត់ត្រាមួយដែលបង្ហាញពីការពិតទាក់ទងទៅនឹងការជម្លៀសប្រជាជន។ ហើយការសរសេរបានបញ្ជាក់ដូចតទៅនេះ “ពាក់ព័ន្ធទៅនឹងការដកប្រជាជន គឺថាមានពេលណាមួយយើងនឹងអនុញ្ញាតឲ្យប្រជាជនត្រឡប់មកប្រទេស -- មកទីក្រុងវិញ”។ ការណ៍នេះគឺបង្ហាញថា យើងយល់អំពីយុទ្ធសាស្ត្រ អាចសួរថាហេតុអ្វីបានយើងមានគំនិតបែបនេះ។ យើងឆ្លើយថា

ព្រោះថាយើងមិនដែលអនុវត្តការណ៍នេះពីមុន គឺការជម្លៀសប្រជាជនចេញពីទីក្រុងទៅជនបទ។ បញ្ហាដែលខ្ញុំយល់ឃើញ គឺថាដោយសារតែបញ្ហានៃការផ្គត់ផ្គង់ស្បៀងអាហារ និងជម្រក។

ខ្មែរមានលេខ 00427872 ហើយចុះក្រោមបន្តិចគឺបានបញ្ជាក់ថា "ដោយសារតែយើងបានរក្សានូវសមិទ្ធិផលបដិវត្តន៍ដោយការផ្ទេរ ឬការជម្លៀសប្រជាជនចេញនោះ យើងគិតថាលុយកាក់គឺជាធនធានដ៏ធំ ប៉ុន្តែយើងមិនប្រើប្រាស់លុយកាក់នោះឡើយ។

[១៣:៥៨:២១]

ឥឡូវនេះយើងមើលទៅលើលេខ 00003216, 004378 (ស៊ីក) យើងមានចំណងជើងមួយដែលនិយាយថា និយាយពីសមមិត្ត ឆែម តើ--

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំឲ្យតំណាងសហព្រះរាជអាជ្ញាគាត់ធ្វើការអានឲ្យបានយឺតបន្តិច។

**លោក វីល្លៀម ស្មីត៖**

ចំណុចទី២ "អាកប្បកិរិយារបស់អ្នកដឹកនាំនៅៗប្រើប្រាស់អាកប្បកិរិយាជាផ្តាច់ការ ជាពិសេសជាមួយនឹងប្រជាជនមូលដ្ឋាន"។ បំពេញ -- "ចំណុចទី៤ ឲ្យតែឃើញគឺអប់រំបន្ទាន់ បើប្រៀបធៀបបដិវត្តន៍សង្គមនិយមនៅខ្វះខាត មានការបែងចែកវណ្ណៈ ឬក៏ប្រភេទនេះ វណ្ណៈនេះ វណ្ណៈនោះ។ ឧទាហរណ៍ដូចជាពួករណសិរ្សជាដើម"។ ប្រសិនបើយើងមើលទំព័រ 00003336, ជាភាសាអង់គ្លេស ភាសាអង់គ្លេសមានលេខ 00437849, ជាភាសាខ្មែរយើងឃើញថានៅពេលបញ្ចប់ការប្រជុំ គឺថាវាមានបញ្ហាចាត់តាំង សមាជិកគណៈកម្មាធិការក្រសួងបានបញ្ជាក់ថា "ទី១ គឺគណៈសាខាក្រសួង បងវ៉ាន់ លេខា, បងហុង អនុលេខា, បងរឿន សមាជិក, បងវ៉ែន, បងជាម ជាសមាជិក"។

[១៤:០០:១៧]

ខ្ញុំលើកឡើងនូវឯកសារនេះ ដោយសារតែឯកសារនេះផ្តល់នូវការពិភាក្សាផ្ទៃក្នុងនៅក្នុងក្រសួងការបរទេស ក៏ដូចជាអ្វីដែលបានកើតឡើង ពិសេសទាក់ទងទៅនឹងការស្វែងរកខ្មាំង ក៏ដូចជាការគាំទ្រដល់បដិវត្តន៍។

នៅពេលដែលយើងពិនិត្យទៅលើឯកសារមួយនេះ គឺយើងឃើញថា បងវ៉ាន់ ត្រូវបានបង្ហាញនៅផ្នែកនានានៃឯកសារនេះ។ ឥឡូវនេះ ខ្ញុំចង់លើកយកឯកសារ E3/857 គឺជារបាយការណ៍លម្អិតមួយដែលផលិតឡើងដោយក្រសួងការបរទេស ដែលមានចំណងជើងថា "ការធ្វើការជាមួយគណៈ ហើយ

និងអង្គភាពនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧" 00355487 ជាភាសាអង់គ្លេស។ ហើយកថាខណ្ឌដំបូងនៅក្នុងរបាយការណ៍នេះមានចំណងជើងថា "របាយការណ៍សង្ខេបពីអង្គភាព" ចំណុចទី១ គឺសកម្មភាពខ្មាំង។ ខ្មែរ 00086707, ហើយបារាំង 00811227 សូមដកស្រង់៖ "ក្រសួងរបស់យើងនោះ យើងបានកត់សម្គាល់ឃើញថា ជាតិយើងបានកម្ទេច ហើយបោសសម្អាតនូវខ្មាំងជាមូលដ្ឋាន ជា សេ.អ៊ី.អា កា.ហ្សេ.បេ ហើយនិងយួនលេបទឹកដី។ ជាមូលដ្ឋានគឺយើងបានបោសសម្អាតគ្រឿងម៉ាស៊ីន ក្បាលម៉ាស៊ីនខ្មាំងដ៏សំខាន់ ដែលគេធ្វើផែនការ ដែលគេចង់ផ្តួលរំលំយើងទាំងស្រុង ដើម្បីកាន់អំណាចអំពីកម្មករ ពលករ កសិកររបស់យើង ត្រូវបានបោសសម្អាតកម្ទេចចេញអស់ហើយ។ យើងបានឯកភាពគ្នាលើបញ្ហាបោសសម្អាតខ្មាំងទាំងនេះ ទន្ទឹមនឹងនេះ យើងក៏បានឯកភាពគ្នាថា ខ្មាំងមិនទាន់អស់នៅឡើយទេក្នុងក្រសួងយើង ក៏ដូចជាក្នុងអង្គភាពនីមួយៗ។ ដូច្នេះយើងបន្តបោសសម្អាតឲ្យបានស្អាតជ្រះស្រឡះក្នុងក្រសួង ក៏ដូចជាអង្គភាពនីមួយ"។

[១៤:០២:៤៩]

នៅខាងក្រោមតទៅទៀត ដោយសង្ខេបនោះ និយាយថា "ប្រសិនបើយើងមើលនៅក្នុងក្រសួងទាំងមូលយើងឃើញថា ៩៨ភាគរយក្នុងក្រសួងទាំងមូលបានស្អាត ហើយគឺ៩៨ភាគរយល្អ យល់ពីបញ្ហាបោសសម្អាតខ្មាំង។ ប៉ុន្តែភាគរយទៀត នៅបន្តមាននៅឡើយពីរភាគរយទៀត។ ឥឡូវនេះយើង គេកំពុងតែធ្វើសកម្មភាព។ នៅខាងក្រោម "អង្គភាពនីមួយៗត្រូវមានទស្សនៈច្បាស់លាស់ ហើយត្រូវចាប់អារម្មណ៍ជានិច្ច ហើយយើងត្រូវយកឈ្នះលើអ្វីៗទាំងអស់។ ហើយធ្វើអ្វីដែលចាំបាច់ត្រូវតែធ្វើ ដើម្បីការពារខ្មាំងភាគរយកុំឲ្យលូតលាស់បាន។ បើមិនដូច្នោះទេ យើងនឹងនៅតែមានបញ្ហាទៅទៀត គេនឹងធ្វើឲ្យមានបដិបក្ខ ហើយនិងបំបែកបក្សរបស់យើងនោះ ហើយគេអាចពង្រីកធំឡើងៗ ពីពីរទៅបីទៅបួនទៅប្រាំភាគរយ។ បាទ ដូច្នេះ យើងត្រូវតែបោសសម្អាត ហើយនិងបង្រួមឲ្យតូចឲ្យនៅកាន់តែតូចរហូតទៅដល់មួយចុចប្រាំ ឬមួយកន្លះតែប៉ុណ្ណោះ"។ នេះជាឯកសារដែលនិយាយពីការចាប់ផ្តើមចេញពីក្រសួងការបរទេស ក៏ប៉ុន្តែយើងឃើញច្បាស់ថាមានការយោងនៅក្នុងទីនោះ ដែលថាជាប្រភពនៃឯកសារនោះ គឺក្រសួងនេះឯង គឺមានយោងគឺថា "យើងត្រូវបង្កើនការប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់នៅក្នុងក្រសួង ពីព្រោះថាវាមានខ្សែរបស់បរទេស"។ ហើយចំណុចមួយទៀតគឺថា និយាយពីផ្នែកនយោបាយគឺថាវាមាន គេឃើញមានខ្មាំងនៅក្នុងនោះជាដើម។

[១៤:០៤:៤៨]

ផ្នែកមួយទៀតនិយាយថា ជាឧទាហរណ៍តួនាទីរបស់ ប-១ នោះគឺថាសំខាន់ចំនួនបួន។ នេះហើយជាភារកិច្ចដែលសំខាន់របស់ក្រសួងការបរទេស។

លោក លោកស្រីចៅក្រម ខ្ញុំមិនដកស្រង់ចេញពីសេចក្ដីនៅក្នុងឯកសារនេះទេ ប៉ុន្តែខ្ញុំសូមជម្រាបថា គោលបំណងនៃឯកសារនេះ ខ្លឹមសារនេះគឺផ្ដោតទៅលើទិសដៅទៅលើខ្មាំង ហើយនិងពង្រឹងបដិវត្តន៍សង្គមនិយមរបស់គេនោះឯង។ ខ្ញុំសូមជម្រាបថា ផ្អែកតាមអង្គហេតុនេះ នេះជាភស្តុតាងអំពីតួនាទីដែលក្រសួងការបរទេសដែលលោក អៀង សារី បានអនុវត្តនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។

លោក លោកស្រីចៅក្រម ឥឡូវនេះយើងចូលទៅឯកសារមួយទៀត E3/1550 គឺជាសំបុត្រមួយមាននៅក្នុងចម្លើយសារភាពរបស់ ហ៊ូ នឹម ហៅ ភី។ ចេញពីឯកសារនេះ យើងមើលឃើញថា ហ៊ូ នឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៥។ នៅក្នុងសំបុត្រជូនទៅ នៅខាងដើមសំបុត្រនោះគេដាក់ថា “ជូនបក្សកុម្មុយនីស្តកម្ពុជា គឺសូមគោរពខ្ពស់ជាងជីវិត បងប៉ុល, បងនួន, បងវ៉ាន់, បងវ៉ន, បងខៀវ ហើយនិងសមមិត្តហែម”។

[១៤:០៦:៣៣]

បន្ទាប់មកទៀត នៅពេលដែលយើងបានអានសំបុត្រនេះទៅខាងក្រោម យើងឃើញច្បាស់ថា ហ៊ូ នឹម ត្រូវបានចាប់នៅថ្ងៃនេះឯង។ ហើយគាត់បានសូមអង្វរករទៅបក្សដែលមានជនមួយចំនួននៅក្នុងបញ្ជាក់លើក្បាលសំបុត្រនេះ ដើម្បីសុំឲ្យរួចរស់ជីវិត។ នៅក្នុងកថាខណ្ឌមួយ ខ្មែរ 00003118, បារាំង 0076688, ហើយអង់គ្លេស 0075961 (ស៊ីក) គាត់បាននិយាយថា “ខ្ញុំសូមជម្រាបបក្សដាច់ខាតថា ខ្ញុំពុំដែលក្បត់បក្ស ពុំដែលធ្វើការជាភ្នាក់ងារ សេ.អ៊ី.អា ទេ ឬក៏ភ្នាក់ងារពួកយួន ពួក សឹង ង៉ុកថាញ់ នោះទេ ដើម្បីបង្កប់ក្នុងបក្ស ឬក៏បំផ្លាញបក្សនោះទេ។ ហើយខ្ញុំប្រកាន់ជំហរដាច់ខាត ទោះបីជាបក្សក្លាយទៅជាអ្វីក៏ដោយ”។

កថាខណ្ឌមួយទៀត “ជាដំបូងនេះខ្ញុំសូមអនុគ្រោះ ខ្ញុំមិនរត់ទៅណាទេ បក្សឃុំឃាំងខ្ញុំក៏ឃុំឃាំងចុះ តែសូមបក្សអនុគ្រោះដោយកុំបាច់ចងច្រវាក់ហ្នឹង។ ខ្ញុំសូមឲ្យបក្សដោះលែងខ្ញុំ ខ្ញុំមិនរត់ទៅណាទេ។ បើសិនខ្ញុំរត់ សូមបក្សបាញ់ខ្ញុំសម្លាប់ទៅ”។ នេះហើយគឺជាខ្លឹមសារសំបុត្ររបស់ជនម្នាក់ដែលគាត់បញ្ជូនទៅបក្ស ហើយនៅក្នុងនោះដែលថាមានលោក ប៉ុល ពត, នួន ជា, អៀង សារី, វន វេត, សុន សេន ហើយនិង ខៀវ សំផន ផងដែរ។

[១៤:០៨:៣៧]

ភាពពាក់ព័ន្ធនៃឯកសារនេះ លោក លោកស្រីចៅក្រម គឺថាប្រជាជនតែងតែនិយាយសំដៅនៅលើសំបុត្ររបស់ ហ៊ូ នឹម នេះគឺថាគឺជាបុគ្គលដែលមានអំណាចខ្ពស់បំផុតនៅក្នុងបក្សនៃកាលនោះ ដែលគាត់សុំអង្វរករសុំឲ្យដោះគាត់ឲ្យបានរួចជីវិតនោះ។

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតចូលទៅដល់ការនិយាយអំពីទំនាក់ទំនងអំណាចនៅក្នុងបក្ស។ ឥឡូវនេះ យើងអាចត្រឡប់ទៅឯកសារមួយទៀតជាឯកសារវីដេអូ។ ឯកសារ D នោះ គឺ D108/32.2។ ខ្ញុំនឹងមានឯកសារ E ជូនឥឡូវនេះ គឺនិយាយថា សេចក្តី -- វីដេអូសង្ខេបខ្លីពី តាម៉ុក គឺសមាជិកគណៈអចិន្ត្រៃយ៍ ដែលពន្យល់អំពីទំនាក់ទំនងអំណាចនៅក្នុងរវាងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍។ ដូច្នេះខ្ញុំសូមអនុញ្ញាតពិនិត្យរកបន្តិច។

**លោក វីណ្ស៊ៀម ស្មីត៖**

ខ្ញុំសូមអភ័យទោស ខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីឲ្យផ្នែកសោតទស្សន៍បញ្ចាំងវីដេអូនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម។ មន្ត្រីបច្ចេកទេសសោតទស្សន៍ចាក់បង្ហាញវីដេអូ នៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៤:១០:៤៧]

*(ការបង្ហាញឯកសារវីដេអូ)*

*"ប៉ុល ពត ដែលខ្ញុំថាទទួលខុសត្រូវនៅកម្ពុជា ប៉ុល ពត ជាបុគ្គលទី១, នួន ជា បុគ្គលទី២, អៀង សារី បុគ្គលទី៣, សោ ភឹម បុគ្គលទី៤, ខ្ញុំបុគ្គលទី៥"។*

*(បញ្ចប់ការបង្ហាញឯកសារវីដេអូ)*

[១៤:១១:២៣]

**លោក វីណ្ស៊ៀម ស្មីត៖**

*(គ្មានការបកប្រែ)*

**អ្នកបកប្រែ៖**

ពីអ្នកបកប្រែលោកប្រធាន អ្នកបកប្រែតាមមិនទាន់លេខខាងដើមនៃ ERN អំមិញបាទ។

**លោក វិល្លៀម ស្មីត៖**

បាទ គឺថាគាត់ជាអគ្គរដ្ឋទូតប្រចាំប្រទេសឡាវ ត្រូវបានឃុំខ្លួននៅស-២១ ហើយបើយើងមើលទំព័រខាងដើមអំពីចំណារនេះ ចម្លើយរបស់ មាឃ ទូច បាទហៅ កែម ដែលជា -- អំពីប្រវត្តិសកម្មភាពក្បត់របស់គាត់នោះ គឺនិយាយថា "ជូនបង គឺអនុវត្តសកម្មភាពនៅក្នុងប្រទេសឡាវដូចខាងក្រោម មានទំនាក់ទំនងជាមួយនឹង អេច.ស៊ី.អា ហើយបញ្ជូនអន្តោប្រវេសន៍ទៅខ្មែរ ទៅឡាវ ទៅថៃ ដើម្បីទៅបំពាក់បំប៉ន ដើម្បីប្រឆាំងបដិវត្តន៍"។ ហើយបន្ទាប់មកមានយោងអំពីរបៀបដែលអ្នកនោះធ្វើការជាមួយអគ្គរដ្ឋទូតយួនជាដើម។ ទាក់ទងទៅនឹងឯកសារនេះ គឺថានៅខាងដើម នៅខាងលើហ្នឹង ខាងស្តាំដៃ គឺមានចំណារថា "សមមិត្ត វ៉ាន់"។ ហើយភាពពាក់ព័ន្ធនៃឯកសារនេះ គឺនិយាយថា អគ្គរដ្ឋទូតចេញពីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ដែលគេបានជូនដំណឹងអំពីលោក អៀង សារី អំពីបញ្ហានេះតាមរយៈចំណារនេះហើយ។ ហើយឯកសារនេះ ក៏ស្ថិតនៅក្នុងស-២១ ហើយជនដែលមានឈ្មោះនេះក៏ក្លាយទៅជាជនរងគ្រោះនៃស-២១ នោះដែរ។

[១៤:១៣:១១]

លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតចូលទៅដល់ការបង្ហាញនូវវីដេអូ មួយ E3/3052R ដែលនិយាយថា ឯកសារភាពយន្តអំពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញអំពីការប្រជុំមហាមីទិ្ទងរបស់បក្សកុម្មុយនីស្តកម្ពុជាដែលយើងឃើញ នួន ជា, អៀង សារី ហើយនិងមេដឹកនាំផ្សេងទៀត។ ជាពិសេសនៅលើវេទិកានៅពេលនោះ។ បាទ ហើយខ្ញុំនឹងសូមអនុញ្ញាតឲ្យបង្ហាញ បញ្ចាំងនូវវីដេអូឃ្លីបនេះបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីសោតទស្សន៍ដាក់បង្ហាញវីដេអូឃ្លីបនៅលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៤:១៤:១៤]

*(ការបង្ហាញឯកសារវីដេអូជារូបភាព)*

[១៤:១៦:០៧]

**លោក ច័ន្ទ តាវារស្មី៖**

លោកប្រធាន ខ្ញុំសូមជម្រាបលោកប្រធានផងដែរថា ខ្សែវីដេអូនេះគឺពុំមានសំឡេងទេបាទ។

សូមអរគុណ។

[១៤:២១:៥១]

**លោក វីណ្ឌៀម ស្មីត៖**

សូមអរគុណ លោក លោកស្រីចៅក្រម។ ជាថ្មីម្តងទៀត ភាពពាក់ព័ន្ធនៃឯកសារនេះគឺអំណាចជាក់ស្តែងរបស់លោក អៀង សារី ហើយនិងមេដឹកនាំផ្សេងទៀតមាននៅក្នុងសម័យកាលនោះ។ លោក លោកស្រី ឥឡូវនេះខ្ញុំសូមត្រឡប់ទៅរកឯកសារថ្មី E3/989 គឺជាតារាងពេលវេលាដែលដាក់បញ្ចូលនូវដំណើរបរទេសរបស់លោក អៀង សារី ទៅបរទេសក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយប្រៀបធៀបទៅនឹងកំណត់ត្រាស-២១ អំពីការចាប់ខ្លួន ហើយនិងការសម្លាប់បុគ្គលិកនៅក្រសួងការបរទេស។ ឯកសារនេះផលិតឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ដោយមានគោលបំណងក្នុងការប្រៀបធៀប តើពេលណាខ្លះដែលបុគ្គលិកក្រសួងការបរទេសត្រូវបានចាប់ខ្លួន ឬក៏សម្លាប់នៅស-២១? ត្រូវបានប្រហារជីវិត ឬថាតើ អៀង សារី នៅឬក៏មិននៅក្នុងប្រទេសនៅក្នុងពេលដែលមានការចាប់ខ្លួន ឬក៏ការកាប់សម្លាប់បានកើតឡើងនោះ?

[១៤:២៣:២២]

ខ្ញុំសូមអនុញ្ញាតបង្ហាញអេក្រង់នេះ អ៎! នៅលើតារាងនេះនៅលើអេក្រង់ ដើម្បីជាការពន្យល់ដែលខ្ញុំសូមអានដើម្បីឱ្យមានការយល់ដឹងបន្តទៅទៀត។ តារាងនេះគឺបានបែងចែកអំពីហេតុការណ៍ អំពីការកាប់សម្លាប់ ការចាប់ខ្លួន ហើយនិងដំណើរទៅបរទេសរបស់លោក អៀង សារី ដោយផ្អែកទៅតាមកាលវិភាគពេល។ ហើយយើងមើលកាលវិភាគលំដាប់លំដោយនៅលើអេក្រង់ ដែលចាប់ផ្តើមឡើងនៅពីសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបញ្ចប់រហូតទៅដល់ចុងនៃរបបនោះ។ តាមពិតយើងមើលឃើញថា អ្នកវិភាគរបស់ការិយាល័យចៅក្រមស៊ើបអង្កេតនេះ គឺបានបើកមើលពិនិត្យឯកសារទាំងអស់នៅក្នុងសំណុំរឿងដែលពាក់ព័ន្ធទៅនឹងអវត្តមានរបស់លោក អៀង សារី ទៅក្រៅប្រទេស នៅក្នុងគណៈប្រតិភូ ឬក៏ការដែលគាត់អញ្ជើញទៅបរទេស។ មានកំណត់ត្រា១៥០ជាង ដែលថាបុគ្គលិកក្រសួងការបរទេសហ្នឹងគឺត្រូវបានចាប់ខ្លួន ហើយសម្លាប់នៅស-២១ នៅក្នុងសម័យកាលនោះ។ អ្នកវិភាគនោះនិយាយថា "នៅក្នុងឯកសារនេះអ្នកទោស៩៩ ហើយនិងការកាប់សម្លាប់ដែលថា ៩៥ នៅលើតារាងនេះគឺថា មានកាលវិភាគមិនពេញលេញទាំងស្រុងទេ សេចក្តីសន្និដ្ឋានដោយអ្នកវិភាគនោះបញ្ជាក់ថាបើមើលពេលវេលាគឺមិនមែនជាបញ្ជីទាំងស្រុង នៃដំណើរបរទេសរបស់លោក អៀង សារី ទេ គប្បីតែអានគួបជាមួយសក្ខីកម្ម

ជាភស្តុតាងរបស់សាក្សីផ្សេងទៀត ប៉ុន្តែអ្វីដែលយើងអាចពិនិត្យឃើញនោះ -- បាទ សូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ផងដែរ អ្វីដែលយើងឃើញនៅលើអេក្រង់ លើតារាងពេលនេះ។ សូមអនុញ្ញាតទៅទំព័របន្ទាប់ បាទ សូមត្រឡប់ទៅទំព័រទី១ឡើងវិញ យើងអាចឃើញក្នុងតារាងពេលវេលា គឺថាបន្ទាប់ទី១ គឺទាក់ទងទៅនឹងការកាប់សម្លាប់ ហើយនិងការដាក់ពន្ធនាគារ។ ទី៣ គឺថាបញ្ជាក់អំពីដំណើរការទៅក្រៅប្រទេសរបស់លោក អៀង សារី ហើយមាននៅក្នុងសំណុំរឿង។ ផ្អែកតាមការវិភាគលើព័ត៌មាននេះ គឺថាផ្អែកទៅលើស្ថិតិនេះ អៀង សារី គឺពិតជានៅក្នុងប្រទេសប្រហែល ៨០ភាគរយនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ ហើយគាត់នៅក្រៅប្រទេសនោះប្រហែលជា២០ភាគរយនោះទេ ផ្អែកលើព័ត៌មានដែលយើងទទួលបានដោយអ្នកវិភាគរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ។

[១៤:២៦:១៨]

អ្វីដែលខ្ញុំចង់ជម្រាបតុលាការនោះគឺថា ផ្អែកតាមព័ត៌មាននេះ អៀង សារី តួនាទីរបស់គាត់នោះគឺបង្ហាញថា -- ឯកសារនោះបង្ហាញថា គាត់មានតួនាទី គឺច្រើន ភាគច្រើននៅក្នុងប្រទេសជាជាងនៅក្រៅប្រទេស នេះហើយពាក់ព័ន្ធទៅនឹងការដឹងអំពីសកម្មភាពដែលថាគាត់បានអនុវត្ត ឬក៏បុគ្គលិកក្រោមបង្គាប់របស់គាត់អនុវត្តនៅក្នុងសម័យកាលនោះ។

លោក លោកស្រីចៅក្រម ឥឡូវនេះខ្ញុំចង់ត្រឡប់ សូមអនុញ្ញាតត្រឡប់ទៅរកឯកសារចុងក្រោយមួយ នេះជាឯកសារ E3/89 ជាបទសម្ភាសន៍របស់ ស្ទីវិន ហេដឌ័រ ហើយនិងលោក អៀង សារី នៅថ្ងៃ ១៧ ខែធ្នូ ឆ្នាំ១៩៩៦។ នៅក្នុងបទសម្ភាសន៍នោះគាត់បានសួរលោក អៀង សារី នូវសំណួរមួយចំនួនជាពិសេសទាក់ទងទៅនឹងនយោបាយនៃសម័យកាលនោះ ដែលទាក់ទងទៅនឹងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ សំណួរទូទៅនោះគឺថា ដែលគាត់សួរទៅគាត់នោះគឺថា ស្ទីវិន ហេដឌ័រ សួរទៅគាត់នៅទំព័រទី១ ជាសំណួរដ៏វែង ប៉ុន្តែគឺថាអាចគាត់សួរ។

[១៤:២៧:៥៦]

"ស្ទីវិន ហេដឌ័រ៖ ខ្ញុំចង់ចាប់ផ្តើមជាមួយនឹងបញ្ហា ប្រល័យពូជសាសន៍ ហើយសុំឲ្យលោកផ្តល់យោបល់អំពីការវាយតម្លៃរបស់ខ្ញុំលើបញ្ហានេះ។ ផ្អែកលើភស្តុតាងដែលខ្ញុំបានឃើញរហូតដល់ពេលនេះខ្ញុំជឿជាក់ថាមាន-- មិនមានផែនការប្រព្រឹត្តប្រល័យពូជសាសន៍ទេ ប៉ុន្តែប្រល័យពូជសាសន៍បានកើតមានឡើង លទ្ធផលនៃនយោបាយបួន ហើយនិងការអនុវត្ត រួមគ្នាបួន។ ទី១ គឺមានផែនការក្នុងការអនុវត្តការធ្វើឲ្យទៅជាវណ្ណៈអធន ហើយនិងវិធីរបស់អង្គការដោយការបង្ខំ ហើយធ្វើឡើងលឿនពេក។ ទី២

មានផែនការក្នុងការអនុវត្តធ្វើខ្មែររូបនីយកម្មដោយវិធីសាស្ត្របង្ខំឱ្យល្បឿនលឿនដូចខាងលើនោះដែរ។ ទី៣ អ្នកណាដែលជំទាស់ អ្នកណាដែលតស៊ូ ឬក៏មិន បានអនុវត្តផែនការនេះ នឹងត្រូវចាត់ទុកថាជាខ្មាំង ឬក៏ជនក្បត់ជាតិ ហើយក្បត់បក្ស ពីព្រោះផែនការនេះ គឺចាត់ជាសំខាន់ដើម្បីឱ្យកម្ពុជាចូលទៅជាសង្គមនិយមដ៏ខ្លាំងមួយ ដែលមានលទ្ធភាពឯករាជ្យផុតពីមូលធនវៀតណាមបាន។ ចំណុចទី៤ អ្នកណាដែលត្រូវបានចោទថាជាខ្មាំង ឬក៏ជនក្បត់នោះ ត្រូវចាប់ខ្លួនដោយសន្តិសុខ ធ្វើទារុណកម្ម ឱ្យធ្វើសារភាព ហើយឆ្លើយដាក់អ្នកផ្សេង ហើយនិងក្រោយមកសម្លាប់។ អំណាចក្នុងការចាប់ខ្លួន ទារុណកម្ម ហើយនិងសម្លាប់មនុស្សគឺកើតមានឡើងជាដំបូង ឬក៏ក្រៅផ្លូវការ ចេញមកពីមជ្ឈិម ហើយចូលទៅដល់ថ្នាក់ភូមិភាគ តំបន់ ហើយនិងស្រុក នៅក្នុងសហករណ៍ នៅក្នុងអង្គភាពយោធានោះផងដែរ។ ហើយការប្រើប្រាស់ទារុណកម្មត្រូវបានបង្កើតនូវការពង្រីកនូវចំនួនខ្មាំង ឱ្យកាន់តែច្រើនឡើង។

[១៤:២៩:៥៦]

នៅពេលជាមួយគ្នានេះដែរ ការខកខានខាងសេដ្ឋកិច្ច និងយោធារបស់បដិវត្តន៍ហ្នឹងនាំឱ្យមានការមនុស្សជាច្រើន ហើយមានការចោទប្រកាន់មនុស្សថាក្បត់ជាតិជាច្រើននៅក្នុងជួរបក្ស។ លទ្ធផលជាទូទៅគឺកើតជាប្រល័យពូជសាសន៍ ទោះបីជាមិនមានផែនការឱ្យធ្វើបែបនេះក្តី”។

ឆ្លើយតបនឹងសំណួរដ៏វែងនេះ អៀង សារី បានឆ្លើយថា៖ ខ្ញុំក៏បានឃើញរឿងរ៉ាវអ៊ីចឹងដែរ។ នេះហើយដែលគេសួរថាតើខ្ញុំត្រូវនិយាយពីប្រល័យពូជសាសន៍ដែរទេ? ខ្ញុំនិយាយថា តើមានន័យដូចម្តេចជាផែនការនៃការធ្វើប្រល័យពូជសាសន៍ គឺធ្វើឱ្យពូជសាសន៍មួយត្រូវបាត់ ប៉ុន្តែបើតាមខ្ញុំមិនឃើញមានផែនការនោះទេ។ ប៉ុន្តែអ្វីដែលលោកបាននិយាយនេះ អំពើដែលបានកើតឡើងគឺឃើញជាក់ស្តែងក្នុងធ្វើឱ្យមានការឈឺចាប់ដល់ប្រជាជាតិ ប្រទេសជាតិ។ គំនិតរបស់ខ្ញុំ ដូចរបស់អ្នក ដូចដែលលោកនិយាយអ៊ីចឹង បដិវត្តន៍គឺថាមានបញ្ហាជាច្រើន ហើយនិងស្មុគស្មាញជាច្រើន។ មនុស្សមួយចំនួនត្រូវបានចាត់ទុកថាធ្វើខុស ហើយកាន់តែកើនឡើង។ ហើយខ្ញុំក៏យល់ស្របជាមួយលោកលើបញ្ហានេះ។ នៅក្នុងចំណុចពីរដំបូងរបស់លោក ទី១ គឺថាដើម្បីធ្វើឡើងដើម្បីបង្កើតនូវមូលដ្ឋានកុម្មុយនីស្តដ៏រឹងមាំមួយ ដើម្បីឱ្យប្រទេសឆាប់រហ័សលឿនជាងវៀតណាម ដើម្បីកុំឱ្យវៀតណាមដើរទាន់យើង ហើយកុំឱ្យទាហានមកកុងត្រូលត្រួតត្រាលើប្រទេសកម្ពុជានោះទៀត។ នេះគឺពិតទាំងស្រុងហើយ។ ជាការយល់ដឹងទូទៅអំពីថ្នាក់ដឹកនាំ។

[១៤:៣១:៥២]

ហើយនៅចំណុចបន្តទៀតគឺនិយាយអំពីអំណាចរបស់គណៈអចិន្ត្រៃយ៍។ ក្នុងពេលមួយគឺថាមានការសម្រេចចិត្តមួយ ឬការមានការយល់ដឹងមួយ ដែលយើងត្រូវធ្វើជាលក្ខណៈបែបនេះ ឬក៏មួយយ៉ាងម៉េចដែរ? អៀង សារី បានឆ្លើយថា៖ ជាការត្រឹមត្រូវ ចាប់តាំងពីពេលដែលទទួលបានជោគជ័យនៅក្នុងសង្គ្រាម៥ឆ្នាំ ប្រឆាំងនឹងការឈ្លានពាន គំនិតនេះត្រូវបានបង្កើតឡើងចាប់ពីពេលនោះមក។ ប៉ុន្តែរហូតមកដល់ចុងឆ្នាំ៧៥ ទើបគំនិតនេះត្រូវបានប្រើប្រាស់ឡើង ហើយវាត្រូវបានគេយកមកអនុវត្ត ដើម្បីប្រើប្រាស់នៅក្នុងលក្ខណៈមួយដ៏ឆាប់រហ័សក្នុងបង្កើតជាសហគមន៍មួយ ហើយនិងធ្វើឲ្យយួនគ្មានលទ្ធភាពដណ្តើម លេបយកទឹកដីកម្ពុជា។ ហើយនៅពេលនោះហើយ ដែលសកម្មភាពនុ៎ងត្រូវបានគេធ្វើឡើង។ ក៏ប៉ុន្តែគំនិតទាំងអស់នេះ គឺគំនិតដែលភ័យខ្លាច ត្រូវបានលេបទឹកដីដោយវៀតណាម ហើយនិងគំនិតដែលថាវៀតណាមនឹងចូលមកឈ្លានពាន បានកើតឡើងនៅចំពោះមុខយើង។ តាមពិតទៅនៅពេលដែលយើងចូលរួមនៅក្នុងសង្គ្រាមប្រឆាំងបារាំង វាគំនិតនេះត្រូវបានកើតឡើង។ គឺជាគំនិតដែលថា យួនអាចលេបទឹកដីកម្ពុជា។

[១៤:៣៣:០៦]

ទោះបីជាយ៉ាងណាក៏ដោយ យើងធ្វើការព្យាយាមដើម្បីរក្សានូវសាមគ្គីភាពជាមួយវៀតណាមដើម្បីឈ្នះសង្គ្រាមលើពួកអាណានិគមបារាំង។ លោក ស្ទីវ ហេដឌ័រ បានបន្តទៀតថា៖ ថាតើមានការប្រជុំកម្រិតគណៈមជ្ឈិមដែរឬទេនៅក្នុងឆ្នាំ៧៥ ដែលថាមានគោលដៅជាក់លាក់មួយចំនួន ត្រូវបានគេដាក់ឡើងទាក់ទងទៅនឹងបញ្ហានេះ? ចម្លើយ៖ នៅក្នុង នៅខែ៦ ឆ្នាំ៧៥ គឺមានការប្រជុំមួយដើម្បីសម្រេចថាតើយើងត្រូវធ្វើដូចម្តេចដើម្បីរារាំងមិនឲ្យវៀតណាមចូលមកគ្រប់គ្រងកម្ពុជា។ សំណួរ៖ តើបញ្ហានេះត្រូវបានសម្រេចនៅកម្រិតគណៈមជ្ឈិម ឬក៏គណៈអចិន្ត្រៃយ៍? ចម្លើយគឺថា៖ ការណ៍នេះត្រូវបានសម្រេចនៅកម្រិតគណៈអចិន្ត្រៃយ៍ មិនមែនគណៈមជ្ឈិមទេ គឺគណៈអចិន្ត្រៃយ៍។ សំណួរ៖ តើអ្នកណាខ្លះនៅក្នុងគណៈអចិន្ត្រៃយ៍នាពេលនោះ? ចម្លើយ៖ តាមពិតទៅគណៈអចិន្ត្រៃយ៍នៅពេលនោះគឺមាន ប៉ុល ពត, នួន ជា, សោ ភឹម, ខ្ញុំ, សុន សេន ហើយនិង តាម៉ុក។ ស្ទីវ ហេដឌ័រ បានសួរថា៖ តាម៉ុក ហើយនិង វន វ៉េត ឬក៏មិនមែនទេ? អៀង សារី បានឆ្លើយថា៖ បាទ គឺ វន វ៉េត។ ស្ទីវ ហេដឌ័រ បានសួរទៀតថា៖ ចុះ ខៀវ សំផន? អៀង សារី ឆ្លើយថា៖ ខៀវ សំផន មិនមែនទេ ប៉ុន្តែ ខៀវ សំផន មានវត្តមាននៅពេលនោះ"។

[១៤:៣៤:២៤]

ខ្ញុំសូមថ្លែងអំណរគុណសម្រាប់ផ្តល់ឱកាសដល់ខ្ញុំនៅថ្ងៃនេះ ដើម្បីធ្វើបទបង្ហាញអំពីឯកសារទាំង

អស់នេះជូនដល់សាធារណជនក្នុងលក្ខណៈមួយជាលក្ខណៈរួម។ ហើយខ្ញុំសូមធ្វើការបញ្ចប់បទបង្ហាញរបស់ខ្ញុំនៅពេលនេះ ទាក់ទងទៅនឹងតួនាទីរបស់លោក អៀង សារី។ សូមអរគុណអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាស២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះប្រាំនាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៥ នាទី ដល់ម៉ោង ១៤:៥៧ នាទី)*

[១៤:៥៧:១៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

អញ្ជើញលោកមេធាវី!

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម នៅក្នុងពេលសម្រាកនេះ ខ្ញុំបាននិយាយជាមួយលោក សុន អរុណ ហើយលោកបានជូនដំណឹងថាកូនក្តីរបស់ខ្ញុំឥឡូវនេះគាត់បានចុះហត្ថលេខាលើលិខិតដកៗនូវការបោះបង់សិទ្ធិរបស់គាត់វិញ។ ឥឡូវនេះ គឺយើងនៅក្នុងដំណើរក្នុងការបញ្ជូនទៅអង្គជំនុំជម្រះ ហើយនិងភាគីទាំងអស់តាមរយៈ អ៊ីម៉ែល ហើយនិងចម្លងជូននូវលិខិតរបស់គាត់ក្នុងការដកការបោះបង់សិទ្ធិរបស់គាត់ពីមុននោះទៅវិញ។ សូមអរគុណបាទ។

[១៤:៥៨:៣០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៥៩:៥៣]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

តើលោកអាចជម្រាបដល់អង្គជំនុំជម្រះឲ្យបានច្បាស់លាស់ ជាងអម្បាញ់មិញនេះបានដែរឬទេ ថាតើការលះបង់សិទ្ធិរបស់លោក -- អ៎! ការដកនូវសិទ្ធិអវត្តមាននៅក្នុងកិច្ចដំណើរការសវនាការ ការដាក់បង្ហាញឯកសារគន្លឹះនានា ដែលអង្គជំនុំជម្រះបានកំណត់ធ្វើសវនាការនាពេលនេះនេះ តើគាត់ដកនូវផ្នែកណា ឬក៏ដកទាំងស្រុងនៃកិច្ចដំណើរការសវនាការ ឬក៏ដកតែផ្នែកណាមួយ ដូចជាដកនូវផ្នែកដែលពាក់ព័ន្ធទៅនឹងការដាក់បង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ នួន ជា គឺរបស់គាត់?

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ហើយគាត់បាន -- ពីមុនគាត់ដកបោះបង់សិទ្ធិក្នុងការចូលរួមក្នុងការបង្ហាញឯកសារទាក់ទងនឹងតួនាទីរបស់គាត់។ ដូច្នេះការបង្ហាញរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងតួនាទីរបស់លោក ខៀវ សំផន យើងអាចបន្តបាន។ ប៉ុន្តែការបោះបង់សិទ្ធិនោះ ដូចដែលបានខ្ញុំពិភាក្សាជាមួយសហសេវិករបស់ខ្ញុំ សុន អរុណ នោះ គឺថានេះជាអនុសាសន៍ដែលយើងបានទទួលពីកូនក្ដីរបស់យើងខ្ញុំ។ យើងខ្ញុំមិនអាចអានភាសាខ្មែរទេ ប៉ុន្តែខ្ញុំគិតថា គឺជាទាក់ទងទៅនឹងការបោះបង់សិទ្ធិរបស់គាត់ក្នុងការចូលរួមនោះឯង បើគាត់ដក គឺគាត់ដកអានុំង ខ្លឹមសារនុំងឯងមកវិញបាទ។

[១៥:០១:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់ឲ្យលោកបំភ្លឺខ្ញុំលោក កូប៉េ។ លោកនិយាយថា គាត់បានបោះបង់សិទ្ធិក្នុងការវត្តមាននៅក្នុងការបង្ហាញឯកសារទាក់ទងទៅនឹងគាត់។ ខ្ញុំគិតថា គាត់បោះបង់សិទ្ធិ គាត់ដកការបោះផងសិទ្ធិហ្នឹង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំមានអត្ថន័យបែបដូច្នោះមែន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ចាស អរគុណ។

[១៥:០២:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

ដើម្បីបញ្ជាក់បន្ថែមលើបញ្ហាដែលកើតមានឡើងនេះ អង្គជំនុំជម្រះក៏សូមជម្រាបជូនអំពី -- នូវលទ្ធផលនៃការពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃនេះ។ នៅថ្ងៃនេះខាងវេជ្ជបណ្ឌិតទទួលថែទាំព្យាបាលលោក នួន ជា នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានពិនិត្យឃើញថាសភាពទូទៅល្អ ហើយក្អកម្តងម្កាល កម្តៅ ៣៧ដឺក្រេ ដង្ហើម និងចង្វាក់ដង្ហើមពុំមានអ្វីប្រែប្រួលទេ។ កម្លាំងកំហែងប្រសើរជាងមុន ប៉ុន្តែពុំទាន់មានលទ្ធភាពអាចក្រោកអង្គុយដោយខ្លួនឯងបាននៅឡើយ។ ស្ថានភាពសុខភាពមានលំនឹង បើប្រៀបធៀបពីម្សិលមិញ។

បាទ នេះជាលទ្ធផលដែលអង្គជំនុំជម្រះបានទទួលនូវលិខិតពិនិត្យសុខភាពរបស់ជនជាប់ចោទ នួន ជា នៅអម្បាញ់មិញនេះ គឺមុនពេលចូលមកដំណើរការសវនាការថ្ងៃនេះ។ អ៊ីចឹងសូមភាគី និងសាធារណជនជ្រាប។ អ៊ីចឹងលទ្ធភាពវាអាចមានខុសគ្នារវាងបញ្ហាទាំងពីរនេះ។

សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

[១៥:០៣:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រមជម្រាបសួរភាគីទាំងអស់។

ខ្ញុំមានសំណើមួយជូនអង្គជំនុំជម្រះ នៅក្នុងដំណាក់កាលនេះ គឺពាក់ព័ន្ធទៅនឹងការបង្ហាញឯកសារដោយការិយាល័យសហព្រះរាជអាជ្ញា។ ក្នុង -- គឺក្នុងក្របខ័ណ្ឌនៃការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន។ ដើម្បីឱ្យសំណើរបស់ខ្ញុំមានការយល់ច្បាស់នោះ ជាបឋមខ្ញុំសូមរំឭកឡើងវិញ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ គឺឯកសារដែលមានលេខ E90/7 ជាពិសេសនោះ គឺនៅក្នុងកថាខណ្ឌ២២ នៃសេចក្តីសម្រេចនេះ ដែលមានចែងដូចតទៅ "នៅក្នុងក្របខ័ណ្ឌច្បាប់របស់ អ.វ.ត.ក អង្គជំនុំជម្រះយល់ឃើញថា កំណត់ហេតុស្តាប់ចម្លើយឬប្រតិចារឹកដែលស្នើដាក់នៅចំពោះអង្គជំនុំជម្រះ ដែលពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានចាត់ទុកថាច្បាប់មិន

អនុញ្ញាតឡើយ អនុលោមតាមវិធានផ្ទៃក្នុង ៨៧(៣)(ឃ) នៃវិធានផ្ទៃក្នុង និងមិនអាចយក -- ទទួលយកបានឡើយសម្រាប់គោលបំណងនេះ លើកលែងតែកំណត់ហេតុ ឬប្រតិចារឹកមួយចំនួនដែលមានបង្ហាញនៅខាងក្រោមនេះ។

[១៥:០៥:៤១]

គេប្រាប់ខ្ញុំថា ឲ្យខ្ញុំនិយាយឲ្យយឺតៗ ដូច្នេះខ្ញុំនិយាយឡើងវិញ។ និងមិនអាចយកទទួលយកសម្រាប់គោលបំណងនេះឡើយ លើកលែងតែកំណត់ហេតុ ឬប្រតិចារឹកមួយចំនួន ដែលបង្ហាញនៅខាងក្រោមនោះ ឬលើកលែងតែមេធាវីការពារក្ដីត្រូវបានឱកាស ផ្ដល់នូវឱកាសក្នុងការពិនិត្យសាក្សីផ្ដល់ចម្លើយទាំងនេះនៅក្នុងសវនាការ។

លោកប្រធាន ផ្អែកតាមសេចក្ដីសម្រេចនេះ នៅថ្ងៃនេះខ្ញុំស្នើឲ្យសហព្រះរាជអាជ្ញាកុំឲ្យបង្ហាញអំពីឯកសារ២០ ដែលមានលេខដូចតទៅ នៅពេលដែលខ្ញុំនិយាយថា ឯកសារ២០នេះគឺស្ថិតនៅក្នុងបញ្ជីបង្ហាញពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន សម្រាប់ថ្ងៃទី៣០ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ គឺមានលេខយោង១០.១៨ ដែលជាលិខិតរបស់សម្ដេច សីហនុ។ ខ្ញុំសូមកុំឲ្យបង្ហាញឯកសារលេខ ៧០ និង៧១ នៃបញ្ជីនេះ គឺឯកសារទី១ នេះគឺលេខ IS20.35។ ឯកសារទី២ E190.1.72។ ចំពោះអ្នកបកប្រែគឺថា លេខឯកសារនេះគឺ ឯកសារលេខ២០ គឺស្ថិតនៅក្នុងបញ្ជីឯកសារដែលបញ្ជូនដោយសហព្រះរាជអាជ្ញានៅក្នុងក្របខ័ណ្ឌនៃការបង្ហាញឯកសារពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន។

[១៥:០៧:៤៤]

ខ្ញុំសូមបញ្ជាក់ផងដែរថា មានឯកសារមួយទៀត គឺប្រភេទដូចគ្នានឹងដែរគឺលេខ ៧៣ គឺឯកសារ E3/464។ ខ្ញុំសូមបញ្ជាក់ថា ពាក់ព័ន្ធទៅនឹងលិខិតរបស់ព្រះបរមសពសម្ដេចព្រះ នរោត្តម សីហនុ នោះឯកសារនេះគឺបង្កជាបញ្ហា គឺវាពាក់ព័ន្ធទៅនឹងការស្នើសាក្សីរបស់មេធាវី ខៀវ សំផន គឺនៅក្នុងឧបសម្ព័ន្ធ ខ នៃចម្លើយដែលមានលេខយោង E9/14/1/1.12 ERN ជាភាសាអង់គ្លេស 00650078 គឺនៅលេខ៣៧នៃតារាងដែលមេធាវីការពារក្ដី ខៀវ សំផន ស្នើសុំសាក្សី -- ឲ្យកោះហៅសាក្សី ហើយនៅក្នុងនោះមានឈ្មោះរបស់ -- មានព្រះបរមនាមរបស់សម្ដេចព្រះ នរោត្តម សីហនុ ហើយសហព្រះរាជអាជ្ញាបានជំទាស់ ដោយពន្យល់ថាការស្នើសុំនេះគឺមិនមានភាពពាក់ព័ន្ធនោះទេ។

ដូច្នេះខ្ញុំគិតថា នៅថ្ងៃនេះយើងមិនអាចបង្ហាញឯកសារនេះបានទេ ពីព្រោះថា យើងមិនមានលទ្ធភាពក្នុងការទទួលបានព័ត៌មានបន្ថែមពីបុគ្គលដែលសរសេរលិខិតនេះ ពីព្រោះថាព្រះអង្គបានទទួល

ព្រះរាជមរណភាពហើយ។

[១៥:០៩:៣៧]

ដូច្នេះយើងខ្ញុំសូមឲ្យអង្គជំនុំជម្រះគោរពតាមគោលការណ៍ ដែលបានចែងនៅក្នុងសេចក្ដីសម្រេច ដែលបានលើកឡើងនេះ។ ហើយក៏សូមឲ្យអង្គជំនុំជម្រះបញ្ជាក់ជូនសហព្រះរាជអាជ្ញាថា កុំឲ្យយក ឯកសារនេះមកបង្ហាញនៅក្នុងសវនាការនេះ។ សូមអរគុណលោកប្រធាន ដែលបានផ្ដល់វេទិកានេះជូន យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:១០:០៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងមេធាវី ភាគីទាំងអស់។ ជា អកុសល្យនោះ គឺថាយើងត្រូវចាប់ផ្ដើមបទឧទ្ទេសនាមអំពីការកែតម្រូវ បើតាមមតិរបស់លោកស្រីមេធាវី អម្បាញ់មិញនេះ។ ចម្លើយដែលមេធាវីការពារក្ដីលើកអំមិញនោះ គឺថាត្រូវបានធ្វើឡើងដោយចំពោះ បុគ្គលដែលទទួលមរណភាពជាដើម។ ដូច្នេះផ្អែកតាមវិធានដែលអនុវត្តនៅលំដាប់អន្តរជាតិនោះគឺថា គឺ យើងត្រូវយោងទៅរកវិធានទាំងអស់នោះ នៅក្នុងសេចក្ដីសម្រេចដែលមេធាវីបានលើកឡើងអំមិញ។

ប្រសិនបើមេធាវីនៅតែបន្តអាន គឺអានកថាខណ្ឌ៣២ ដែលនិយាយ ហើយនិងពន្យល់ទៅតាម ពាក្យរបស់លោក លោកស្រីចៅក្រមដែលថា ចម្លើយរបស់បុគ្គលដែលមិនអាចមកបង្ហាញ ឬក៏មរណ ភាពនោះ គឺថាអាចយកមកប្រើបាន ដើម្បីបញ្ជាក់ពីអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ។

[១៥:១១:១១]

ដូច្នេះ អ្វីដែលលោកស្រីមេធាវីលើកអម្បាញ់មិញនេះគឺធ្វើឲ្យមានការភ័ន្តច្រឡំដល់អង្គជំនុំជម្រះ ក្នុងការទទួលយកការបង្ហាញឯកសារនេះ។ ហើយសេចក្ដីសម្រេចនោះគឺថា សេចក្ដីមុននោះគឺស្របទៅ នឹងស្ដង់ដារអន្តរជាតិ។ ដូច្នេះ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា សូមបដិសេធសំណើរបស់លោកស្រី មេធាវីអម្បាញ់មិញនេះ។ ហើយអនុញ្ញាតឲ្យយើងខ្ញុំប្រើឯកសារដូចដែលយើងបានស្នើ ដើម្បីឲ្យគោរព ទៅតាមគោលការណ៍នេះ ថ្ងៃនេះ ឬក៏ថ្ងៃស្អែកនោះ ហើយនិងទាក់ទងទៅនឹងការកំណត់ដូចដែលអង្គជំនុំ ជម្រះបានកំណត់ហើយ។ ដូច្នេះយើងខ្ញុំសូមស្នើបែបនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញមេធាវីការពារក្តី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំត្រូវតែផ្តល់ការបញ្ជាក់ជូនទៅអ្វីដែលខាងសហព្រះរាជអាជ្ញាបានលើកឡើង។ នៅពេលដែលលោកចង់យកឯកសាររបស់បុគ្គលដែលទទួលមរណភាពហើយដែលពាក់ព័ន្ធទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទនោះ គឺថាមិនត្រូវធ្វើនៅក្នុងការបង្ហាញឯកសារនោះទេ ពីព្រោះថាមានការជជែកតវ៉ាដោយមានកម្រិត។ ដូច្នេះបើលោកចង់ធ្វើបែបនេះត្រូវតែធ្វើសំណើទៅជាលាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះដើម្បីសុំការអនុញ្ញាតប្រើប្រាស់ឯកសារនេះ ហើយខ្ញុំនៅតែរក្សានូវការជំទាស់របស់ខ្ញុំដដែល។

[១៥:១២:៤៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១៧:១៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសួរបញ្ជាក់អំពីបញ្ហាឯកសារមួយចំនួន ដែលមានការជំទាស់តវ៉ាពីមេធាវីការពារក្តីទៅតំណាងសហព្រះរាជអាជ្ញាដែលជាអ្នករៀបចំក្នុងការដាក់គ្រោង និងដាក់បង្ហាញឯកសារទាំងនេះ។

សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ជាក់ដោយខ្លីទេ លោកសហព្រះរាជអាជ្ញា អង្គជំនុំជម្រះបានស្តាប់ការជំទាស់ដែលលើកឡើងដោយមេធាវីការពារក្តី ខៀវ សំផន ពាក់ព័ន្ធទៅនឹងឯកសារមួយចំនួន។ អ្វីដែលអង្គជំនុំជម្រះចង់ដឹងនៅពេលនេះថា តើឯកសារដែលមេធាវីការពារក្តី ខៀវ សំផន ជំទាស់នោះមានដាក់នៅក្នុងបញ្ជីឯកសារដែលបានដាក់ជូនអង្គជំនុំជម្រះដែរឬទេ? ឬក៏ឯកសារទាំងនោះសុទ្ធសឹងជាឯកសារថ្មី ហើយក្នុងករណីនេះពាក់ព័ន្ធទៅនឹងការទទួលយកឯកសារមានលក្ខណៈផ្សេង។ យើងបានស្តាប់ឮថាមានឯកសារមួយចំនួនដែលបានទទួលលេខកូដ E3 រួចទៅហើយ។ ដូច្នេះយើងខ្ញុំគិតថាពាក់ព័ន្ធទៅនឹងឯកសារទាំងអស់នោះគឺថាមាននៅក្នុងបញ្ជី ហើយត្រូវបានសម្រេចដោយអង្គជំនុំ

ជម្រះរួចហើយ។ ចុះៗ -- ប៉ុន្តែចំពោះឯកសារផ្សេងទៀតនោះ តើលោកសហព្រះរាជអាជ្ញាអាចបញ្ជាក់បានទេ? ហើយលោកមិនចង់បង្ហាញឯកសារនៅរសៀលនេះទេ ដូច្នេះអង្គជំនុំជម្រះអាចសម្រេចនូវបញ្ហានេះនៅថ្ងៃស្អែកព្រឹកបាន។

[១៥:១៩:០៥]

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកចៅក្រម ឡាវ៉ែន៍។ ឯកសារទាំងអស់នេះគឺដាក់បញ្ចូលនៅតាមវិធាន៨០ ជាឯកសារក្នុងឆ្នាំ២០១១ ដែលថានៅក្នុងពេលនោះ ខ្ញុំបានស្នើ យើងថាជាឯកសារបន្ថែម។ យើងខ្ញុំស្នើបែបនេះ ហើយឯកសារ E190.1.72 ហើយតាមពិតដែលខ្ញុំនឹងពិនិត្យផ្ទៀងផ្ទាត់ឡើងវិញនៅពេលយប់នេះ ហើយនិងជូនព័ត៌មានឲ្យបានគ្រប់គ្រាន់រួចរាល់នៅពេលចាប់ផ្តើម ពេលព្រឹកនេះ។

ខ្ញុំមិនស្នើឯកសារពិសេសនេះ នៅក្នុងពេលដែលយើងនៅសល់ថ្ងៃនេះទេ ហើយខ្ញុំៗសូមជម្រាបអង្គជំនុំជម្រះ ហើយនិងភាគី ហើយខ្ញុំបញ្ជាក់ថា គឺថាវិធាន៨០នេះ បញ្ជីនេះគឺថាខ្ញុំនឹងពិនិត្យមើលឡើងវិញយប់នេះ ប្រសិនបើចាំបាច់យើងនឹងផ្តល់ព័ត៌មានបន្ថែមទៀត ហើយជាពិសេស គឺទាក់ទងទៅនឹងបុគ្គល ឬក៏សាក្សីដែលបានទទួលមរណភាព។ ប៉ុន្តែហើយអ្នកដែលគាត់តែងអត្ថបទ ឬក៏លិខិតនោះទទួលមរណៈ អាហ្នឹងគឺជាការពិតបែបដូច្នេះមែន។ សូមអរគុណ។

[១៥:២០:២៨]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ដូច្នេះប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីដាក់បង្ហាញឯកសារ។

**លោក វើង ហ៊ត់៖**

លោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព! សួស្តីភាគីទាំងអស់គ្នា ខ្ញុំ និងសហការីលោក ចារីក នឹងធ្វើការបង្ហាញឯកសារទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន។ លោក លោកស្រីចៅក្រមទាំងអស់ នៅចាំបានថា កាលពីថ្ងៃទី២០ -- អ៎! ថ្ងៃទី១៣, ១៤ ខែកុម្ភៈ ឆ្នាំ២០១២ យើងខ្ញុំបានធ្វើការបង្ហាញឯកសារផ្សេងៗទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងអំឡុងពេលមុនថ្ងៃទី១៧ មេសា ១៩៧៥។ ឯកសារទាំងឡាយដែលយើងខ្ញុំនឹងធ្វើការបង្ហាញជូននៅថ្ងៃនេះ នឹងបន្ថែមទៅលើការបង្ហាញឯកសារកាលពីលើកមុន។

[១៥:២២:១០]

ដូច្នេះយើងខ្ញុំសូមអញ្ជើញលោក លោកស្រីចៅក្រមទាំងអស់ ធ្វើការពិចារណាទៅលើឯកសារដែលបានបង្ហាញទាំងពីរដំណាក់កាលជាមួយគ្នាតែម្តង ដោយហេតុថា ការបង្ហាញទាំងពីរលើកនេះរួមបង្កើតបានជាការតភ្ជាប់គ្នា មិនអាចចែកឲ្យដាច់ពីគ្នាបានឡើយ។ យើងខ្ញុំផ្តល់ជូននូវការបង្ហាញសង្ខេបខ្លីបន្ទាប់មកតាមការអនុញ្ញាតរបស់លោក លោកស្រីចៅក្រម ខ្ញុំនឹងប្រគល់វេទិកានេះ ជូនទៅសហការីលោក ថារីក ដែលនឹងត្រូវធ្វើការបង្ហាញឯកសារទាំងអស់នោះ។ ឯកសារដែលយើងខ្ញុំនឹងត្រូវធ្វើការបង្ហាញនេះ ស្ថិតនៅក្នុងប្រភេទឯកសារដូចខាងក្រោម៖

[១៥:២៣:០៧]

ទី១) សមាសភាពរបស់លោក ខៀវ សំផន នៅក្នុងអង្គការជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជារួមមានគណៈមជ្ឈិមបក្ស និងការចូលរួមរបស់គាត់នៅក្នុងការប្រជុំនានារបស់គណៈអចិន្ត្រៃយ៍បក្ស។

ទី២) ឯកសារផ្សេងៗទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ ការផ្តល់សច្ចានុម័តលើច្បាប់រដ្ឋធម្មនុញ្ញ ការលាលែងតំណែងរបស់សម្តេចនរោត្តម សីហនុ ពីប្រធានរដ្ឋ ហើយនិងការបង្កើតប្រធានរដ្ឋថ្មីដែលមានលោក ខៀវ សំផន ជាប្រធាន។

ទី៣) ឯកសារនានាដែលបង្ហាញភស្តុតាងអំពីការត្រួតត្រារបស់ ខៀវ សំផន នៅក្នុងក្រសួងពាណិជ្ជកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមទាំងរបាយការណ៍ជាច្រើនរបស់ក្រសួងនេះដែលផ្ញើទៅលោក ខៀវ សំផន ផង។

ទី៤) ឯកសារដែលទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលនៃក្រសួងពាណិជ្ជកម្មទាំងឡាយ ដែលធ្វើការនៅក្នុងមន្ទីរនានាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន។

ទី៥) សុន្ទរកថារបស់លោក ខៀវ សំផន ដែលក្នុងនោះមានការផ្តល់ការគាំទ្រនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងដែលឆ្លុះបញ្ចាំងពីតួនាទីរបស់គាត់នៅក្នុងបក្ស ហើយនិងនៅក្នុងរដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យ។

ទី៦) លិខិតឆ្លើយឆ្លងនានារបស់អង្គការលើកលែងទោសអន្តរជាតិផ្ញើជូនលោក ខៀវ សំផន នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលស្វែងរកសូមឲ្យគិតគូរយកចិត្តទុកចំពោះអំពើឧក្រិដ្ឋកម្មនានាជាទ្រង់ទ្រាយធំដែលកំពុងត្រូវបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា។

[១៥:២៥:៤៩]

ទី៧) បទសម្ភាសន៍ និងឯកសារចេញផ្សាយនានារបស់ ខៀវ សំផន ក្នុងនោះរួមទាំងខ្សែវីដេអូ

ជាច្រើន ដែលជនជាប់ចោទលើកឡើងពិភាក្សាអំពីតួនាទីរបស់គាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបនេះ និងអំពីទំនាក់ទំនងរបស់គាត់ជាមួយនឹងក្រុមមេដឹកនាំបក្សដទៃទៀត។ ហើយនិង

ទី៨) ចម្លើយរបស់ ខៀវ សំផន ចំពោះមុខសហចៅក្រមស៊ើបអង្កេត។ ក្នុងនោះគាត់បានលើកយកពិភាក្សាបន្ថែមអំពីតួនាទីរបស់គាត់។

តាមពិតទៅពេលវេលារបស់យើងខ្ញុំមានកំណត់ផងដែរ។ ដូច្នេះ មិនអាចបង្ហាញគ្រប់ឯកសារដែលពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន ទាំងអស់បានទេ។ ក្នុងន័យនេះ ឯកសារដែលយើងខ្ញុំនឹងដាក់បង្ហាញគឺជាឧទាហរណ៍ តំណាងឲ្យភស្តុតាងជាច្រើនដែលទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទ ខៀវ សំផន។ ឯកសារទាំងនេះមានការពាក់ព័ន្ធដោយសារថា នៅក្នុងចំណោមបញ្ហាផ្សេងៗ ឯកសារនេះបង្ហាញឲ្យឃើញអំពីសមាជិកភាពរបស់ ខៀវ សំផន ក្នុងមុខតំណែងជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា និងកម្ពុជាប្រជាធិបតេយ្យ។ ការគាំទ្រ និងការរួមចំណែករបស់គាត់ ចំពោះគោលនយោបាយនានារបស់បក្ស ការយល់ដឹងរបស់គាត់នាសម័យកាលនោះ ចំពោះឧក្រិដ្ឋកម្មនានាដែលកំពុងប្រព្រឹត្ត ដើម្បីការពន្លឿនគោលនយោបាយ និងការការពារយ៉ាងក្លៀវក្លាចំពោះគោលនយោបាយទាំងនោះ។

[១៥:២៨:២២]

តទៅនេះ ខ្ញុំសូមអនុញ្ញាតលោកប្រធាន សូមឲ្យសហការីរបស់យើងខ្ញុំ ថារីក នឹងបង្ហាញភស្តុតាងជាបន្តទៅទៀត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយមុននឹងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះក៏សូមជម្រាបជូនបន្ថែមដល់ភាគី និងសាធារណជន អំពីព័ត៌មានពាក់ព័ន្ធជាមួយនឹងលោក នួន ជា។ តាមលិខិតនៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត លេខ០០០២៧៩៩ ម.ក.ម.ខ.ស បានអនុញ្ញាតឲ្យលោក នួន ជា ចាកចេញពីមន្ទីរពេទ្យនៅថ្ងៃស្អែក នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ វេលាម៉ោងដប់បួនរសៀល។ ហើយបញ្ជាក់ថា លោក នួន ជា ហ្នឹងបានចូលពេទ្យ សម្រាកពេទ្យនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ហើយក៏បានអនុញ្ញាតឲ្យលោក នួន ជា សម្រាកចំនួន១៤ថ្ងៃដែរ គិតពីថ្ងៃចេញពីមន្ទីរពេទ្យ។ ហើយលិខិតនេះចេញដោយលោកគ្រូពេទ្យវេជ្ជបណ្ឌិត គីម សមសាន្ត ដែលមានការបញ្ជាក់បានឃើញពីប្រធាន

នាយករងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចាន់ វិចិត្រ។

សូមជ្រាបជាព័ត៌មានបាទ!

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅលោកតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការដាក់បង្ហាញឯកសារភស្តុតាង។

[១៥:២៩:៥៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ជាដំបូងខ្ញុំសូមបញ្ជាក់ក្នុងពេលដ៏ខ្លីនេះថា ដូចដែលសហការីខ្ញុំបានបញ្ជាក់រួចមកហើយតាមបញ្ជី តាមវិធាន៨០ គឺឯកសារដែលយើងបានដាក់ទាក់ទងទៅនឹងការជំទាស់របស់មេធាវីការពារ ខៀវ សំផន គឺនៅក្នុងបញ្ជីខែមេសា ឆ្នាំ២០១១ របស់យើង។ ប៉ុន្តែ ដូច្នេះខ្ញុំនឹងធ្វើការបញ្ជាក់នៅក្នុងឧបសម្ព័ន្ធដើម្បីឲ្យមានភាពងាយស្រួលក្នុងការបញ្ជាក់ទៅលើបញ្ហាអស់ទាំងនេះ។ គឺធ្វើតាមអ៊ីម៉ែលដើម្បីបញ្ជាក់បំភ្លឺ។

យើងសូមចាប់ផ្តើមបទបង្ហាញរបស់យើងទៅលើឯកសារ ដែលពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន ដែលយើងពិនិត្យមើលជាដំបូងទៅចម្លើយតបរបស់ ខៀវ សំផន ដែលបានផ្តល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត។

[១៥:៣១:០៣]

ឯកសារទាំងនោះ គឺជាឯកសារដែលពាក់ព័ន្ធព្រោះជាឯកសារថ្មីៗ ហើយលើកយកជាពិសេសទៅលើបទចោទជាក់លាក់ប្រឆាំងនឹងលោក ខៀវ សំផន។ គឺជាការលើកឡើងពីព្រឹត្តិការណ៍ដោយខ្លួនលោកផ្ទាល់។ គឺក្នុងចម្លើយតបទាំងនោះ គឺមាននូវព្រឹត្តិការណ៍ ក៏ដូចជាហេតុការណ៍ជាក់លាក់មួយចំនួនទាក់ទងទៅនឹងតួនាទីរបស់គាត់នៅក្នុងពេលអតីតកាលកន្លងមក។ គឺការសម្ភាសនេះធ្វើឡើងនៅចុងឆ្នាំ២០០៧ ដែលលោក ខៀវ សំផន ធ្វើការផ្តល់ចម្លើយចំនួនបួនទៅឲ្យសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំនឹងផ្តល់នូវលេខ E3 ដើម្បីជាកំណត់ត្រាប្រតិចារឹកគឺ E3/557។ នេះគឺជាសវនាការពិភាក្សាមួយដែលលោក ខៀវ សំផន -- គឺជាសវនាការតទល់មួយដែលធ្វើឡើងជាមួយលោក ខៀវ សំផន។ មួយទៀតគឺ E3/27 នេះគឺជាកំណត់ហេតុសួរចម្លើយរបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃ១៣ ខែធ្នូ ២០០៧ ហើយមានការសម្ភាសមួយទៀតនៅថ្ងៃ១៤ ខែធ្នូ ២០០៧ គឺឯកសារដែលមានលេខ E3/37 និងទី៣ -- និងឯកសារមួយទៀតគឺមាន E3/210 គឺធ្វើឡើងនៅថ្ងៃ១៤ ខែធ្នូ ២០០៧ ដែរ។ ហើយនៅខែ

កុម្ភៈ ២០០៨ ចាប់ពីថ្ងៃ ចាប់ពីខែកុម្ភៈ ឆ្នាំ២០០៨ លោក ខៀវ សំផន សម្រេចថារក្សានៅស្ងៀមមិនផ្ដល់ចម្លើយអ្វីទាំងអស់ ហើយក្នុងប្រកាសនេះគឺមាននៅក្នុងឯកសារដែលមានលេខ E3/702។

[១៥:៣២:៥៨]

ជាដំបូង ខ្ញុំសូមចូលទៅក្នុងឯកសារនៅថ្ងៃ១៣ ខែធ្នូ ២០០៧ គឺឯកសារ E3/27។ ឯកសារនេះបានពិភាក្សាទៅលើអង្គហេតុមួយចំនួនពាក់ព័ន្ធទៅក្នុងសំណុំរឿងនេះរួមបញ្ចូលទាំងទីតាំងរបស់លោក ខៀវ សំផន គឺក្នុងរយៈពេលភ្លាមៗបន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញ នៅថ្ងៃ -- ខែមេសា ឆ្នាំ៧៥ គឺគាត់មានវត្តមាននៅឧដុង្គជាមួយនឹង ប៉ុល ពត ព្រមទាំងមន្ត្រី -- ព្រមទាំងអ្នកដឹកនាំជាន់ខ្ពស់ដទៃៗទៀត។ ហើយក៏មានការរៀបរាប់អំពីការពិភាក្សារបស់ -- ដែលលោក ខៀវ សំផន បំពេញការពារពីឆ្នាំ៧០ ដល់៧៥ ហើយក៏រៀបរាប់អំពីការចូលមកទីក្រុងភ្នំពេញ ព្រមទាំងរៀបរាប់អំពីទីតាំងរបស់លោកនៅក្នុងទីក្រុងភ្នំពេញជាមួយ ប៉ុល ពត និង នួន ជា នៅក្នុងឆ្នាំ៧៥ ផងដែរ។

[១៥:៣៤:០៤]

ហើយចុងក្រោយឯកសារនេះក៏និយាយអំពីសមាជិករបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍។ ព្រមទាំងនិយាយអំពីការប្រជុំ អំពីរយៈ អំពីចំនួននៃការប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមនេះផងដែរ។

លោក ស្មីត បានរៀបរាប់អំពីឯកសារទាំងអស់នេះភាគច្រើនរួចមកហើយ។ ដូច្នេះ ខ្ញុំនឹងមិនរៀបរាប់ជាលម្អិតនោះទេ។ ខ្ញុំសូមធ្វើការអាននូវឃ្លាមួយជាពិសេស នេះជាចម្លើយរបស់លោក ខៀវ សំផន ដែលនិយាយអំពីសកម្មភាពនៅក្នុងខែមេសា ឆ្នាំ៧៥។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារនេះនៅលើអេក្រង់ គឺមានលេខ 00156664, ភាសាបារាំងមានលេខ 00156666, ភាសាអង់គ្លេសគឺមានលេខ 00156743។

[១៥:៣៥:០០]

នៅក្នុងឯកសារនេះ លោក ខៀវ សំផន ឆ្លើយតបទៅនឹងសំណួរដែលសួរថា តើលោកមកពីទីកន្លែងណា? នៅពេលដែលគាត់ចូលទីក្រុងភ្នំពេញ។ ហើយគាត់ឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់ “អស់រយៈពេលជាង១០ថ្ងៃ ខ្ញុំនៅទីបញ្ជាការរបស់ ប៉ុល ពត នៅខាងលិចឧដុង្គ។ ខ្ញុំបញ្ជាក់ថា ខ្ញុំមិនបានចូលរួមក្នុងការងារទេ។ ខ្ញុំគ្រាន់តែមានវត្តមានប៉ុណ្ណោះ ហើយខ្ញុំតាមដានព្រឹត្តិការណ៍ ដែល ប៉ុល ពត បានសង្ខេបឲ្យខ្ញុំម្ដងម្កាល។ សំណួរ៖ តើមានវត្តមានអ្នកដទៃទៀតដែរឬទេ? ឆ្លើយ៖ ដូចជាមានតែពីរ

នាក់ខ្ញុំទេ។ ប្រហែលជាមាន នួន ជា ដែរ ប៉ុន្តែខ្ញុំមិនច្បាស់នោះទេ។ មានផងដែរនូវវត្តមានរបស់របស់ប្រធានផ្នែកយោធាដែលដឹកនាំការប្រយុទ្ធ និងដែលមកជាប្រចាំ។ តាម៉ុក ឬអនុរបស់គាត់ដែលជាប្រធានតំបន់ឧត្តរ ឬក៏ កុយ ធួន ឬក៏អនុរបស់គាត់គឺ កែ ពក។ ហើយក៏ប្រែលជាមាន សោ ភឹម ផងដែរដែលជាប្រធានតំបន់បូព៌ា ប៉ុន្តែគាត់មកដោយកម្រណាស់។ សំណួរបន្តៈ តើ សុន សេន មានវត្តមានដែរឬទេ? ឆ្លើយៈ ពិតប្រាកដហើយ។ តាមពិតទៅគាត់មានទីបញ្ជាការនៅជិតនោះ”។

[១៥:៣៦:៥១]

កថាខណ្ឌបន្ទាប់គឺពីរទំព័រនៅខាងក្រោម គឺគេសួរលោក ខៀវ សំផន “ថាតើរវាងឆ្នាំ៧០ និង៧៥ លោកស្ថិតនៅជាអចិន្ត្រៃយ៍ជាមួយមេដឹកនាំខ្មែរក្រហមឬ?” ចម្លើយៈ បាទ។ ពីព្រោះខ្ញុំមានតួនាទីជាអ្នកទំនាក់ទំនងជាមួយសម្តេច នរោត្តម សីហនុ។ នៅពេលដែលមានការបង្កើតរណសិរ្សរួបរួមជាតិបន្ទាប់ពីមានរដ្ឋប្រហារឆ្នាំ៧០ សម្តេច សីហនុ មិនស្គាល់ តាម៉ុក និង ប៉ុល ពត ទេ។ ហើយខ្ញុំជាមនុស្សតែមួយគាត់ដែលអាចធ្វើទំនាក់ទំនងជាមួយព្រះអង្គបាន”។

ខ្ញុំសូមបញ្ជាក់ដោយសង្ខេប ដើម្បីជាកំណត់ត្រាថា កិច្ចសម្ភាសន៍ដដែលហ្នឹងគឺនៅផ្នែកបន្ទាប់គឺនិយាយអំពីទីកន្លែងរបស់ ប៉ុល ពត, នួន ជា និង ខៀវ សំផន បន្ទាប់ពីត្រឡប់មកដល់ទីក្រុងភ្នំពេញ។ ហើយគាត់បានបញ្ជាក់ថា ពួកគាត់ទាំងអស់នោះស្នាក់នៅជាមួយគ្នានៅស្ថានីយរថភ្លើង និងនៅវិហារព្រះកែវមរកត។ ហើយចុងក្រោយមកស្នាក់នៅនៅមាត់ទន្លេ។

[១៥:៣៨:២៨]

ហើយផ្នែកពាក់ព័ន្ធដែលខ្ញុំលើកយកមកធ្វើបទបង្ហាញនៅពេលនេះ គឺមាននៅពីរបីទំព័រខាងក្រោម គឺខ្មែរមានលេខ 00156619 បារាំងគឺមានលេខ 00156672 និងខ្មែរមានលេខ -- សូមអភ័យទោសគឺអង់គ្លេសមានលេខ 00156751 គឺថាចំណុចសំខាន់នៃចំណុចនេះគឺបញ្ជាក់ថា ខៀវ សំផន បានទទួលស្គាល់ថា គាត់គឺជាសមាជិកគណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិម។ ដំបូងជាសមាជិកបម្រុងក្នុងឆ្នាំ៧១ ហើយគាត់ក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ៧៦។ នៅក្រោមចំណុចនេះបន្តិចគេសួរគាត់នូវសំណួរដូចតទៅនេះ “លោកបាននិយាយថាលោកបានចូលរួមនៅក្នុងការពង្រីកនៅក្នុងកិច្ចប្រជុំពង្រីករបស់គណៈអចិន្ត្រៃយ៍ តើលោក -- តើអាចប្រាប់ពីចំណុចនេះបានដែរឬទេ? ឆ្លើយៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានបង្ហាញថា ខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំនោះ១៤ដង ក្នុងចំណោម១៩។ ខ្ញុំបានភ្លេចអំពីចំនួនពិតប្រាកដ ប៉ុន្តែប្រហែលជាក្នុងចំនួននោះ។ ខ្ញុំបញ្ជាក់ថា ខ្ញុំដឹងតែពីកិច្ចប្រជុំណាដែលខ្ញុំបានចូលរួម

ប៉ុណ្ណោះ។ ដូចដែលខ្ញុំបានពន្យល់រួចហើយ ក្នុងពេលនៃការប្រជុំនោះ គេនិយាយអំពីការការពារជាតិ ការកសាងប្រទេស និងជម្លោះជាមួយវៀតណាម។ គឺនៅក្នុងកិច្ចប្រជុំនុំង គឺគេនិយាយអំពីបញ្ហាទាំងអស់នេះ"។

ខ្ញុំសូមបន្តទៅឯកសារបន្តទៀត លោក លោកស្រីចៅក្រមជាទីគោរព! គឺជាកិច្ចសម្ភាសន៍នៅថ្ងៃ ១៤ ធ្នូ ២០០៧ គឺឯកសារ E3/37 ហើយនៅក្នុងឯកសារនេះ ខ្ញុំធ្វើការសង្ខេបថា លោក ឌៀវ សំផន បានពណ៌នាអំពីការចាត់តាំងទៅកាន់មន្ទីរ៨៧០ គឺការចាត់តាំង ឌឿន ហើយនិង ឌៀវ សំផន ខ្លួនគាត់ផ្ទាល់។ ហើយគាត់បានរៀបរាប់អំពីការរស់នៅនៅមន្ទីរក-១ និងក-៣ ជាមួយមេដឹកនាំដទៃទៀត ហើយគាត់ក៏បាននិយាយអំពីសុន្ទរកថា ដែលគាត់បានថ្លែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៥:៤០:៥៨]

ខ្ញុំនឹងធ្វើការជ្រើសរើសនូវឃ្លាមួយចំនួនដែលខ្ញុំត្រូវអាន។ នៅក្នុងសំណួរ-ចម្លើយទី១ លោក ឌៀវ សំផន បាននិយាយដូចតទៅនេះ គឺខ្មែរមានលេខ 00156675, បារាំងមានលេខ 00156680 និងភាសាអង់គ្លេសមានលេខ 00156753។ សំណួរបានសួរដូចតទៅនេះ "ពីមុនលោកបាននិយាយថា ស៊ើ វ៉ាស៊ី ហៅ ឌឿន គឺជាប្រធានមន្ទីរ៨៧០ តើគាត់មានតួនាទីយ៉ាងម៉េចដែរ? ហើយតើអ្នកណាជាអ្នកបន្តក្រោយពីគាត់? គាត់ត្រូវបានគេតែងតាំងក្រោយពី ប៉ុល ពត បង្កើតមន្ទីរនៅក្បែរមាត់ទន្លេ នៅជិតវិហារព្រះកែវមរកត ក្នុងខែមិថុនា ឆ្នាំ៧៥។ គាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៧ ប៉ុន្តែខ្ញុំបានដឹងរឿងនេះ តែនាពេលក្រោយប៉ុណ្ណោះ គឺក្រោយឆ្នាំ១៩៧៩។ ខ្ញុំមិនបានមានការភ្ញាក់ផ្អើលចំពោះអវត្តមានរបស់គាត់ទេ ព្រោះដូចដែលខ្ញុំនិយាយរួចហើយថា ម្នាក់ៗគិតតែពីការងាររបស់ខ្លួនប៉ុណ្ណោះ។ ឌឿន ធ្វើដំណើរច្រើន"។

ហើយឃ្លាបន្ទាប់ដែលខ្ញុំចង់ដកគឺនៅទំព័របន្ទាប់ គឺនិយាយអំពីសមាជិករបស់មន្ទីរ៨៧០ ដែលខ្ញុំបានបញ្ជាក់ពីដើម។ "សំណួរ៖ តើលោកអាចពណ៌នាអំពីរចនាសម្ព័ន្ធ និងសមាជិកភាពរបស់មន្ទីរ៨៧០ បានដែរឬទេ? ចម្លើយ៖ វាជាមន្ទីរមួយនៃគណៈកម្មាធិការអចិន្ត្រៃយ៍ វាមានសមាសភាពតែពីរនាក់ទេ គឺ ឌឿន និង ខ្ញុំ។ ឌឿន ជាប្រធានហើយមានសហការីច្រើនដូចជា ប៉ង់ ជាដើម ហើយគាត់ទទួលខុសត្រូវលើការងារនយោបាយ។ ចំណែកឯខ្ញុំវិញ ដូចដែលខ្ញុំបាននិយាយរួចមកហើយ ខ្ញុំទទួលបន្ទុករៀបចំបញ្ជីតម្លៃសម្រាប់សហករណ៍ការបែងចែកសម្ភារៈសម្រាប់ភូមិភាគ តាមការណែនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងទំនាក់ទំនងជាមួយសម្តេច សីហនុ"។

[១៥:៤៣:៣២]

ឃ្លាបន្តដែលខ្ញុំចង់និយាយយោង គឺខ្មែរមានលេខ 00156677, ភាសាបារាំងមានលេខ 00156683 និងភាសាអង់គ្លេសមានលេខ 00156756 ហើយចំណុចនេះគឺពាក់ព័ន្ធអំពីមុខងាររបស់មន្ទីរ៨៧០។ “សំណួរ៖ តើមន្ទីរ៨៧០ មានមុខងារផ្សេងទៀតក្រៅពីអ្វីដែលលោកបានជម្រាបដែរឬទេ? ឆ្លើយ៖ ពីដំបូងមន្ទីរនេះហាក់ដូចជាមិនមានភាពសំខាន់ទេ ប៉ុន្តែវាចាប់ផ្តើមសំខាន់ ពីព្រោះវាមានតួនាទីដើម្បីមើលការងាររបស់គណៈអចិន្ត្រៃយ៍។ ខ្ញុំដឹងអំពីបញ្ហានេះនៅពេលដែលដួលរលំរបប ហើយនៅពេលដែលខ្ញុំមកដល់ទីក្រុង -- មកដល់ខេត្តប៉ៃលិន”។

ផ្នែកបន្ទាប់ គឺពីរសំណួរនៅខាងក្រោម ហើយនេះជាឃ្លាចុងក្រោយដែលខ្ញុំចង់អាននៅក្នុងអត្ថបទនេះ។ គឺនិយាយអំពីសុន្ទរកថាដែលលោក ខៀវ សំផន បានផ្តល់ ព្រមទាំងខ្លឹមសារនៃសុន្ទរកថានោះ។ “សំណួរ៖ តើលោកយល់ស្របអំពីខ្លឹមសារនៃសុន្ទរកថាដែលលោកបានថ្លែងដែរឬទេ? ប្រសិនបើលោកមិនយល់ស្របទេ តើលោកអាចផ្តល់ឧទាហរណ៍នៃការមិនយល់ស្របរបស់លោកនោះដែរឬទេ? ចម្លើយ៖ ជាទូទៅខ្ញុំយល់ស្របជាមួយហ្នឹង ពីព្រោះវាមានឱសានវាទពីវៀតណាមនៅខែឧសភា ១៩៧៦។ ខ្ញុំសូមរំឭកថា ខ្ញុំត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋនៅខែមេសា ១៩៧៦ ចំពោះចំណុចខ្លះ ខ្ញុំបង្ហាញការមិនយល់ស្របរបស់ខ្ញុំ ឧទាហរណ៍ការលុបបំបាត់លុយដែលនាំឲ្យមិនមានការអភិវឌ្ឍផ្នែកសិប្បកម្ម”។

ហើយចុះក្រោយមបន្តិច “ខ្ញុំមិនអាចបង្ហាញការមិនយល់ស្របរបស់យើងជាសាធារណៈនោះទេ ពីព្រោះម្យ៉ាងមិនត្រូវបង្ហាញអំពីទំនាស់ផ្ទៃក្នុងបក្សឲ្យគេដឹង និងម្យ៉ាងទៀត ខ្ញុំមិនអាចនៅរស់រានមានជីវិតបានទេ ប្រសិនបើខ្ញុំហ៊ានលើកឡើងអំពីការជំទាស់ណាមួយនោះ។ ឧទាហរណ៍របស់ ហ៊ូ នឹម និង ហ៊ូ យន់ ជាភស្តុតាងស្រាប់”។

[១៥:៤៦:១៩]

លោក លោកស្រីចៅក្រម ឯកសារចុងក្រោយដែលខ្ញុំសូមអាននៅក្នុងបណ្តុំនៃការសម្ភាសរបស់លោក ខៀវ សំផន ជាមួយនិងសហចៅក្រមស៊ើបអង្កេត គឺ E3/210។ ការសម្ភាសនេះគឺបន្ត អំពីការភ័យខ្លាច និងការចាប់ខ្លួន ដែលលើក ខៀវ សំផន បានលើកឡើងអំពីការបាត់ខ្លួន និងការចាប់ខ្លួនលោក ហ៊ូ នឹម និង ហ៊ូ យន់ គឺខ្មែរ ERN មានលេខ 00156689, បារាំងមានលេខ 00156694 និងភាសាអង់គ្លេសមានលេខ 00156948។ “សំណួរ៖ នៅព្រឹកនេះលោកបានបញ្ជាក់ថាការចាប់ខ្លួន ហ៊ូ នឹម និង ហ៊ូ

យន់ គឺជាភស្តុតាងនៃភាពមិនអាចនិយាយបានអំពីការមិនយល់ស្របណាមួយ។ ដូច្នេះលោកបានដឹងអំពីការចាប់ខ្លួននិងការសម្លាប់ តើអ៊ីចឹងមែនទេ? ចម្លើយគឺដូចតទៅនេះ៖ ខ្ញុំលើកឡើងអំពីបញ្ហារបស់ ហ៊ូ នឹម និង ហ៊ូ យន់ ប៉ុន្តែខ្ញុំនិយាយតែនៅក្រោយឆ្នាំ៧៩ នេះ។ វាមិនផ្ទុយនោះទេ ដែលខ្ញុំ -- តើមិនមានភាពផ្ទុយគ្នាឬទេ ហ្នឹងដែលម្យ៉ាងលោកអះអាងថាលោកបានដឹងរឿងនេះតែក្រោយឆ្នាំ១៩៨៩ ប៉ុណ្ណោះ ប៉ុន្តែម្យ៉ាងទៀតលោកមានអារម្មណ៍ថា មានការគំរាមកំហែងតាំងតែពីមុនឆ្នាំ៧៩ មកម្ល៉េះ? ឆ្លើយ៖ ខ្ញុំមិនដឹងថា ពន្យល់លោកចៅក្រមរបៀបម៉េចនោះទេ។ វាមានឱសានវាទរបស់វៀតណាម ប៉ុល ពត ខ្លួនគាត់ និងបក្សកុម្មុយនីស្តកម្ពុជាមានអារម្មណ៍ថាត្រូវបានគេគំរាមកំហែង។ ទាំងអស់នេះមិនអនុញ្ញាតឲ្យខ្ញុំបង្កើតឧបទ្ទវហេតុណាមួយនោះទេ។ សំណួរ៖ តើលោកនៅរក្សាចម្លើយរបស់លោក ដែលលោកមិនដឹងអំពីការចាប់ខ្លួនមុនឆ្នាំ៧៩ ដែរឬទេ? ឆ្លើយ៖ មិនមែនមិនដឹងសោះនោះទេ។ ខ្ញុំបានឃើញសមាជិកមួយចំនួនរបស់គណៈកម្មាធិការមជ្ឈិមបាត់ខ្លួនម្តងមួយៗ។ ខ្ញុំមិនអាចផ្តល់ជូនលោកចៅក្រមអំពីឈ្មោះពួកគេបានទេ ព្រោះខ្ញុំមិនជិតស្និទ្ធនឹងពួកគេនោះទេ។ ទោះជាយ៉ាងណាក៏ដោយខ្ញុំមិនដឹងទាល់តែសោះអំពីទំហំនៃហេតុការណ៍នោះ"។

ហើយមុនពេលដែលយើងបញ្ចប់ឯកសារនេះ ខ្ញុំមានអត្ថបទសម្រង់ពីរបីដែលមាននៅក្នុងទំព័រខាងក្រោម ដែលនិយាយអំពីព្រឹត្តិការណ៍នៅចុងឆ្នាំ៧៨ គាត់ដឹងអំពីការសម្លាប់រង្គាលនៅចុងឆ្នាំ៧៨ គឺនៅចុងឆ្នាំ១៩៩៨។

[១៥:៤៩:៤៧]

ជាបន្តទៅទៀតនេះ ខ្ញុំសូមធ្វើការដកស្រង់អំពីកថាខណ្ឌមួយដែលមានលេខខ្មែរ 00156691, បារាំងមានលេខ 00156696 ហើយបារាំងមានលេខ 1 -- អង់គ្លេសមានលេខ 00156951។ ហើយគាត់បាននិយាយអំពីការដឹងរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ពាក់ព័ន្ធទៅនឹងការប្រកាសនៅក្នុងវគ្គស្វ័យទិតៀន ខ្ញុំសូមផ្តល់ឧទាហរណ៍ដូចតទៅ កម្មាភិបាលមួយចំនួនយល់ឃើញថា វាហាក់ដូចជាមិនការត្រឹមត្រូវ ដែលយើងធ្វើការផ្តន្ទាទោសចំពោះអ្នកដែលប្រព្រឹត្តអំពើអសីលធម៌ គឺមានកំហុសសីលធម៌។ ទាក់ទងទៅនឹងការចាប់ខ្លួននៅព្រះវិហារ ពិតជាមែន ប៉ុន្តែអ្នកទោសត្រូវដោះលែងមកវិញ។ ពួកគេបានដោះលែងប៉ុន្តែមិនមានការយល់ស្របជាមួយគេនោះទេ។ គឺថាគ្រប់គ្នាបានយល់ស្របថា ជាការត្រឹមត្រូវ ប៉ុន្តែខ្ញុំមិនដឹងពីវិសាលភាពនៃការចាប់ខ្លួននោះទេ។

[១៥:៥១:១៨]

ចុងក្រោយនៅក្នុងឯកសារនេះ គឺមានការនិយាយអំពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយនិងអារម្មណ៍របស់លោក ខៀវ សំផន នៅពេលនោះ។ គឺខ្មែរមានលេខ 00156690, ភាសាអង់គ្លេសមានលេខ 00156945, បារាំងមានលេខ 00156966។ “ពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្ញុំដឹងច្បាស់ថាប្រជាជនអាចនឹងមានការគ្រោះថ្នាក់នៅតាមផ្លូវ នៅពេលដែលមានការដួលរលំ ខ្ញុំសួរខ្លួនខ្ញុំថា ហេតុអ្វីបានជាមានការជម្លៀស? ខ្ញុំមិនបានធ្វើការសម្រេចបែបនេះទេ គឺវាខុសពីគោលការណ៍របស់ចលនា”។

ផ្នែកចុងក្រោយដែលខ្ញុំដកស្រង់ គឺនិយាយអំពីចម្លើយរបស់ ខៀវ សំផន ដែលបង្ហាញអំពីការព្រួយបារម្ភរបស់គាត់នៅក្នុងខែមេសា ឆ្នាំ៧៥ ហើយគេសួរគាត់ដូចតទៅ គឺសួរគាត់ទាក់ទងទៅនឹងការឈឺចាប់ ដែលប្រជាជនបានទទួលរង។ យើងនឹងពិនិត្យដោយសង្ខេប ថាតើនៅពេលនោះលោក ខៀវ សំផន និយាយយ៉ាងដូចម្ដេច។

[១៥:៥៣:០០]

ប្រធានបទបន្ទាប់ដែលខ្ញុំចង់លើកយកមកនិយាយនៅពេលនេះ គឺពាក់ព័ន្ធទៅនឹងតួនាទីរបស់លោក ខៀវ សំផន នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ក្នុងឋានៈជាថ្នាក់លើរបស់បក្ស ក៏ដូចជានៅក្នុងស្ថាប័ននានានៃបក្ស -- នៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយនេះគឺជាការដែលបានឆ្លុះបញ្ចាំងនៅក្នុងឯកសារផងដែរ ដែលជាឯកសារដែលយើងមាន។

ឥឡូវនេះខ្ញុំសូមបន្តទៅឯកសារដែលមានលេខ E3/182។ ឯកសារនេះគឺជាឯកសារដែលបានបង្ហាញពីពេលមុនកន្លងមកហើយ គឺជាកំណត់ហេតុការប្រជុំអចិន្ត្រៃយ៍នៅថ្ងៃ០៩ ខែ១០ ឆ្នាំ៧៥។ យើងមើលទៅលើឯកសារនេះតែបន្តិចប៉ុណ្ណោះក្នុងពេលនេះ ហើយផ្អែកទៅលើអ្វីដែលសហការីរបស់ខ្ញុំបានពិភាក្សាកន្លងរួចមកហើយទៅលើឯកសារនេះ។ ឯកសារនេះគឺនិយាយអំពីការបែងចែកអំណាច ការបែងចែកតួនាទី និងការប្រតិបត្តិតួនាទី។ ប្រសិនបើយើងមើលទៅលើទំព័រទី១ ទាំងបីភាសា គឺការបែងចែកការងារ និងកិច្ចដំណើរការ។ ការបែងចែកការងារ និងកិច្ចដំណើរការមានដូចតទៅៈ ទី១ គឺសមមិត្តលេខា, ទី២ សមមិត្តអនុលេខា, ទី៣ សមមិត្ត វ៉ាន់ ឬក៏ អៀង សារី។

[១៥:៥៤:៤៥]

ពិតហើយលេខ២ ហ្នឹងគឺលោក នួន ជា។ ហើយយើងឃើញថាលេខ៤ គឺសមមិត្ត ហែម។ ហើយបានបញ្ជាក់តទៅនេះថាទទួលរណសិរ្ស និងរាជរដ្ឋាភិបាលពាណិជ្ជកម្ម ខាងបញ្ជី និងតម្លៃ។

អ្វីដែលយើងគួរកត់សម្គាល់ក្នុងឯកសារនេះផងដែរ គឺថាមានបុគ្គលពីររូបដែលជាសមាជិករបស់គណៈអចិន្ត្រៃយ៍គឺនៅលេខ៦ សមមិត្ត ខៀវ ដែលជា សុន សេន និងលេខ៧ គឺសមមិត្ត វន ឬក៏ វន វ៉េត នោះឯង។ នៅក្នុងបញ្ជីនេះ នៅខាងក្រោមបន្តិចគឺថាសមមិត្តទាំងពីរដែលខ្ញុំអានហ្នឹង គឺនៅក្រោមសមមិត្ត ហែម។ នៅក្នុងលំដាប់លំដោយប្រហាក់ប្រហែលគ្នាដែរ យើងអាចមើលឃើញនៅក្នុងឯកសារផ្សេងទៀត។ ខ្ញុំមិន-- សូមមិនអនុញ្ញាតបង្ហាញទេ គឺឯកសារ E3/858 គឺនិយាយអំពីការបែងចែកឆ្មាំសន្តិសុខ ហើយនិងបុគ្គលិកដទៃទៀតដើម្បីទៅធ្វើការនៅតាមទីកន្លែងនានាក្នុងទីក្រុងភ្នំពេញ។ ក្នុងឯកសារនេះ យើងបានឃើញអំពីការរៀបរាប់ ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នា។ គឺយើងឃើញ ក-១ នៅខាងលើ។ ក-១ គឺជាទីកន្លែងធ្វើការ និងជានិវេសនដ្ឋានរបស់ ប៉ុល ពត ហើយនិង ក-៣ សម្រាប់អ៊ំទី២ ហើយមាន បងវ៉ាន់ ហើយនិង បងហែម ដែលជា ខៀវ សំផន ហើយនៅក្រោម ខៀវ សំផន គឺបងវន។

[១៥:៥៦:៤៧]

លោក លោកស្រីចៅក្រមជាទីគោរព! ក្នុងពេលកន្លងមកនេះ សហការីរបស់ខ្ញុំបានពិភាក្សារួចមកហើយអំពីការប្រជុំដែលធ្វើឡើងរបស់គណៈអចិន្ត្រៃយ៍។ ដូច្នេះ យើងគួរតែពិនិត្យមើលទៅលើអ្នកចូលរួមនៅក្នុងកិច្ចប្រជុំទាំងអស់នោះ ជាពិសេសគឺវត្តមានរបស់ ខៀវ សំផន។

យើងឃើញថាមានការប្រជុំ ២៣ដងរបស់មេដឹកនាំបក្ស។ ហើយនៅក្នុងកិច្ចប្រជុំទាំងអស់នេះ ពេលខ្លះជាកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ ពេលខ្លះមិនមែនទេ។ ប៉ុន្តែសមាជិកដែលចូលរួមគឺបុគ្គលដែលចូលរួមនៅក្នុងកិច្ចប្រជុំនោះបានបញ្ជាក់ថា នេះគឺជាការប្រជុំរបស់មេដឹកនាំបក្ស ឬក៏ជាកម្មាភិបាលដឹកនាំ ដែលក្នុងនោះមាន ប៉ុល ពត, នួន ជា និងសមាជិករបស់គណៈអចិន្ត្រៃយ៍ដទៃទៀតបានចូលរួមផងដែរ។

ក្នុងកំណត់ត្រានៃការប្រជុំទាំង ២៣នេះ មានតែកិច្ចប្រជុំចំនួន១៩ប៉ុណ្ណោះដែលមានបញ្ជីឈ្មោះអ្នកចូលរួម។ នៅក្នុងការប្រជុំទាំង១៩ ដែលមានបញ្ជីឈ្មោះនោះ លោក ខៀវ សំផន ត្រូវបានគេកត់ត្រាថាបានចូលរួមចំនួន ១៦កិច្ចប្រជុំ គឺមានប្រហែលជា៨៤ភាគរយនៃការប្រជុំ។

[១៥:៥៨:២៦]

អ្នកដែលចូលរួមញឹកញាប់ជាង ខៀវ សំផន គឺ ប៉ុល ពត ហើយបន្ទាប់មក នួន ជា ដែលចូលប្រជុំ១៨ ដង។ សមាជិកគណៈអចិន្ត្រៃយ៍ដទៃទៀត រួមមាន សុន សេន និង វន វ៉េន ចូលរួមចំនួន១០ដង

ឬក៏តិចជាងនេះ។

លោកប្រធាន ខ្ញុំឃើញថាយើងដល់ពេលវេលាហើយ ខ្ញុំអាចបន្តទៅមុខ២-៣នាទីទៀត ប្រសិនបើលោកប្រធានអនុញ្ញាត ឬមួយក៏ខ្ញុំអាចនឹងបញ្ចប់ត្រឹមចំណុចនេះ? សូមលោកប្រធាន មេត្តាសម្រេច។

**ប្រធានអង្គជំនុំ៖**

*(មិនឮសំឡេង)*

**លោក អាប់ឌុលឡាក់ ចារីក៖**

ខ្ញុំសូមបន្តទៅទៀត។ ឥឡូវនេះ យើងធ្វើការពិចារណាអំពីព្រឹត្តិការណ៍នៅក្នុងឆ្នាំ៧៥ ដែលនិយាយពីការវិលត្រឡប់របស់សម្តេចព្រះ នរោត្តម សីហនុ មកកាន់ប្រទេសកម្ពុជា។ ហើយនៅក្នុងបរិបទនោះ គឺនិយាយអំពីការលាលែងអំពីតួនាទីរបស់គាត់ជាប្រធានរដ្ឋ ហើយត្រូវបានជំនួសដោយលោក ខៀវ សំផន។

ឥឡូវនេះខ្ញុំសូមអនុញ្ញាតចាក់បង្ហាញនូវខ្សែវីដេអូខ្លីមួយ ដែលក្នុងនេះមានពីរផ្នែក ដែលមានចំនួនប្រហែលជា -- ដែលមានរយៈពេលប្រហែល៣នាទី គឺឯកសារដែលមាន D295/2/2.23R គឺលេខ D295/2/2.23R ហើយខ្ញុំសូមលោកប្រធានអនុញ្ញាត ដើម្បីឲ្យខាងផ្នែកសោតទស្សន៍មេត្តាចាក់បង្ហាញនូវខ្សែវីដេអូនេះ ហើយខ្ញុំគិតថាខាង អេ.វី ខាងសោតទស្សន៍គាត់មាននូវផ្នែកវីដេអូនេះហើយ គឺជាខ្សែវីដេអូផ្នែកទី១។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីខាងផ្នែកសោតទស្សន៍ដាក់ចាក់បង្ហាញនូវវីដេអូឃ្លីបលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៦:០១:០៣]

*(ការបង្ហាញឯកសារវីដេអូជារូបភាព)*

[១៦:០៣:២៣]

**លោក អាប់ឌុលឡាក់ ចារីក៖**

ជាបន្តទៀតនេះ ខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធានអនុញ្ញាតដល់ខាងសោតទស្សន៍ចាក់នូវខ្សែវីដេអូនៅក្នុងផ្នែក(ក)(២) ដែលមានរយៈពេលប្រហែល ១នាទីជាការបង្ហាញវីដេអូអំពីព្រះរាជវិលត្រឡប់របស់ព្រះមហាក្សត្រនរោត្តម សីហនុ ពីប្រទេសចិនមកកាន់កម្ពុជា។ សូមលោកប្រធានមេត្តាអនុញ្ញាត។

[១៦:០៣:៤៧]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត! មន្ត្រីផ្នែកសោតទស្សន៍ចាក់វីដេអូលើអេក្រង់ទូរទស្សន៍តាមការស្នើសុំរបស់តំណាងសហព្រះរាជអាជ្ញា!

[១៦:០៤:០០]

*(ការបង្ហាញឯកសារវីដេអូជារូបភាព)*

[១៦:០៥:១០]

**លោក អាប់ឌុលឡាក់ ថារីក៖**

រូបភាពនេះគឺជារូបភាពដែលមាន ដែលធ្វើឡើងនៅប្រហែលជាខែ៩ ឆ្នាំ៧៥។ យើងមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីកាលបរិច្ឆេទនេះទេ គឺនៅពេលនោះ គឺព្រះអង្គម្ចាស់ នរោត្តម សីហនុ -- ហើយ ឥឡូវនេះខ្ញុំសូមអនុញ្ញាតបន្តទៅមុខ ឬមួយក៏លោកប្រធានចង់ផ្អាកកិច្ចដំណើរការនីតិវិធីនេះសិន?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណតំណាងសហព្រះរាជអាជ្ញា។ បាទ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី៣១ ខែមករា ឆ្នាំ២០១៣ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹកទៅ។ ហើយសវនាការនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងបន្តធ្វើសវនាការការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានាពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទធ្វើឡើងដោយតំណាងសហព្រះរាជអាជ្ញា ការធ្វើអត្ថាធិប្បាយ។

[១៦:០៦:២២]

មានការបកប្រែទេ? ឮទេអ្នកបកប្រែ? មានបញ្ហា?

បាទ សាជាថ្មីម្តងទៀត គឺសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី៣១ ខែមករា ឆ្នាំ២០១៣ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការដោយការដាក់បង្ហាញឯកសារភស្តុតាងគន្លឹះនានា ពាក់ព័ន្ធទៅនឹងតួនាទីរបស់ជនជាប់ចោទ ដែលត្រូវដាក់បង្ហាញដោយតំណាងសហព្រះរាជអាជ្ញា។ ការធ្វើអត្ថាធិប្បាយឬ/និង

ការជំទាស់ និងការឆ្លើយតបទៅនឹងការជំទាស់ភាគីពាក់ព័ន្ធ សូមភាគី និងសាធារណជនជ្រាប។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប គឺលោក អៀង សារី និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ និងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកចូលរួមសវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ដោយទុកឲ្យគាត់នៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការនេះ ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៧ នាទី)*